# ជំពូកទី ៦

# ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

Draft

Draft

# ជំពូកទី ៦
# ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

## ៦.១ សេចក្តីផ្តើម

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ គឺជាការសិក្សា ដើម្បីប្រមើលមើលរកហេតុប៉ះពាល់ ដែលបង្កឡើងពីសកម្មភាពរបស់គម្រោងទៅលើធនធានបរិស្ថានធម្មជាតិ និងបរិស្ថានសង្គម ដែលមាននៅក្នុងតំបន់ និងជុំវិញទីតាំងគម្រោង ដូចជា ការធ្វើឲ្យកខ្វក់នូវប្រភពទឹកអូរក្នុងតំបន់គម្រោង ការបំរែបំរួលសណ្ឋានដី ការហូរច្រោះដី ការបំពុលខ្យល់ ការរំខានដោយសំលេង ការបាត់បង់ព្រៃឈើ និងទីជំរក ការប៉ះពាល់ដល់ជីវៈចំរុះក្នុងទឹក-លើគោក ការប៉ះពាល់ដល់មុខរបរ និងកំរិតជីវភាព ប្រាក់ចំណូល ប្រពៃណី ទំនៀមទំលាប់របស់សហគមន៍មូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់គម្រោងជាដើម។

ការរៀបចំផែនការក្នុងការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ សំរាប់គម្រោងធ្វើអាជីវកម្មរ៉ែលោហៈនៅតំបន់ភ្នំព្រឹក ក្រុមសិក្សាបានប្រមូលឯកសារពាក់ព័ន្ធមួយចំនួនដូចមានបង្ហាញក្នុងជំពូកទី៤ ស្តីពីធនធានបរិស្ថានដែលមានស្រាប់ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដូចជាអាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធ សហគមន៍មូលដ្ឋានដែលរស់នៅក្នុង និងក្បែរទីតាំងគម្រោង ដែលរងនូវការប៉ះពាល់ពីការអភិវឌ្ឍន៍គម្រោង (មានបង្ហាញជូនក្នុងជំពូកទី ៥) ដើម្បីជាមូលដ្ឋានគ្រឹះសំរាប់ធ្វើការវិភាគឲ្យបានល្អិតល្អន់ និងរកវិធានការដោះស្រាយបញ្ហា ទំនាស់រវាងវិនិយោគិន និងសហគមន៍មូលដ្ឋានឲ្យមានប្រសិទ្ធភាព។

ជាមួយគ្នានេះដែរ ការកំណត់នូវទំហំហេតុប៉ះពាល់បរិស្ថានត្រូវបានបែងចែកជាពីរផ្នែកធំៗ គឺហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងវិជ្ជមាន ដែលកើតមានឡើងក្នុងដំណាក់កាលកំណត់ទីតាំង ដំណាក់កាលឈូសឆាយដី-ការសាងសង់ (ការរៀបចំការដ្ឋាន) ដំណាក់កាលធ្វើអាជីវកម្ម និងដំណាក់កាលបញ្ចប់គម្រោង ដោយលើកនូវវិធានការមួយចំនួន ដើម្បីកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានអោយនៅកំរិតអប្បបរិមា និងជំរុញនូវរាល់ហេតុប៉ះពាល់បរិស្ថានវិជ្ជមានឲ្យដល់កំរិតអតិបរិមាដែលបណ្តាលមកពីសកម្មភាពនៃគម្រោង។

នៅក្នុងការវាយតំលៃនេះផងដែរ ក្រុមការងារបានប្រើប្រាស់នូវតារាង Checklist ដើម្បីកំណត់នូវទំហំនៃហេតុប៉ះពាល់បរិស្ថាន ដោយធ្វើការវិភាគថាតើកំរិតនៃការប៉ះពាល់មានកំរិតតិច មធ្យម ខ្លាំង ឬមិនមានការប៉ះពាល់ ព្រមទាំងលើកឡើងនូវវិធានការកាត់បន្ថយឲ្យបានសមស្រប។

## ៦.២ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងវិធានការកាត់បន្ថយ

### ៦.២.១ ដំណាក់កាលកំណត់ទីតាំង

តាមរយៈការសិក្សា និងការអង្កេតព្រៃឈើបានបង្ហាញថា ទីតាំងស្នើសុំមាននៅសេសសល់ជាប្រភេទព្រៃស្រោងរេចរិល ក្នុងនោះប្រភេទដើមឈើដែលគេប្រទះក្នុងតំបន់គម្រោងមានដូចជាដើម កំរៀង ស្លុង សុក្រំ ស្រឡៅ ដែលមានអង្កត់ផ្ចិតតូចជាង១០សង់ទីម៉ែត្រ។ ម្យ៉ាងវិញទៀត បើប្រៀបធៀបនឹងគំរបព្រៃឈើ ព្រៃស្រោង (៩៩ ហិកតា-ផែនទីគំរបព្រៃឆ្នាំ ២០០២ និង ១០៦ ហិកតា- ផែនទីគំរបព្រៃឆ្នាំ ២០០៦) និងដីគ្មានគំរបព្រៃ ឆ្នាំ ២០០២ និងឆ្នាំ ២០០៦ គឺមានការប្រែប្រួល។ តាមការចុះសិក្សាអង្កេតជាក់ស្តែងពី ស្ថានភាពធនធានព្រៃឈើនៅក្នុងតំបន់គម្រោងមានតែដីចំការ និងដីលំនៅស្ថានរបស់ប្រជាពលរដ្ឋភាគច្រើន ចំណែកព្រៃពិតប្រាកដនៅក្នុងទីតាំង

គម្រោងបានបង្ហាញថា មិនមានធនធានព្រៃឈើ ដែលមានតំលៃខាងផ្នែកសេដ្ឋកិច្ចទេ ធនធានព្រៃឈើគឺមានតែនៅលើភ្នំប៉ុណ្ណោះដែលជាព្រៃរេចរិល ហើយភ្នំមួយចំនួនត្រូវបានកាប់រានយកដីធ្វើចំការជាបណ្តើរៗ។

ក. បរិស្ថានធម្មជាតិ

ក.១ ធនធានព្រៃឈើ និងទីជំរក

-ក្នុងទីតាំងគម្រោងធនធានព្រៃឈើមានតែនៅតាមភ្នំ ជាលក្ខណៈព្រៃស្រោង ដោយភាគច្រើនមានតែដីចំការ និងដីលំនៅដ្ឋានរបស់ប្រជាជន។ ទោះយ៉ាងនេះក្តីការស្នើសុំគម្រោង ធ្វើអាជីវកម្មរ៉ែលោហៈលើផ្ទៃដីទំហំ ០៤ (បួន) គីឡូម៉ែត្រក្រឡា របស់ក្រុមហ៊ុន PHU YANG (CAMBODIA) Co.,Ltd ដំណើរការរបស់គម្រោងអាចប៉ះពាល់ដល់ធនធានព្រៃឈើ ដោយសារអាចមានជនទុច្ចរិតបង្កើនបទល្មើសព្រៃឈើ ការបរបាញ់សត្វព្រៃ ការសាងសង់យានដ្ឋានជួសជុលគ្រឿងចក្រ និងកន្លែងស្តុកប្រេងឥន្ធនៈ។ល។

<u>វិធានការកាត់បន្ថយ</u>

-ក្រុមហ៊ុននឹងធ្វើការសហការជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងមានសមត្ថកិច្ចក្នុងការរៀបចំផែនការមេមួយ ឲ្យបានច្បាស់លាស់ ដើម្បីធានាការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន អវិជ្ជមាន ដែលអាចនឹងកើតមានឡើង។

-ផ្ទៃដីព្រៃទ្រនាប់តាមដងអូរមួយចំនួន នៅក្នុងតំបន់គម្រោងខាងក្រុមហ៊ុននឹងធ្វើការសហការជាមួយស្ថាប័នជំនាញ ដើម្បីធ្វើការកំណត់ពីទំហំ១០០ម៉ែត្រសងខាងអូរដែលត្រូវរក្សាទុកដើម្បីជាប្រយោជន៍ជួយថែរក្សាគុណភាពទឹកកាត់បន្ថយការហូរច្រោះ ជាផ្លូវសត្វព្រៃឆ្លងកាត់ ជាជំរកសត្វព្រៃក៏ដូចជាជួយថែរក្សាលំនឹងបរិស្ថានក្នុងតំបន់ផងដែរ។

ខ. បរិស្ថានសង្គម

ខ.១ សតិអារម្មណ៍របស់ប្រជាជន

នៅក្នុងដំណាក់កាលនេះ នឹងអាចបង្កការភ្ញាក់ផ្អើលខាងសតិអារម្មណ៍ដល់ប្រជាជន ដែលរស់នៅក្នុង និងក្បែរតំបន់គម្រោងដោយសារពួកគាត់បានដឹង និងឃើញស្ថាប័នជំនាញពាក់ព័ន្ធនានាចុះទៅសិក្សាពីស្ថានភាពព្រៃឈើ និងការប្រើប្រាស់ដីនៅតំបន់វិនិយោគដោយពួកគាត់គិតថានឹងហានការប៉ះពាល់ដល់ដី ចំការ និង ដីលំនៅដ្ឋាន របស់ពួកគាត់។

<u>វិធានការកាត់បន្ថយ</u>

ដើម្បីបញ្ចៀស និងដោះស្រាយចំពោះការបារម្ភរបស់ប្រជាជនមូលដ្ឋាន ក្រុមហ៊ុននឹងរៀបចំឲ្យមាន:

-ការពិភាក្សាក្រុមជាមួយប្រជាជនមូលដ្ឋាន រឺជាបុគ្គល (ការជ្រើសរើសដីជីកយករ៉ែរបស់ក្រុមហ៊ុនប៉ះពាល់ដល់ដីស្រែចំការ រឺលំនៅឋាន) ដែលទទួលរងនូវការប៉ះពាល់ពីការអនុវត្តន៍គម្រោង ដើម្បីផ្តល់ ជាព័ត៌មានលំអិតស្តីពីព្រំប្រទល់គម្រោង និងគោលដៅក្នុងការវិនិយោគនៅតំបន់នេះ។ បន្ថែមពីនេះទៀត ប្រជាជន ដែលចូលរួមការពិភាក្សា អាចធ្វើការបញ្ចេញមតិយោបល់ក៏ដូចជាបង្ហាញពីកង្វល់របស់ខ្លួន ដោយសារការវិនិយោគក្នុងតំបន់នេះ និងអាចលើកជាសំណូមពររបស់ខ្លួនទៅឲ្យក្រុមហ៊ុនវិនិយោគផងដែរ។

Draft

-ការបង្ហាញយ៉ាងច្បាស់លាស់ដល់ប្រជាជនក្នុងតំបន់គម្រោង អំពីដំណើរការវិនិយោគអាជីវកម្មរ៉ែលោហៈ តាំងពីដំណាក់កាលស្នើសុំរាជរដ្ឋាភិបាលរហូតដល់ដំណាក់កាលវិនិយោគ និងបញ្ចប់គម្រោង ដោយធ្វើបទបង្ហាញយ៉ាងច្បាស់លាស់ពីរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ និងរំលេចនូវរាល់វិធានការកាត់បន្ថយ និងបញ្ចៀសនូវហេតុប៉ះពាល់នានា ដែលនឹងធ្វើការចងក្រងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញរបស់ក្រុមហ៊ុនវិនិយោគរ៉ែលោហៈ PHU YANG (CAMBODIA) Co.,Ltd ។

ខ.២ ការប្រើប្រាស់ដីរបស់ប្រជាជន

តាមការចុះសិក្សាអង្កេតជាក់ស្តែងជាមួយអាជ្ញាធរមូលដ្ឋានបានអោយដឹងថា គម្រោងធ្វើអាជីវកម្មរ៉ែលោហៈរបស់ក្រុមហ៊ុន PHU YANG (CAMBODIA) Co.,Ltd មានពាក់ព័ន្ធជាមួយនឹងដីចំការ និងដីភូមិដ្ឋានរបស់ប្រជាជនភូមិ ភ្នំព្រឹក មានទំហំប្រហែលជាជា ២៤២ ហិកតា។ ការប៉ះពាល់ដល់ដីស្រែ-ចំការរបស់ប្រជាជននៅក្នុងតំបន់នេះបានធ្វើអោយប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់នេះ ដោយសារតែដីស្រែចំការគឺជាកម្មវត្ថុមួយយ៉ាងសំខាន់នៃមុខរបរប្រចាំថ្ងៃរបស់ពួកគាត់។

<u>វិធានការកាត់បន្ថយ</u>

ក្រុមហ៊ុននឹងធ្វើការចរចារជាមួយប្រជាជន (ទិញ រឺ ជួល) ចំពោះដីចំការ និងដីភូមិដ្ឋានដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគ។

### ៦.២.២ ដំណាក់កាលឈូសឆាយដី និងសាងសង់ (ការរៀបចំការដ្ឋាន)

នៅក្នុងដំណាក់កាលនេះ សកម្មភាពរបស់ក្រុមហ៊ុនពុំមានលក្ខណៈខ្លាំងក្លាទេ គឺខាងក្រុមហ៊ុននឹងធ្វើការឈូសឆាយដីសំរាប់សាងសង់ផ្លូវចូលការដ្ឋាន សាងសង់អគារស្នាក់នៅរបស់កម្មករ សាងសង់បង្គន់អនាម័យ សាងសង់ឃ្លាំង ទីលានដើម្បីជ្រើសរើស និងថៃទាំផលិតផលធ្វើអាជីវកម្ម។

ក. បរិស្ថានធម្មជាតិ

ក.១ ធនធានរូបសាស្រ្ត

ក.១.១ ការបំរែបំរួលសណ្ឋានដី

នៅដំណាក់កាលនេះ សកម្មភាពផ្សេងៗរបស់គម្រោងនឹងធ្វើអោយមានការផ្លាស់ប្តូរទ្រង់ទ្រាយស្ថានភាពដើមនៃសណ្ឋានដីដោយសារការឈូសឆាយ និងការចាក់បំពេញដីនៅទីទំនាបដើម្បីសាងសង់ផ្លូវចូលការដ្ឋាន សាងសង់អគារស្នាក់នៅ សំរាប់ការសាងសង់ឃ្លាំងការដ្ឋានធ្វើអាជីវកម្ម។

<u>វិធានការកាត់បន្ថយ</u>

-ក្រុមហ៊ុននឹងធ្វើការឈូសឆាយពង្រាបដី ដើម្បីកសាងហេដ្ឋារចនាសម្ពន្ធ័នានាក្នុងតំបន់គម្រោង ដែលដូចមានចែងក្នុងផែនការមេរបស់ក្រុមហ៊ុនដោយមានការត្រួតពិនិត្យ និងវាយតំលៃយ៉ាងត្រឹមត្រូវពីមន្រ្តីមន្ទីរពាក់ព័ន្ធពិតជាអាចកាត់បន្ថយ ឬបញ្ចៀសនូវការប្រែប្រួលសណ្ឋានដីតំបន់គម្រោងអោយស្ថិតនៅកំរិតអប្បបរមា។

-ម្យ៉ាងវិញទៀតខាងក្រុមហ៊ុននឹងធ្វើការជ្រើសរើសយកទីតាំងដែលសមស្របបំផុត ក្នុងកំរិតជម្រាលពី ០-៥ ដឺក្រេ (តំបន់វាលរាបដែលមានកំរិតជម្រាលប្រហាក់ប្រហែលគ្នា) ដើម្បីធានាអោយបាននូវការកាត់បន្ថយការហូរច្រោះដីអោយបានកំរិតអប្បបរមា។

-ការបង្ហាញយ៉ាងច្បាស់លាស់ដល់ប្រជាជនក្នុងតំបន់គម្រោង អំពីដំណើរការវិនិយោគអាជីវកម្មរ៉ែលោហៈ តាំងពីដំណាក់កាលស្នើសុំរាជរដ្ឋាភិបាលរហូតដល់ដំណាក់កាលវិនិយោគ និងបញ្ចប់គម្រោង ដោយធ្វើបទបង្ហាញយ៉ាងច្បាស់លាស់ពីរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ និងរំលេចនូវរាល់វិធានការកាត់បន្ថយ និងបញ្ចៀសនូវហេតុប៉ះពាល់នានា ដែលនឹងធ្វើការចងក្រងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញរបស់ក្រុមហ៊ុនវិនិយោគរ៉ែលោហៈ PHU YANG (CAMBODIA) Co.,Ltd ។

ខ.២ ការប្រើប្រាស់ដីរបស់ប្រជាជន

តាមការចុះសិក្សាអង្កេតជាក់ស្តែងជាមួយអាជ្ញាធរមូលដ្ឋានបានអោយដឹងថា គម្រោងធ្វើអាជីវកម្មរ៉ែលោហៈរបស់ក្រុមហ៊ុន PHU YANG (CAMBODIA) Co.,Ltd មានពាក់ព័ន្ធជាមួយនឹងដីចំការ និងដីភូមិដ្ឋានរបស់ប្រជាជនភូមិ ភ្នំព្រឹក មានទំហំប្រហែលជាជា ២៤២ ហិកតា។ ការប៉ះពាល់ដល់ដីស្រែ-ចំការរបស់ប្រជាជននៅក្នុងតំបន់នេះបានធ្វើអោយប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់នេះ ដោយសារតែដីស្រែចំការគឺជាកម្មវត្ថុមួយយ៉ាងសំខាន់នៃមុខរបរប្រចាំថ្ងៃរបស់ពួកគាត់។

<u>វិធានការកាត់បន្ថយ</u>

ក្រុមហ៊ុននឹងធ្វើការចរចារជាមួយប្រជាជន (ទិញ រឺ ជួល) ចំពោះដីចំការ និងដីភូមិដ្ឋានដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគ។

**៦.២.២ ដំណាក់កាលឈូសឆាយដី និងសាងសង់** (ការរៀបចំការដ្ឋាន)

នៅក្នុងដំណាក់កាលនេះ សកម្មភាពរបស់ក្រុមហ៊ុនពុំមានលក្ខណៈខ្លាំងក្លាទេ គឺខាងក្រុមហ៊ុននឹងធ្វើការឈូសឆាយដីសំរាប់សាងសង់ផ្លូវចូលការដ្ឋាន សាងសង់អគារស្នាក់នៅរបស់កម្មករ សាងសង់បង្គន់អនាម័យ សាងសង់ឃ្លាំង ទីលានដើម្បីជ្រើសរើស និងថែទាំផលិតផលធ្វើអាជីវកម្ម។

**ក. បរិស្ថានធម្មជាតិ**

**ក.១ ធនធានរូបសាស្ត្រ**

**ក.១.១ ការបំរែបំរួលសណ្ឋានដី**

នៅដំណាក់កាលនេះ សកម្មភាពផ្សេងៗរបស់គម្រោងនឹងធ្វើអោយមានការផ្លាស់ប្តូរទម្រង់ទ្រាយស្ថានភាពដើមនៃសណ្ឋានដីដោយសារការឈូសឆាយ និងការចាក់បំពេញដីនៅទីទំនាបដើម្បីសាងសង់ផ្លូវចូលការដ្ឋាន សាងសង់អគារស្នាក់នៅ សំរាប់ការសាងសង់ឃ្លាំងការដ្ឋានធ្វើអាជីវកម្ម។

<u>វិធានការកាត់បន្ថយ</u>

-ក្រុមហ៊ុននឹងធ្វើការឈូសឆាយពង្រាបដី ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់គម្រោង ដែលដូចមានចែងក្នុងផែនការមេរបស់ក្រុមហ៊ុនដោយមានការត្រួតពិនិត្យ និងវាយតំលៃយ៉ាងត្រឹមត្រូវពីមន្ត្រីមន្ទីរពាក់ព័ន្ធពិតជាអាចកាត់បន្ថយ ឬបញ្ចៀសនូវការប្រែប្រួលសណ្ឋានដីតំបន់គម្រោងអោយស្ថិតនៅកំរិតអប្បបរមា។

-ម្យ៉ាងវិញទៀតខាងក្រុមហ៊ុននឹងធ្វើការជ្រើសរើសយកទីតាំងដែលសមស្របបំផុត ក្នុងកំរិតជម្រាលពី ០-៥ ដឺក្រេ (តំបន់វាលរាបដែលមានកំរិតជម្រាលប្រហាក់ប្រហែលគ្នា) ដើម្បីធានាអោយបាននូវការកាត់បន្ថយការហូរច្រោះដីអោយបានកំរិតអប្បបរមា។

Draft

ក.១.២ ការហូរច្រោះដី

ដីនៅតំបន់អភិវឌ្ឍន៍គម្រោងទទួលរងនូវការហូរច្រោះ ដែលបណ្ដាលមកពីកត្តាធម្មជាតិ និងកត្តាសកម្មភាពទាំងឡាយរបស់គម្រោង។ ម្យ៉ាងទៀតទ្រង់ទ្រាយសណ្ឋានដីនៃតំបន់គម្រោងជាតំបន់ភ្នំដូចនេះវាងាយនឹងសឹករិចរិល និងហូរច្រោះចូលទៅកាន់ទីតាំងទំនាបក្បែរខាងជាពិសេសនៅរដូវមានភ្លៀងធ្លាក់។

<u>វិធានការកាត់បន្ថយ</u>

-ក្រុមហ៊ុននឹងធ្វើការជ្រើសរើសយកទីតាំងដែលមានកំរិតនីវ៉ូទាប (១១២-២២៥ ម៉ែត្រធៀបនឹងរយៈកំពស់របស់ផ្ទៃទឹកសមុទ្រ) និងមានកំរិតរាបស្មើ (០-៥ ដឺក្រេ) ។

-ក្រុមហ៊ុននឹងមិនមានសកម្មភាពឈូសឆាយខ្លាំងនៅរដូវវស្សា។

-ក្រុមហ៊ុននឹងឈូសឆាយដីពង្រាបដីសំរាប់សាងសង់ ដោយគោរពតាមលក្ខណៈទម្រង់ប្រភេទដី និងបែបបទការអនុវត្តន៍របស់ក្រុមហ៊ុន ដើម្បីកាត់បន្ថយការហូរច្រោះដីដោយសារសកម្មភាពសាងសង់នានារបស់គម្រោង។

-ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់អោយបានត្រឹមត្រូវតាមបទដ្ឋានទ្រង់ទ្រាយដី។

-ក្រុមហ៊ុននឹងដាំកំរាលរុក្ខជាតិស្មៅឬកូនឈើតាមជំរាលជើងទេរក្នុងតំបន់ការដ្ឋានរបស់គម្រោងដើម្បីជួយបន្ថយការហូរច្រោះដី។

ក.១.៣ គុណភាពដី

សកម្មភាពរបស់គម្រោងនៅក្នុងដំណាក់កាលនេះអាចនាំអោយមានការខូចគុណភាពដីដោយសារៈ

-ការប្រើប្រាស់គ្រឿងចក្រសំរាប់គោលបំណងផ្សេងៗរបស់គម្រោងបានចូលរួមធ្វើអោយប៉ះពាល់គុណភាពដីដោយសារការហៀរកំពប់ការទុកដាក់ ឬច្រាលចោលប្រេងម៉ាស៊ីនលែងប្រើទៅលើដី និងការហូរនាំនូវសារធាតុទាំងនោះដោយទឹកភ្លៀងទៅតំបន់ក្បែរៗនោះ។

-ការបង្កឡើងដោយបុគ្គលិក-កម្មកររបស់ក្រុមហ៊ុនក្នុងការទុកដាក់ការលាងសំអាតគ្រឿងចក្រ/ ការចោលនូវសំណល់ប្រេង-ខ្លាញ់សំបកកំប៉ុងប្រេងម៉ាស៊ីនសំណល់ផ្ទះបាយ និងសំណល់ផ្សេងៗទៀតក្បែរបរិវេណការដ្ឋានក៏នឹងធ្វើអោយមានការខូចគុណភាពដីផងដែរ ប្រសិនបើខាងក្រុមហ៊ុន មិនបានធ្វើការគ្រប់គ្រងអោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

<u>វិធានការកាត់បន្ថយ</u>

-មានកន្លែងទុកដាក់ និងលាងសំអាតគ្រឿងចក្រត្រឹមត្រូវគ្រប់គ្រាន់ និងត្រួតពិនិត្យគ្រឿងចក្រទាំងអស់ជាប្រចាំដើម្បីកាត់បន្ថយនូវការលេចជ្រាប ឬលេចប្រេងម៉ាស៊ីនមុននឹងចេញប្រតិបត្តិការ។

-ទុកដាក់នូវប្រេងឥន្ធនៈសំរាប់បំរើការងារនៅក្នុងការដ្ឋាន និងសំណល់ប្រេងម៉ាស៊ីនឲ្យបានត្រឹមត្រូវដោយធ្វើការសាងសង់នូវឃ្លាំងទុកដាក់ប្រេងទាំងនោះអោយបានសមស្របបំផុត ដើម្បីជៀសវាងនូវឧប្បត្តិហេតុនានា ដែលនឹងកើតមានឡើងហើយសំណល់ប្រេងម៉ាស៊ីន និងសន្សំទុកលក់ទៅឲ្យឈ្មួញដែលទិញយកទៅកែច្នៃឡើងវិញ។

-មានផែនការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទអោយបានល្អប្រសើរ គឺជីករណ្ដៅ ដែលមានលក្ខណៈបច្ចេកទេសសំរាប់ទុកដាក់សំណល់រឹងដោយលប់ដីជាប្រចាំ

និងសាងសង់បង្គន់អនាម័យដែលមានអាងស្តុកសំណល់រាវឲ្យបានត្រឹមត្រូវជៀសវាងការបង្ហូរសំណល់រាវ ឬចោលសំណល់រឹង/សំរាមទៅតាមទីសាធារណៈ។

-ធ្វើការណែនាំ និងអប់រំដល់បុគ្គលិក-កម្មករ ដោយហាមប្រាមមិនអោយមានការបោះចោលសំរាមពាសវាល ពាសកាល ឬបង្ហូរសំណល់រាវទៅទីសាធារណៈឡើយ។

ក.១.៤ គុណភាព និងជលសាស្រ្តទឹកលើដី

-ក្នុងទីតាំងគម្រោងមានការធ្វើអាជីវកម្មរ៉ែបែបអាណាធិបតេយ្យ ដូចនេះប្រព័ន្ធអូរធម្មជាតិអាចនឹងត្រូវ រាំងស្ទះ រាក់ ឬប្រែប្រួលល្បឿនទឹកបណ្តាលមកពីការកើនឡើងនូវកករល្បាប់ម៉ដ្ឋ/ភក់ បណ្តាលមកពីសកម្មភាពអាជីវកម្មរ៉ែអាណាធិបតេយ្យទាំងនោះ។

-ការតាំងទីលំនៅរបស់គម្រោងនៅក្បែរប្រភពទឹក ការចោលសំណល់រឹង ដែលមានប្រភពចេញពីសំណល់សំភារៈសាងសង់សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗ មកពីការប្រើប្រាស់របស់បុគ្គលិក-កម្មករគម្រោងឬពីការហៀរកំពប់សារធាតុប្រេងពីគ្រឿងចក្រ និងរថយន្តនោះ បណ្តាលអោយបំពុលដល់គុណភាពទឹក។

<u>វិធានការកាត់បន្ថយ</u>

-ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់នូវសកម្មភាពអាជីវកម្មរ៉ែអាណាធិបតេយ្យ។

-ការតាំងទីលំនៅនឹងស្ថិតនៅឆ្ងាយពីប្រភពទឹកអូរ ៥០ម៉ែត្រ គិតពីកំរិតនៃទឹកជំនន់ និងចាត់វិធានការណ៍យ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង និងសំណល់រាវដោយរៀបចំប្រមូលសំណល់រឹង (សំរាម) យកទៅចោលនៅក្នុងរណ្តៅ ដែលមានសុវត្ថិភាពដល់បរិស្ថាន និងសង្គមព្រមទាំងសាងសង់បង្គន់អនាម័យឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងមានការអប់រំដល់បុគ្គលិក-កម្មករឲ្យយកចិត្តទុកដាក់ខ្ពស់លើបញ្ហាសំណល់រឹង-រាវនេះ។

-សាងសង់កន្លែងស្តុកប្រេងឥន្ទនៈអោយត្រឹមត្រូវ ដោយមិនអោយកំពប់លើដីដែលនាំអោយហូរចូលក្នុងប្រភពទឹកអូរ ហើយក្រុមហ៊ុននឹងត្រូវបានត្រួតពិនិត្យជាប្រចាំយ៉ាងម៉ដ្ឋចត់មុននឹងប្រតិបត្តិដើម្បីធានាមិនអោយមានការលេចជ្រាបប្រេង។

-សាងសង់ឃ្លាំងទុកដាក់ប្រេងឥន្ទនៈប្រកបដោយសុវត្ថិភាព ដើម្បីជៀសវាងនូវឧប្បត្តិហេតុនានាដែលនឹងបង្កឲ្យមានការហៀរ កំពប់ ឬជ្រាបទៅក្នុងដីដែលនាំអោយហូរចូលក្នុងប្រភពទឹកស្ទឹងហើយក្រុមហ៊ុននឹងត្រូវបានត្រួតពិនិត្យជាប្រចាំយ៉ាងម៉ដ្ឋចត់មុននឹងប្រតិបត្តិដើម្បីធានាមិនអោយមានការលេច/ជ្រាបប្រេង។

-ធ្វើការឈូសឆាយដីនៅរដូវប្រាំង ក្នុងករណីមានការឈូសឆាយដីរដូវវស្សាក្រុមហ៊ុននឹងប្រតិបត្តិក្នុងទ្រង់ទ្រាយតូចហើយនៅក្នុងស្ថានភាពលើសណ្ឋានដីរាបស្មើ។

-អនុវត្តតាមផែនការមេរបស់ក្រុមហ៊ុនដោយមានការតាមដាននិងត្រួតពិនិត្យពីមន្ត្រីជំនាញនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងបរិស្ថានជាប្រចាំ។

-ធ្វើការគ្រប់គ្រងសំអាតមែកឈើឬសឈើ និងស្លឹកឈើឲ្យបានល្អជាពិសេសគ្រប់គ្រងនូវល្បាប់ម៉ដ្ឋ/ភក់កុំឲ្យហូរចូលក្នុងប្រភពទឹកអូរដែលមានក្នុងតំបន់គម្រោង និងទប់ស្កាត់ការកើនឡើងកំរិតកករល្អក់ក្នុងប្រភពទឹក។

ក.១.៥ គុណភាព និងជលសាស្រ្តទឹកក្រោមដី

-ការស្តុកប្រេងឥន្ធនៈ ដើម្បីបំរើសេចក្តីត្រូវការសំរាប់សកម្មភាពគ្រឿងចក្ររបស់គម្រោងអាចធ្វើអោយមានការហៀរ ឬកំពប់ប្រេងទៅលើដីដែលកត្តានេះវានឹងនាំអោយមានការបំពុលដល់ប្រភពទឹកក្រោមដីដោយសារតែការហូរនាំសារធាតុប្រេងនៅពេលដែលមានភ្លៀងធ្លាក់។

-សំណល់រឹងដូចជាសំបកកំប៉ុងប្រេងម៉ាស៊ីនសំណល់ផ្ទះបាយ សំណល់បង្គន់អនាម័យ និងសំណល់ផ្សេងៗទៀតអាចនឹងធ្វើអោយមានការបំពុលប្រភពទឹកក្រោមដី ប្រសិនបើការកំណត់ទីតាំងទុកដាក់សំណល់ទាំងនេះមិនបានត្រឹមត្រូវដូចជានៅតំបន់ដែលមានជំរាបទឹកខ្លាំង (ដីមានភាពត្រសុះខ្លាំង)។

-ការឈូសឆាយដីសំរាប់រៀបចំការដ្ឋាន និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធមួយចំនួននៅក្នុងទីតាំងគម្រោងអាចនឹងមានការលប់នូវប្រភពទឹកស្ទឹង ឬប្រឡាយតូចៗខ្លះ ដែលវាអាចជះឥទ្ធិពលទៅដល់ការថយចុះនូវធារទឹកក្រោមដី។

-ការជីកយករ៉ែនិងការចំរាញ់យករ៉ែរបស់ក្រុមប្រកបអាជីវកម្មរ៉ែអាណាធិបតេយ្យនៅលើដីគម្រោងក៏បង្កឲ្យប៉ះពាល់ខ្លាំងដល់ទឹកក្រោមដី។

<u>វិធានការកាត់បន្ថយ</u>

-សាងសង់ឃ្លាំងទុកដាក់ប្រេងឥន្ធនៈប្រកបដោយសុវត្ថិភាព និងរៀបទំនប់ការពារព័ទ្ធជុំវិញឃ្លាំងដើម្បីជៀសវាងនូវឧប្បត្តិហេតុនានាដែលនឹងបង្កឲ្យមានការហៀរកំពប់ ឬជ្រាបទៅក្នុងដី។

-មានផែនការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទអោយបានប្រសើរ ដោយធ្វើការជ្រើសរើសទីតាំងដែលមានអំណោយផលសំរាប់ជីករណ្តៅ (ដីដែលមានលក្ខណៈស្រទាប់ដីឥដ្ឋក្រាស់ដែលអាចកាត់បន្ថយបាននូវជំរាបសារធាតុពុល) សំរាប់ទុកដាក់សំរាបប្រកបទៅដោយបច្ចេកទេស ដើម្បីធានាមិនអោយមានការជ្រាបឬលេចចេញពីរណ្តៅដែលនាំអោយមានការបំពុលទៅដល់ខ្សែទឹកក្រោមដី។ ចំពោះសំណល់រាវចេញពីបង្គន់អនាម័យក្រុមហ៊ុននឹងធ្វើការជីកអាងស្តុកសំណល់រាវអោយបានសមស្របតាមលក្ខណៈបច្ចេកទេស។

-ការឈូសឆាយដីត្រូវអនុវត្តឡើងស្របតាមផែនការមេជាក់លាក់ ដោយមិនធ្វើការឈូសឆាយលប់ប្រភពទឹកផ្សេងៗ ដែលមានក្នុងតំបន់គម្រោង និងគោរពទៅតាមគោលការណ៍ណែនាំរបស់មន្ត្រីជំនាញនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងបរិស្ថាន ដើម្បីថែរក្សាស្ថានភាពបរិស្ថាន ដែលមានស្រាប់នៅក្នុងតំបន់គម្រោងអភិវឌ្ឍន៍។

-ដើម្បីបញ្ចៀសដល់ការប៉ះពាល់ដល់ប្រភពទឹកក្រោម ដីក្រុមហ៊ុនវិនិយោគត្រូវធានានូវការអនុវត្តប្រព្រឹត្តិកម្មរបស់រោងចក្រចំរាញ់រ៉ែដោយសុវត្ថិភាពនូវការទុកកាកសំណល់រ៉ែ និងសារធាតុគីមីចំរាញ់រ៉ែដោយមានការទុកដាក់ត្រឹមត្រូវតាមសៀវភៅផែនការរបស់ខ្លួន។

ក.១.៦ គុណភាពខ្យល់

-គុណភាពខ្យល់ក្នុងតំបន់គម្រោង ដែលធ្លាប់តែបរិសុទ្ធតាមរយៈនៃការបន្សុទ្ធតាមបែបលក្ខណៈធម្មជាតិដោយដើមឈើ និងរុក្ខជាតិគ្រប់ប្រភេទនោះ និងមានការប្រែប្រួលដោយសារសកម្មភាពឈូសឆាយដី ការកាប់ឈើក្នុងទីតាំងគម្រោង ដើម្បីសំអាតការដ្ឋាន (ការដុតមែកឈើ-ស្លឹកឈើ) មុននឹងកាយយកធនធានរ៉ែមានតំលៃការបំ

ភាយឧស្ម័នពុលពីគ្រឿងចក្រ និងការបង្កើតឲ្យមានការហុយធូលីដីជាច្រើននៅផ្លូវប្រាំង ដោយសារការដឹកជញ្ជូនសំភារៈចេញ-ចូលក្នុងទីតាំងគម្រោង។

-ម្យ៉ាងវិញទៀតវានឹងបាត់បង់នូវតុល្យភាពនៃការស្រូបយកឧស្ម័នកាបូនឌីអុកស៊ីត ($CO_2$) និងការបញ្ចេញឧស្ម័នអុកស៊ីសែន ($O_2$) របស់ដើមឈើក្នុងតំបន់គម្រោង ដែលនាំឲ្យឧស្ម័នកាបូនឌីអុកស៊ីត ($CO_2$) នឹងកើនឡើង ឯកម្រិតនៃការបញ្ចេញឧស្ម័នអុកស៊ីសែន ($O_2$) នឹងត្រូវថយចុះក្នុងតំបន់គម្រោង។

<u>វិធានការកាត់បន្ថយ</u>

-ការបំពុលខ្យល់ដែលបង្កឡើង ដោយសកម្មភាពឈូសឆាយដីក្នុងតំបន់គម្រោង ដើម្បីសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធនឹងត្រូវការកាត់បន្ថយតាមរយៈនៃការឈូសឆាយត្រូវធ្វើឡើង តាមដំណាក់កាលដោយឆ្លាស់គ្នាទៅតាមឆ្នាំនៃអនុតំបន់គម្រោងនីមួយៗដែលបានកំណត់ក្នុងផែនការមេរបស់ក្រុមហ៊ុន។

-មិនទុកដីអោយនៅទំនេរយូរក្រោយពេលឈូសឆាយរួចគឺក្រុមហ៊ុននឹងធ្វើការបង្ហាប់ដីភ្លាមៗដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

-ប្រើប្រាស់គ្រឿងចក្រ ដែលមានបំពាក់តំរង់ចំពោះឧស្ម័នដែលមានគុណភាពខ្ពស់ដើម្បីកាត់បន្ថយឧស្ម័នជាតិពុលទៅក្នុងបរិយាកាស។

ខ. ធនធានជីវសាស្ត្រ

ខ.១ ធនធានព្រៃឈើ

-តាមរយៈការចុះសិក្សាអង្កេតជាក់ស្តែងទៅលើធនធានព្រៃឈើ ដែលមាននៅក្នុងតំបន់គំរោងគឺមានចំនួនតិចប៉ុណ្ណោះដោយសារតែព្រៃឈើនៅតំបន់គំរោងគឺមានតែនៅលើភ្នំប៉ុណ្ណោះ ចំពោះនៅតាមជើងភ្នំវិញគឺសុទ្ធតែដីចំការ និងដីលំនៅដ្ឋានរបស់ប្រជាជនស្ទើរតែទាំងអស់ ហើយភ្នំមួយចំនួនត្រូវបានកាប់រានយកដីធ្វើចំការជាបណ្តើរៗ ដូចនេះ វត្តមានរបស់គំរោងអាចនឹងធ្វើអោយប៉ះពាល់ដល់ធនធានព្រៃឈើទាំងនោះ ក្នុងករណីដែលខ្សែរ៉ែមាននៅកន្លែងធនធានព្រៃឈើទាំងនោះ ដោយសារតែការឈូសឆាយដីព្រៃដើម្បីយករ៉ែ។

-បន្ថែមពីនេះទៀត សំរាប់កម្មករដែលបំរើការងារក្នុងតំបន់គម្រោងក៏នឹងអាចមានការធ្វេសប្រហែសនានា (ការចោលកន្ទុយបារី ការបង្កាត់ភ្លើងដាំបាយនៅផ្លូវប្រាំង) ដែលកត្តានេះបានបណ្តាលអោយមានភ្លើងឆេះព្រៃ។

-វាអាចនឹងមានបទល្មើសព្រៃឈើ កើតមានក្នុងតំបន់ខ្លះនៃគម្រោង ដោយក្រុមហ៊ុនមិនទាន់ប្រតិបត្តិទៅដល់។

<u>វិធានការកាត់បន្ថយ</u>

-ក្រុមហ៊ុនត្រូវរួសរាន់លប់ និងដាំដើមឈើ (ពូជក្នុងស្រុក)លើគំរបដីឡើងវិញភ្លាមៗបន្ទាប់ពីរោករ៉ែរួច។

-ក្រុមហ៊ុននឹងធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មករទាំងអស់របស់គម្រោងអោយមានការប្រុងប្រយ័ត្នចំពោះការបង្កាត់ភ្លើងសំរាប់គោលបំណងផ្សេងៗ និងការចោលកន្ទុយបារី ដើម្បីជៀសវាងភ្លើងឆេះព្រៃ ហើយត្រូវរាយការណ៍ដល់អាជ្ញាធរមូលដ្ឋាននៅពេលខ្លួនប្រទះឃើញភ្លើងឆេះព្រៃក្នុងតំបន់គម្រោងដើម្បីធ្វើការទប់ស្កាត់អោយបានល្អទាន់ពេលវេលា។

-ក្រុមហ៊ុននឹងធ្វើការរក្សាទុកនូវដីទ្រនាប់ដងអូរសងខាង ១០០ម៉ែត្រចំនួន ៥៥ហិកតា។

-ក្រុមហ៊ុននឹងបំពាក់ស្លាកសញ្ញាសំគាល់របស់គម្រោងនៅលើគ្រឿងចក្រ និងបុគ្គលិក-កម្មករព្រមទាំងអប់រំណែនាំដល់ បុគ្គលិក-កម្មករទាំងអស់របស់គម្រោងដើម្បីជៀសវាងពីជនឆ្លៀតឱកាសមួយចំនួនបន្លំខ្លួនជាបុគ្គលិករបស់គម្រោងក្នុងការកាប់រានព្រៃឈើបែបអនាធិបតេយ្យ។

ខ.២ សត្វព្រៃនិងទីជំរក

- ពពួកសត្វព្រៃ ដែលមាននៅក្នុងតំបន់តំរោងគឺមានចំនួនតិចប៉ុណ្ណោះដោយសារតែព្រៃឈើនៅតំបន់តំរោងគឺមានតែនៅលើភ្នំប៉ុណ្ណោះ ចំពោះនៅតាមជើងភ្នំគឺសុទ្ធតែដីចំការ និងដីលំនៅដ្ឋានស្ទើរតែទាំងអស់។ពពួកសត្វទាំងនោះ បានពឹងអាស្រ័យទៅលើព្រៃធម្មជាតិ ដែលមានក្នុងតំបន់នេះ ដូចនេះ ប្រភេទសត្វមួយចំនួននឹងមានការថយចុះដោយការងាប់ ឬបំលាស់ទីទៅរស់នៅកន្លែងផ្សេង ដើម្បីស្វែងរកអាហារចិញ្ចឹមជីវិត ឯប្រភេទខ្លះទៀតក៏អាចឈានដល់ការវិនាសបាត់បង់ពីតំបន់គម្រោងនេះទាំងស្រុង ដោយសារតែមានការបាត់បង់នូវទីជំរក ប្រភពចំណីអាហារ កន្លែងបន្តពូជ ឬមិនអាចបន្សាំជីវិតខ្លួនវាបានទៅនឹងលក្ខខណ្ឌនៃស្ថានភាពបរិស្ថានថ្មី។

-មិនតែប៉ុណ្ណោះ សំលេងពីសកម្មភាពផ្សេងៗរបស់កម្មករការប្រើប្រាស់គ្រឿងចក្រសំរាប់ការឈូសឆាយដីនិងការបញ្ឆេះម៉ាស៊ីនភ្លើងក្នុងតំបន់គម្រោង នៅពេលកំពុងធ្វើការក៏បានធ្វើអោយមានការរំខានដល់សត្វព្រៃ ដែលមានវត្តមាននៅក្នុងតំបន់នោះ។

-ទន្ទឹមនឹងនេះអាចនឹងមានការបរបាញ់សត្វព្រៃពីសំណាក់កម្មករគម្រោង និងអាចមានការកើតឡើងនូវបទល្មើសសត្វព្រៃពីសំណាក់ជនឱកាសនិយមមួយចំនួនផងដែរ។

<u>វិធានការកាត់បន្ថយ</u>

-ប្រតិបត្តិទៅតាមផែនការមេរបស់ក្រុមហ៊ុន ដោយបែងចែកជាប្លុកៗចអនុវត្តតាមបណ្តាឆ្នាំដែលបានបញ្ជាក់ក្នុងជំពូកទី៣។ ការអនុវត្តន៍បែបនេះធ្វើអោយសត្វព្រៃក្នុងតំបន់ អាចបំលាស់ទីក្នុងការស្វែងរកចំណីអាហារក៏ដូចជាការបង្កនូវស្ថានភាពអំណោយផលដល់សត្វព្រៃក្នុងការរស់នៅបែបលក្ខណៈធម្មជាតិ។

-កំណត់ពេលវេលាធ្វើការច្បាស់លាស់ ដូចជាធ្វើការតែនៅពេលថ្ងៃ (ម៉ោងចាប់ផ្តើម៧.៣០ ទៅ ១១.៣០នាទី និងល្ងាចម៉ោង១.៣០ ទៅ ៥.៣០នាទី)។

-សាងសង់បន្ទប់សំរាប់ដាក់ម៉ាស៊ីនភ្លើង ដែលប្រើក្នុងគម្រោងហើយម៉ាស៊ីនភ្លើងត្រូវបានបំពាក់នូវឧបករណ៍កាត់បន្ថយសំលេងដើម្បីកាត់បន្ថយនូវការបញ្ចេញសំលេងខ្លាំងនៅពេលយប់។

-ក្រុមហ៊ុននឹងបំពាក់ស្លាកសញ្ញាសំគាល់របស់គម្រោងនៅលើគ្រឿងចក្រ និងបុគ្គលិក-កម្មករព្រមទាំងអប់រំណែនាំដល់បុគ្គលិក-កម្មករទាំងអស់របស់គម្រោង ដើម្បីជៀសវាងពីជនឆ្លៀតឱកាសមួយចំនួនបន្លំខ្លួនជាបុគ្គលិករបស់គម្រោងក្នុងការកាប់រានព្រៃឈើបែបអនាធិបតេយ្យ។

-ធ្វើការអប់រំដល់កម្មកររបស់គម្រោងមិនអោយធ្វើការបរបាញ់សត្វគ្រប់ប្រភេទនៅតំបន់នេះហើយ ធ្វើអោយការគ្រប់គ្រងចំពោះបទល្មើសសត្វព្រៃនានា ដែលកើតឡើងនៅក្នុងតំបន់នេះអោយបានម៉ត់ចត់ ដោយសហការជាមួយនឹងមន្ត្រីសង្កាត់រដ្ឋបាលព្រៃឈើ និងមន្ត្រីជំនាញនៃមន្ទីរបរិស្ថានខេត្តជាប្រចាំ។

ខ.៣ ជីវៈចំរុះក្នុងទឹក

-ការតាំងទីលំនៅនៅជិត ឬក្បែរប្រភពទឹកអូរ និង សកម្មភាពធ្វើអាជីវកម្មរ៉ែរោណាធិបតេយ្យ និងឈូសឆាយដីអាចបង្កជីវៈចម្រុះក្នុងទឹក ជាពិសេសធនធានត្រី ដែលមិនអាចបន្សាំជីវិតបាននឹងការប្រែប្រួលនូវ លក្ខខណ្ឌថ្មីខុសពីបែបលក្ខណៈធម្មជាតិ ដែល បណ្តាលមកពីការកើនឡើងនូវភាពកករល្អក់ និងការនាំមកនូវល្បាប់ម៉ដ្ឋភាពល្វើយនៃកំទេចកំទីមែកឈើ និងស្លឹក ឈើ ការចោលសំណល់ និងការបង្ហូរសំណល់រាវគ្រប់ប្រភេទទៅក្នុងប្រភពទឹកអូរ ការបំរែបំរួលចរន្តទឹកហូរការថយ ចុះនូវកំរិតអុកស៊ីសែន ($O_2$) នៅក្នុងទឹក...។ល។ វាអាចបង្កឲ្យមានការប៉ះពាល់ដល់មជ្ឈដ្ឋានរស់នៅរបស់បណ្តាភាវរស់នៅក្នុងទឹកផងដែរ។

<u>វិធានការកាត់បន្ថយ</u>

-កំណត់យកការតាំងទីលំនៅរបស់បុគ្គលិក-កម្មករស្ថិតនៅឆ្ងាយពីប្រភពទឹក (លើសពី១០០ម) ឯការឈូសឆាយដីនឹងធ្វើឡើងតែនៅរដូវប្រាំងប៉ុណ្ណោះ ដើម្បីកាត់បន្ថយការហូរនាំនូវកំទេចកំទីមែកឈើ-ស្លឹកឈើ កំទេចកំទីផ្សេងៗទៀត និងល្បាប់ម៉ដ្ឋទៅក្នុងប្រភពទឹកអូរ។

-ចូលរួមថែទាំនូវគុណភាពទឹកអូរការពារការហូរច្រោះដី មកពីការជីករ៉ែជាពិសេសគ្រប់គ្រងសំណល់រឹង-រាវ ដោយណែនាំដល់បុគ្គលិកកម្មករមិនឲ្យបោះចោល ឬបង្ហូរដោយផ្ទាល់ចូលទៅក្នុងទឹកអូរជាដាច់ខាត ។

-ទុកដាក់និងលាងសំអាតគ្រឿងចក្រនៅឆ្ងាយពីប្រភពទឹក ។

គ. បរិស្ថានសង្គម

គ.១ ការរស់នៅរបស់ប្រជាជន

សកម្មភាពគ្រឿងចក្រឈូសឆាយដី ការប្រើប្រាស់ម៉ាស៊ីនភ្លើង ការដឹកជញ្ជូនសំភារៈចេញ-ចូល នៅក្នុងតំបន់គម្រោងបានបង្កើតជាសំលេង និងរំញ័រ ដែលកត្តានេះបានធ្វើអោយរំខានដល់ការរស់នៅរបស់ប្រជាជននៅក្នុង និងក្បែរទីតាំងគម្រោង។

<u>វិធានការកាត់បន្ថយ</u>

-ប្រើប្រាស់នូវគ្រឿងចក្រ ដែលមានបំពាក់ឧបករណ៍កាត់បន្ថយសម្លេង រួមជាមួយនឹងផែនការប្រើប្រាស់គ្រឿងចក្រប្រកបដោយប្រសិទ្ធភាព ដោយជៀសវាងការបញ្ឆេះម៉ាស៊ីននៅពេលដែលមិនចាំបាច់។

-កំណត់ពេលវេលាធ្វើការតែនៅពេលថ្ងៃប៉ុណ្ណោះ ដោយមិនធ្វើការរំខានដល់ការរស់នៅរបស់ប្រជាជនដែលរស់នៅក្នុង និងក្បែរគម្រោង។

-កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសំភារៈចេញ-ចូលក្នុងគម្រោង។

-សាងសង់បន្ទប់សំរាប់ដាក់ម៉ាស៊ីនភ្លើង ដែលប្រើក្នុងគម្រោង ហើយម៉ាស៊ីនភ្លើងត្រូវបានបំពាក់នូវឧបករណ៍កាត់បន្ថយសំលេង ដើម្បីកាត់បន្ថយនូវការបញ្ចេញសំលេងខ្លាំងនៅពេលយប់។

គ.២ សុខភាព/សុវត្ថិភាពរបស់បុគ្គលិក-កម្មករ

សកម្មភាពនៃគម្រោងវិនិយោគនេះ ត្រូវការកំលាំងពលកម្មក្នុងស្រុកជាច្រើននាក់ សំរាប់បំរើការងារនៅក្នុងទីតាំងគម្រោង ដូចជាកម្មករបំរើការងារនៅទីកន្លែងជីកយករ៉ែ និងកន្លែងឈូសឆាយដីដើម្បីរៀបចំទីតាំងការដ្ឋាន

និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀត។ ដោយឡែក ទីតាំងគម្រោងស្ថិតនៅតំបន់ព្រៃភ្នំ ដូចនេះកម្មករអាចនឹងងាយកើតនូវជំងឺផ្សេងៗ ដូចជាជំងឺគ្រុនចាញ់ ជំងឺរាគរូស និងជំងឺសើរស្បែកជាដើម។ជាមួយគ្នានេះដែរ វាក៏អាចនឹងមានគ្រោះថ្នាក់ជាយថាហេតុ ដែលបណ្ដាលមកពីគ្រាប់មីនមិនទាន់ផ្ទុះដែលមាននៅក្នុងដីព្រៃ ឬដីចំការដែលសល់តាំងពីសម័យសង្គ្រាមមក និងការប្រើប្រាស់ឧបករណ៍ និង គ្រឿងចក្រដែលប្រើសំរាប់ដំណើរ ការឈូសឆាយដីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការរអិលធ្លាក់ចូល ឬបាក់រណ្ដៅរ៉ែ។

<u>វិធានការកាត់បន្ថយ</u>

-មានការផ្ដល់ទឹកស្អាត និងកន្លែងស្នាក់នៅសមរម្យ និងសាងសង់បង្គន់អនាម័យត្រឹមត្រូវដល់បុគ្គលិក-កម្មករដែលស្នាក់នៅ និងបំរើការងារក្នុងគម្រោង។

-បង្កើតឲ្យមានបន្ទប់ពិនិត្យព្យាបាលជំងឺ ហើយនឹងផ្ដល់ថ្នាំពេទ្យសម្រាប់ព្យាបាលគ្រប់គ្រាន់ និងអប់រំ-ណែនាំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងពីបញ្ហាជំងឺឆ្លងជាប្រចាំ និងវិធីសាស្ត្រថែទាំសុខភាពរបស់ខ្លួនអោយបានល្អ។

-ក្រុមហ៊ុនត្រូវធ្វើការដោះសំអាតមីនជាមុនសិន មុននឹងចាប់ផ្ដើមដំណើរការឈូសឆាយដីសាងសង់ការដ្ឋានធ្វើផ្លូវ និងហេដ្ឋារចនាសម្ព័នផ្សេងៗទៀត។

-បណ្ដុះបណ្ដាលដល់កម្មករនូវវិធីប្រើប្រាស់ឧបករណ៍/គ្រឿងចក្រ ព្រមទាំងបំពាក់នូវឧបករណ៍សុវត្ថិភាពដល់កម្មករផងដែរ។

គ.៣ ផ្លូវគមនាគមន៍

សកម្មភាពនៃការដឹកជញ្ជូនសម្ភារៈចេញ-ចូលរបស់ក្រុមហ៊ុននៅក្នុងតំបន់នោះ អាចធ្វើឲ្យមានការខូចខាតដល់ផ្លូវលំ និងស្ពានសាធារណៈដែលប្រជាជនធ្លាប់តែប្រើប្រាស់ផ្លូវក្នុងតំបន់នោះកន្លងមក។

<u>វិធានការកាត់បន្ថយ</u>

-ខិតខំស្ដាបនាផ្លូវ ស្ពានអោយបានរួសរាល់ទាន់ហេតុ ហើយដាក់អោយប្រើប្រាស់ជាសាធារណៈ។

-កំណត់ទំងន់ផ្ទុក និងល្បឿននៅពេលដឹកជញ្ជូនឆ្លងកាត់លើផ្លូវគម្រោង។

-ធ្វើការថែទាំ និងជួសជុលផ្លូវដែលមាននៅតំបន់គម្រោង ដើម្បីធានាអោយបានការប្រើប្រាស់យូរអង្វែង។

## ៦.២.៣ ដំណាក់កាលធ្វើអាជីវកម្ម

នៅក្នុងដំណាក់កាលនេះ សកម្មភាពរបស់គម្រោងវិនិយោគមានលក្ខណៈយូរអង្វែង ដែលបានកំណត់សាមសិប (៣០) ឆ្នាំសំរាប់រយៈពេលនៃប្រតិបត្តិការឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ដែលរាជរដ្ឋាភិបាលបានផ្ដល់ដីសំរាប់ធ្វើការវិនិយោគលើអាជីវកម្មរ៉ែលោហៈ (រ៉ែមាស)។ ដូចនេះ ក្រុមហ៊ុនធ្វើការឈូសឆាយដីសំរាប់ធ្វើអាជីវកម្មទៅតាមអនុតំបន់ ដែលមានចែងនៅក្នុងផែនការមេ (អាជ្ញាប័ណ្ណឧស្សាហកម្មធនធានរ៉ែ) ដែលមានសុពលភាពសំរាប់រយៈពេលប្រាំ (០៥) ឆ្នាំដំបូងរបស់ក្រុមហ៊ុន។

ក. បរិស្ថានធម្មជាតិ

ក.១ ធនធានរូបសាស្ត្រ

ក.១.១ សណ្ឋានដី

នៅដំណាក់កាលប្រតិបត្តិគម្រោង គម្រោងនឹងប្រើប្រាស់គ្រឿងចក្រកាយយកដីស្រទាប់លើ ដែលពុំមានរ៉ែចេញ (យោងតាមជំពូក៣ Placer មាសស្ថិតនៅលើផ្ទៃដីក្នុងកំរិតកំពស់ពី៥ទៅ៣០ម៉ែត្រមានរាងជាស្រទាប់ៗនិងមានកម្រាស់ពី ១,៧០-១៨,៨៥ ម៉ែត្រ និងជាទូទៅពី ២,៥-៤,០ម៉ែត្រ។ ដូចនេះការកាយយកដីស្រទាប់លើគឺ ស្ថិតទៅតាមរយៈកំរិតកំពស់របស់ Placer មាស។) ហើយក្រុមហ៊ុននឹងយកអាចម៍ដីទាំងនោះទៅចាក់គរនៅក្រៅការដ្ឋាន ដើម្បីរក្សាទុកចាក់បំពេញការដ្ឋានឡើងវិញនៅពេលប្រតិបត្តិការជីកយករ៉ែត្រូវបានបញ្ចប់ ។ សរុបការការធ្វើអាជីវកម្មរ៉ែមាសត្រង់ដំណាក់កាលនេះគឺ ការធ្វើតាមបែបបើកចំហរះ ការបកស្រទាប់ដីលើចេញ គឺធ្វើឡើងជាដំណាក់ៗ ដែលសកម្មភាពឈូសឆាយគំរបដីនេះនឹងធ្វើឲ្យរណ្តៅធំៗទាំងនោះក្លាយទៅជាស្រះតូចៗ ដែលបញ្ហានេះបានបណ្តាលឲ្យមានការប្រែប្រួលស្ថានភាពកំរិតទីជំរាលដែលមាននៅក្នុងតំបន់។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុននឹងរៀបចំផែនការសកម្មភាពក្នុងការឈូសឆាយដីអោយទៅតាមផែនការកំនត់ ដោយជៀសវាងនូវការធ្វើអោយប្រែប្រួលដល់សណ្ឋានដីខ្លាំង ហើយម្យ៉ាងទៀតចំពោះការឈូសឆាយដី ដើម្បីបើកស្រទាប់ដីក្នុងការធ្វើអាជីវកម្មរ៉ែមាស សំរាប់ចរាចរណ៍នៅក្នុងតំបន់គម្រោង ក្រុមហ៊ុនបានធ្វើការជ្រើសរើសយកទីតាំងដែលសមស្របបំផុត ដើម្បីធានាអោយបាននូវការកាយស្រទាប់ដីអោយបានត្រឹមកំរិតអប្បបរិមា។

-សំរាប់អាចម៍ដីដែលបានជីករួច ក្រុមហ៊ុននឹងគរទុកនៅក្នុងទីតាំងដ៏សមគួរក្បែរនោះ សំរាប់ទុកកាយលប់រណ្តៅទាំងនេះវិញ ដែលឲ្យមាននីវ៉ូដីដែលនៅក្បែររណ្តៅ និងដាំដើមឈើដែលសមស្រមទៅនឹងតំបន់គម្រោងឡើងវិញ មុនពេលក្រុមហ៊ុនប្តូរទៅទីតាំងការដ្ឋានផ្សេងទៀត។

ក.១.២ ការហូរច្រោះដី

សកម្មភាពទាំងឡាយរបស់គម្រោង ដូចជា ការកកាយ ការជីក ការបាញ់ទឹករំលីងរ៉ែនឹងធ្វើឲ្យមានការហូរច្រោះដីនៅទីតាំងគម្រោង ហើយម្យ៉ាងទៀត ទ្រង់ទ្រាយសណ្ឋានដីនៃតំបន់គម្រោងជាតំបន់ទីជំរាល ដូចមានបង្ហាញជូនក្នុងជំពូកទី៤។ ដូចនេះវាងាយនឹងសឹករិចរិល និងហូរច្រោះដី ដែលនាំនូវកករល្បាប់ម៉ដ្ឋហូរចូលទៅកាន់ទីតាំងទំនាបក្បែរខាង ឬហូរចូលទៅក្នុងប្រភពទឹកអូរ ដោយសារសកម្មភាពទាំងឡាយរបស់គម្រោង។

<u>វិធានការកាត់បន្ថយ</u>

-ដើម្បីធានាបានកុំឲ្យមានហេតុប៉ះពាល់បរិស្ថានអវិជ្ជមានលើការហូរច្រោះដីចូលទៅក្នុងអូរ និងខូចខាតផ្លូវក្រុមហ៊ុននឹងអនុវត្តនូវវិធានការណ៍ដូចជា ការជីកដីយករ៉ែនៅតំបន់នីមួយៗ គឺមានគំលាតឆ្ងាយពីអូរ យ៉ាងហោចណាស់ចាប់ចំងាយ ៥០ម៉ែត្រ (គិតពីកំរិតទឹកជន់អតិបរមា) និងគំលាតចេញពីផ្លូវការដ្ឋានវិញ គឺចាប់ចំងាយ ៣០ម៉ែត្រ ដើម្បីទប់ស្កាត់ការហូរច្រោះដី។ រីឯមាត់រណ្តៅត្រូវបានកាយដីស្រទាប់លើមួយចំនួន ដើម្បីទប់ជុំវិញចំពោះរណ្តៅដែលបានជីក និងមិនទាន់បានកប់រួចរាល់។

-អនុវត្តតាមផែនការមេរបស់ក្រុមហ៊ុន ដោយមានការតាមដាន និងត្រួតពិនិត្យពីមន្ត្រីជំនាញ នៃក្រសួងបរិស្ថានជាប្រចាំ។

Draft

-រុសរានល់ប និងដាំដើមឈើ លើគម្របដីឡើងវិញភ្លាមៗក្រោយពេលយករ៉ែរួច។

-ក្រុមហ៊ុននឹងប្រើគង់គ្របរណ្ដៅរ៉ែ ធ្វើការសាងសង់ផ្លូវទឹកតូចៗសំរាប់បង្វៀងផ្លូវទឹកលើគំនរអាចម៍ដី និងរណ្ដៅរ៉ែដើម្បីធ្វើការគ្រប់គ្រងទឹកភ្លៀងអោយហូរទៅកាត់ប្រភពទឹកផ្សេង ដើម្បីកាត់បន្ថយការហូរច្រោះដី ដោយសារតែល្បឿនទឹកហូរខ្លាំងនៅពេលមានភ្លៀងធ្លាក់ម្ដងៗ។

-ក្រុមហ៊ុនត្រូវកំណត់ពេលវេលា និងផែនការអោយបានច្បាស់លាស់ក្នុងការធ្វើអាជីវកម្មនៅរដូវភ្លៀង។

-ក្រុមហ៊ុនមិនត្រូវធ្វើអាជីវកម្មនៅរដូវភ្លៀងខ្លាំងទេ ដើម្បីជៀសវាងសំណល់រាវដែលមានសារធាតុកករល្អក់ល្បាប់ម៉ដ្ឋ ឬអាចម៍ដីរ៉ែហូរចេញពីការដ្ឋានចូលទៅក្នុងប្រភពទឹកអូរក្នុងតំបន់គម្រោង។

ក.១.៣ គុណភាពដី

សកម្មភាពរបស់គម្រោងនៅក្នុងដំណាក់កាលនេះ អាចនាំអោយមានការខូចគុណភាពដី ដោយសារ :

-ការប្រើប្រាស់គ្រឿងចក្រសំរាប់គោលបំណងផ្សេងរបស់គម្រោង បានចូលរួមធ្វើអោយប៉ះពាល់គុណភាពដីដោយសារការហៀរ កំពប់ ការទុកដាក់ ឬប្រាលចោលប្រេងម៉ាស៊ីនលែងប្រើទៅលើដី និងការហូរនាំនូវសារធាតុទាំងនោះដោយទឹកភ្លៀងទៅតំបន់ក្បែរៗនោះ។

-ការបង្កឡើងដោយបុគ្គលិក-កម្មកររបស់ក្រុមហ៊ុនក្នុងការទុកដាក់/ការចោលនូវសំណល់ប្រេង-ខ្លាញ់សំបកកំប៉ុងប្រេងម៉ាស៊ីន សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗទៀតក្បែរបរិវេណការដ្ឋាន ក៏នឹងធ្វើអោយមានការខូចគុណភាពដីផងដែរ ប្រសិនបើខាងក្រុមហ៊ុនមិនបានធ្វើការគ្រប់គ្រងអោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

**<u>វិធានការកាត់បន្ថយ</u>**

-ក្រុមហ៊ុននឹងត្រួតពិនិត្យគ្រឿងចក្រគ្រប់ប្រភេទអោយបានល្អជាប្រចាំ ដើម្បីកាត់បន្ថយនូវការលេចជ្រាបប្រេងម៉ាស៊ីននៅពេលចេញ-ក្រោយពេលប្រតិបត្តិការ។

-ទុកដាក់នូវប្រេងឥន្ធនៈសំរាប់ការងារនៅក្នុងការដ្ឋាននិងសំណល់ប្រេងម៉ាស៊ីនឲ្យបានត្រឹមត្រូវ ដោយធ្វើការសាងសង់នូវឃ្លាំងទុកដាក់ប្រេងទាំងនោះអោយបានសមស្របបំផុត ដើម្បីជៀសវាងនូវឧប្បត្តិហេតុនានា ដែលនឹងកើតមានឡើង ហើយសំណល់ប្រេងម៉ាស៊ីននឹងសន្សំទុកលក់ទៅឲ្យឈ្មួញដែលទិញយកទៅកែច្នៃឡើងវិញ។

-មានផែនការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទអោយបានល្អប្រសើរ គឺជីករណ្ដៅដែលមានលក្ខណៈបច្ចេកទេសសំរាប់ទុកដាក់សំណល់រឹងដោយលប់ដីជាប្រចាំ និងសាងសង់បង្គន់អនាម័យដែលមានអាងស្តុកសំណល់រាវឲ្យបានត្រឹមត្រូវជៀសវាងការបង្ហូរសំណល់រាវ ឬចោលសំណល់រឹង/សំរាមទៅតាមទីសាធារណៈ។

-ធ្វើការណែនាំ និងអប់រំដល់បុគ្គលិក-កម្មករ ដោយហាមប្រាមមិនអោយមានការបោះចោលសំរាមពាសវាលពាសកាល ឬបង្ហូរសំណល់រាវទៅទីសាធារណៈឡើយ។

ក.១.៤ គុណភាព និងជលសាស្ត្រទឹកលើដី

-ការចោលសំណល់រឹងដែលមានប្រភពចេញពីសំណល់សំភារៈសាងសង់ សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗមកពីការប្រើប្រាស់របស់បុគ្គលិក-កម្មករគម្រោង និងការបង្ហូរសំណល់រាវពីកន្លែងស្នាក់នៅ ឬពីការហៀរកំពប់សារធាតុប្រេងពី គ្រឿងចក្រ និងរថយន្ត ដែលធ្វើអោយប្រែប្រួល ឬខូចគុណភាពទឹក។

-មានការប៉ះពាល់ដល់គុណភាពទឹកអូរ និងការកើនឡើងនូវកករល្បាប់ម៉ដ្ឋ/ភក់ ដោយសារសកម្មភាពឈូសឆាយ ដែលមិនមានផែនការច្បាស់លាស់ក្នុងការកាត់បន្ថយការហូរច្រោះដី សំណឹកដី។

-លើសពីនេះទៅទៀតកង្វល់ដែលជាបញ្ហានោះគឺ សំណល់ថ្មពីការជីកយករ៉ែ ថ្មមិនមានផ្ទុកសារធាតុរ៉ែដែលជីកយកចេញពីអណ្តូងរ៉ែ មានលាយឡំទៅដោយខនិជស៊ុលភីត ដែលអាចបង្កបានជាសំណល់មានជាតិអាស៊ីដ។

<u>វិធានការកាត់បន្ថយ</u>

-ចាត់វិធានការណ៍យ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសំណល់រឹង និងសំណល់រាវ ដោយរៀបចំប្រមូលសំណល់រឹង(សំរាម)យកទៅចោលនៅក្នុងរណ្តៅដែលមានសុវត្ថិភាពដល់បរិស្ថាននិងសង្គមព្រមទាំងសាងសង់បង្គន់អនាម័យឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងហានការអប់រំដល់បុគ្គលិក-កម្មករឲ្យយកចិត្តទុកដាក់ខ្ពស់លើបញ្ហាសំណល់រឹង-រាវនេះ។

-សាងសង់កន្លែងស្តុកប្រេងឥន្ធនៈអោយបានត្រឹមត្រូវ ដោយមិនអោយកំពប់លើដីដែលនាំអោយហូរចូលក្នុងប្រភពទឹកអូរ ហើយក្រុមហ៊ុននឹងប្រើប្រាស់ថែទាំគ្រឿងចក្រ និងរថយន្តដឹកជញ្ជូនអោយមានគុណភាព និងត្រូវបានត្រួតពិនិត្យ ជាប្រចាំយ៉ាងហ្មត់ចត់មុននឹងប្រតិបត្តិ ដើម្បីធានាមិនអោយមានការលេច/ជ្រាបប្រេង។

-ធ្វើការឈូសឆាយដីនៅរដូវប្រាំង។ ក្នុងករណីមានការឈូសឆាយដីរដូវវស្សា ក្រុមហ៊ុននឹងប្រតិបត្តិក្នុងទ្រង់ទ្រាយតូចៗ ហើយនៅក្នុងស្ថានភាពលើសណ្ឋានដីរាបស្មើ ហើយក្រុមហ៊ុននឹងធ្វើរបាំងការពារកករដី ឬកំទេចកំទីកុំអោយហូរចូលទៅក្នុងប្រភពទឹក។

- សំណល់ថ្មមិនមានផ្ទុកសារធាតុរ៉ែដែលជីកយកចេញពីអណ្តូងរ៉ែ ត្រូវស្តុកទុកយ៉ាងមាំមួនដើម្បីធានាមិនឲមានការខូចខាតឬបំពុលដល់បរិស្ថានជុំវិញ។ ដើម្បីចៀសវាងនូវការបំពុល ដែលអាចកើតមានដល់បរិស្ថានជុំវិញទីតាំងរក្សាសំណល់ថ្ម និងត្រូវហ៊ុំព័ទ្ធទៅដោយទំនប់ដែលជញ្ជាំងទំនប់មានកម្រាស់ និងកំពស់ខ្ពស់ល្មមធានាដល់ការមិនបាក់រលំសំណល់ថ្ម ឬការមិនហៀរហូរទឹកកង្វក់មកក្រៅនៅពេលមានភ្លៀងធ្លាក់ខ្លាំង។ នៅផ្នែកកណ្តាលនៃទីតាំងនេះ ត្រូវបង្កប់បំពង់បញ្ឈរមួយ ដែលអាចឲ្យគេត្រួតពិនិត្យបានពីគុណភាពទឹក នៅផ្នែកបាតនៃទីតាំងស្តុកទុកសំណល់ថ្មនេះផងដែរ។ វិធានការបន្សាបមួយចំនួននឹងត្រូវប្រើប្រាស់នៅពេលពិនិត្យឃើញថាគុណភាពទឹកនៃបាតទំនប់នេះ អាចបង្កនូវការបំពុលបាន។ ជញ្ជាំងទំនប់នឹងមានដាំដើមឈើដើម្បីធានាទប់មិនឲ្យមានការរលំជញ្ជាំងទំនប់ និងកាត់បន្ថយការជ្រាបចេញនូវទឹកកខ្វក់។ ការជីកចង្អូរនៅផ្នែកខាងលើ ដើម្បីបញ្ចៀសការហូរទឹកចូលទៅក្នុងទីតាំងស្តុកទុកសំណល់ថ្មក៏ នឹងជួយបង្កាមិនឲ្យអាងស្តុកសំណល់ថ្មនេះបាក់រលំផងដែរ។ ទីតាំងស្តុកសំណល់ថ្មត្រូវឋិតនៅមិនឆ្ងាយពីការដ្ឋានជីកយករ៉ែដើម្បីសម្រួលដល់ការចាក់បំពេញសំណល់ថ្មទាំងនោះទៅក្នុងរណ្តៅរ៉ែវិញនៅចុងបញ្ចប់នៃការជីកយករ៉ែ។

-អនុវត្តតាមផែនការមេរបស់ក្រុមហ៊ុន ដោយមានការតាមដាន និងត្រួតពិនិត្យពីមន្ត្រីជំនាញ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងបរិស្ថានជាប្រចាំ។

-ធ្វើការគ្រប់គ្រង សំអាតមែកឈើ ឬសឈើ និងស្លឹកឈើឲ្យបានល្អ ជាពិសេសគ្រប់គ្រងនូវល្បាប់ម៉ដ្ឋ/ភក់កុំឲ្យហូរចូលក្នុងប្រភពទឹកអូរសំខាន់ៗដែលមានក្នុងតំបន់គម្រោង
និងទប់ស្កាត់ការកើនឡើងកំរិតកករល្អក់ក្នុងប្រភពទឹក។

-ក្រុមហ៊ុនមិនត្រូវបង្ហូរសំណល់រាវដែលមានសារធាតុកករល្អក់ ល្បាប់ម៉ដ្ឋ ឬអាចម៍ដី ចូលទៅក្នុងប្រភពទឹកស្ទឹង-អូរនានាដែលមាននៅក្នុងតំបន់គម្រោង។

-ក្រុមហ៊ុននឹងត្រូវសាងសង់ទីតាំងរក្សាសំណល់ថ្ម គឺត្រូវត្រូវហ៊ុំព័ទ្ធទៅដោយទំនប់ដែលជញ្ជាំងទំនប់មានកម្រាស់ និងកំពស់ខ្ពស់ល្មមធានាដល់ការមិនបាក់រលំសំណល់ថ្ម ឬការមិនហៀរហូរទឹកកង្វក់មកក្រៅនៅពេលមានភ្លៀងធ្លាក់ខ្លាំង។ នៅផ្នែកកណ្តាលនៃទីតាំងនេះ ត្រូវបង្កប់បំពង់បញ្ឈរមួយ ដែលអាចអោយគេត្រួតពិនិត្យបានពីគុណភាពទឹក នៅផ្នែកបាតនៃទីតាំងស្តុកទុកសំណល់ថ្មនេះផងដែរ។ វិធានការបន្សាបមួយចំនួននឹងត្រូវប្រើប្រាស់នៅពេលពិនិត្យឃើញថាគុណភាពទឹកនៃបាតទំនប់នេះ អាចបង្កនូវការបំពុលបាន។ ជញ្ជាំងទំនប់នឹងមានដាំដើមឈើដើម្បីធានាទប់មិនឲ្យមានការរលំជញ្ជាំងទំនប់ និងកាត់បន្ថយការជ្រាបចេញនូវទឹកកខ្វក់។

ក.១.៥ គុណភាព និងជលសាស្ត្រទឹកក្រោមដី

-ការស្តុកប្រេងឥន្ធនៈ ដើម្បីបំរើសេចក្តីត្រូវការសំរាប់សកម្មភាពគ្រឿងចក្ររបស់គម្រោងអាចនឹងធ្វើអោយមានការហៀរ ឬកំពប់ប្រេងទៅលើដី ដែលកត្តានេះវានឹងនាំអោយមានការបំពុលដល់ប្រភពទឹកក្រោមដី ដោយសារតែការហូរនាំសារធាតុប្រេងនៅពេលដែលមានភ្លៀងធ្លាក់។

-សំណល់រឹង ដូចជាសំបកកំប៉ុងប្រេងម៉ាស៊ីន សំណល់ផ្ទះបាយ សំណល់បង្គន់អនាម័យ និងសំណល់ចេញពីអាងចម្រាញ់រ៉ែ ដែលផ្ទុកសារធាតុពុលអាចនឹងធ្វើអោយមានការបំពុលប្រភពទឹកក្រោមដី ប្រសិនបើក្រុមហ៊ុនមិនបានធ្វើការគ្រប់គ្រងអោយបានត្រឹមត្រូវ។

-ការឈូសឆាយដី ការកាយយកស្រទាប់រ៉ែ ការកាយលប់រណ្តៅចាស់ ការកិនបង្ហាប់ដី អាចកាត់ផ្តាច់ប្រព័ន្ធទឹកក្រោមដី ដែលវាអាចជះឥទ្ធិពលទៅដល់ការថយចុះនូវធារទឹកក្រោមដី។

-បន្ថែមលើការប៉ះពាលទឹកក្រោមដីសំខាន់នោះគឺ សំណល់ពីអាងចម្រាញ់រ៉ែដែលមានផ្ទុកទៅដោយសារជាតិពុលដែលបង្កឡើងដោយ សំណល់រឹងដែលមានទំហំគ្រាប់ម៉ដ្ឋ និងជោគជាំទៅដោយជាតិស៊ីយ៉ានួរ។

<u>**វិធានការកាត់បន្ថយ**</u>

-គ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទអោយបានប្រសើរ ដោយធ្វើការជ្រើសរើសទីតាំងដែលមានអំណោយផលសំរាប់ជីករណ្តៅ (ដីដែលមានលក្ខណៈស្រទាប់ដីឥដ្ឋក្រាស់) សំរាប់ទុកដាក់សំរាប់ប្រកបទៅដោយបច្ចេកទេសដើម្បីធានាមិនអោយមានការជ្រាប ឬលេចចេញពីរណ្តៅដែលនាំអោយមានការបំពុលទៅដល់ខ្សែទឹកក្រោមដី។ ចំពោះសំណល់រាវចេញពីបង្គន់អនាម័យ ក្រុមហ៊ុននឹងធ្វើការឈូសឆាយប្រកបដោយប្រសិទ្ធភាព លប់រណ្តៅ និងដាំដើមឈើ (ពូជក្នុងស្រុក) ភ្លាមៗក្រោយពេលយកស្រទាប់រ៉ែ និងគោរពទៅតាមគោលការណ៍ណែនាំរបស់ជំនាញនៃក្រសួងពាក់ព័ន្ធ។

-ក្រុមហ៊ុននឹងត្រូវសាងសង់ទីតាំងសំណល់ពីការចម្រាញ់រ៉ែដើម្បីរក្សាទុក ដែលមានទំនប់ដីរឹងមាំព័ទ្ធជុំវិញ។ បាត និងជញ្ជាំងនៃអាងស្តុកត្រូវក្រាលទៅដោយដីឥដ្ឋសែសិប (៤០) សង់ទីម៉ែត្រ និងពាសគ្របពីលើដោយប្លាស្ទិកដើម្បីធានាថាមិនមានការជ្រាបចេញនូវសារធាតុពុលចូលទៅក្នុងស្រទាប់ទឹកក្រោមដី។
បាតនៃអាងត្រូវមានបង្កប់បណ្តាញទុយោសម្រាប់បូមទឹកដែលបន្សាបជាតិពុលរួចហើយទៅកាន់អាងតំកល់ទឹកទី១

សម្រាប់ការប្រើប្រាស់ជាថ្មី។ ទុយោបញ្ឈរនៅផ្នែកខាងក្នុងនៃអាងក៏ត្រូវបានរៀបចំសម្រាប់ត្រួតពិនិត្យគុណភាពទឹកនៅបាតអាងស្តុកសំណល់ពីការចម្រាញ់រ៉ែនេះផងដែរ។ កំហាប់ជាតិស៊ីយ៉ានួរដែលនៅក្នុងសំណល់ពីអាងត្រាំរ៉ែ ត្រូវបានបន្សាបដោយកាល់ស្យូមអ៊ីប៉ូក្លរីតដែលគេដាក់បញ្ចូលទៅក្នុងសំណល់ទាំងនោះ និងដោយកាំរស្មីស្វាយអ៊ុលត្រាពីពន្លឺព្រះអាទិត្យ។

-អនុវត្តតាមផែនការមេរបស់ក្រុមហ៊ុន ដោយមានការតាមដាន និងត្រួតពិនិត្យពីមន្ត្រីជំនាញ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងបរិស្ថានជាប្រចាំ។

ក.១.៦ គុណភាពខ្យល់

គុណភាពខ្យល់ក្នុងតំបន់គម្រោង ដែលធ្លាប់តែបរិសុទ្ធតាមរយៈនៃការបន្សុទ្ធតាមបែបលក្ខណៈធម្មជាតិដោយដើមឈើ និងរុក្ខជាតិគ្រប់ប្រភេទនោះ និង មានការប្រែប្រួលដោយសារសកម្មភាពការឈូសឆាយដី ការកាប់ឈើក្នុងទីតាំងគម្រោងដើម្បីសំអាតការដ្ឋាន (ការដុតមែកឈើ-ស្លឹកឈើ) មុននឹងកាយយកធនធានរ៉ែមានតំលៃ ការបំភាយឧស្ម័នពុលពីគ្រឿងចក្រ និងការបង្កើតឲ្យមានការហុយធូលីដីជាច្រើននៅរដូវប្រាំងដោយសារការដឹកជញ្ជូនសំភារៈចេញ-ចូលក្នុងទីតាំងគម្រោង។

<u>វិធានការកាត់បន្ថយ</u>

-ការបំពុលខ្យល់ដែលបង្កឡើងដោយសកម្មភាពឈូសឆាយដីក្នុងតំបន់គម្រោង ដើម្បីសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធនឹងត្រូវកាត់បន្ថយតាមរយៈនៃការឈូសឆាយត្រូវធ្វើឡើងតាមដំណាក់កាល ដោយឆ្លាស់គ្នាទៅតាមឆ្នាំនៃអនុតំបន់គម្រោងនីមួយៗ ដែលបានកំណត់ក្នុងផែនការមេរបស់ក្រុមហ៊ុន។

-មិនទុកដីអោយនៅទំនេរយូរក្រោយពេលឈូសឆាយ និងការកាយយកស្រទាប់រ៉ែ គឺក្រុមហ៊ុននឹងធ្វើការលប់រណ្តៅ និងដាំដើមឈើ (ពូជក្នុងស្រុក) ឡើងវិញភ្លាមៗមុននឹងកាយយកស្រទាប់រ៉ែនៅអនុតំបន់ផ្សេងទៀត។

-ប្រើប្រាស់គ្រឿងចក្រដែលមានគុណភាពខ្ពស់ និងមានបំពាក់តំរងចម្រោះឧស្ម័នត្រឹមត្រូវដើម្បីកាត់បន្ថយការបញ្ចេញនូវឧស្ម័នពុលទៅក្នុងបរិយាកាស។

ខ. ធនធានជីវសាស្ត្រ

ខ.១ ធនធានព្រៃឈើ

-តាមរយៈការចុះសិក្សាអង្កេតជាក់ស្តែងទៅលើធនធានព្រៃឈើ ដែលមាននៅក្នុងតំបន់គម្រោងគឺមានចំនួនតិច ប៉ុណ្ណោះដោយសារតែព្រៃឈើនៅតំបន់គម្រោងគឺមានតែនៅលើភ្នំប៉ុណ្ណោះ ចំពោះនៅតាមជើងភ្នំវិញគឺសុទ្ធតែដីចំការ និងដីលំនៅដ្ឋានរបស់ប្រជាជនស្ទើរតែទាំងអស់ ហើយភ្នំមួយចំនួនត្រូវបានកាប់រានយកដីធ្វើចំការជាបណ្តើរៗ។ដូចនេះវត្តមានរបស់គំរោងអាចនឹងធ្វើអោយប៉ះពាល់ដល់ធនធានព្រៃឈើទាំងនោះ ក្នុងករណីដែលខ្សែរ៉ែមាននៅកន្លែងធនធានព្រៃឈើទាំងនោះ ដោយសារតែការឈូសឆាយដីព្រៃដើម្បីយករ៉ែ។

-បន្ថែមពីនេះទៀត សំរាប់កម្មករដែលបំរើការងារក្នុងតំបន់គម្រោងក៏នឹងអាចមានការធ្វេសប្រហែសនានា(ការចោលកន្ទុយបារី ការបង្កាត់ភ្លើងដាំបាយ...) ដែលកត្តានេះបានបណ្តាលអោយមានភ្លើងឆេះព្រៃ។

-វាអាចនឹងមានបទល្មើសព្រៃឈើកើតមាននៅតំបន់ភ្នំខ្លះនៃគម្រោង ដោយក្រុមហ៊ុនមិនទាន់ប្រតិបត្តិទៅដល់។

**វិធានការកាត់បន្ថយ**

ធ្វើការអប់រំណែនាំដល់បុគលិក-កម្មករទាំងអស់របស់គម្រោង អោយមានការប្រុងប្រយ័ត្ន ចំពោះការបង្កាត់ភ្លើងសំរាប់គោលបំណងផ្សេងៗ និងការចោលកន្ទុយបារី ដើម្បីជៀសវាងភ្លើងឆេះព្រៃ ហើយត្រូវរាយការណ៍ដល់អាជ្ញាធរមូលដ្ឋាននៅពេលខ្លួនប្រទះឃើញភ្លើងឆេះព្រៃក្នុងតំបន់គម្រោងដើម្បីធ្វើការទប់ស្កាត់អោយបានទាន់ពេលវេលា។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនត្រូវបំពាក់ស្លាកសញ្ញាសំគាល់របស់គម្រោងអោយបានជាប់ជានិច្ចនៅពេលធ្វើការដើម្បីជៀសវាងពីជនឆ្លៀតឱកាសមួយចំនួន បន្លំខ្លួនជាបុគ្គលិករបស់គម្រោងក្នុងការកាប់រានព្រៃឈើបែបអនាធិបតេយ្យ។

សហការអោយបានជាប្រចាំជាមួយ រដ្ឋបាលព្រៃឈើក្នុងតំបន់ ដើម្បីទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើដែលអាចកើតមានក្នុងតំបន់គម្រោង។

-ក្រុមហ៊ុននឹងធ្វើការរក្សាទុកនូវដីទ្រនាប់ដងអូរសងខាង ១០០ម៉ែត្រចំនួន ៥៩ហិកតា។

**ខ.២ សត្វព្រៃ និងទីជំរក**

-ពពួកសត្វព្រៃ ដែលមាននៅក្នុងតំបន់គម្រោងគឺមានចំនួនតិចប៉ុណ្ណោះ ដោយសារតែព្រៃឈើនៅតំបន់គម្រោង គឺមានតែនៅលើភ្នំប៉ុណ្ណោះ ចំពោះនៅតាមជើងភ្នំគឺសុទ្ធតែដីចំការ និងដីលំនៅដ្ឋានស្ទើរតែទាំងអស់។ពពួកសត្វទាំងនោះ បានពឹងអាស្រ័យទៅលើព្រៃធម្មជាតិ ដែលមានក្នុងតំបន់នេះដូចនេះ ប្រភេទសត្វមួយចំនួននឹងមានការថយចុះដោយការងាប់ ឬបំលាស់ទីទៅរស់នៅកន្លែងផ្សេង ដើម្បីស្វែងរកចំណីអាហារចិញ្ចឹមជីវិត ឯប្រភេទខ្លះទៀតក៏អាចឈានដល់ការវិនាសបាត់បង់ពីតំបន់គម្រោងនេះ ដោយសារតែមានការបាត់បង់នូវទីជំរក ប្រភពចំណីអាហារ កន្លែងបន្តពូជ ឬមិនអាចបន្សុាំជីវិតខ្លួនវាបានទៅនឹងលក្ខខណ្ឌនៃស្ថានភាពបរិស្ថានថ្មី។

-មិនតែប៉ុណ្ណោះ សំលេង និងរំញ័រពីសកម្មភាពរបស់កម្មករការប្រើប្រាស់គ្រឿងចក្រសំរាប់ការឈូសឆាយដី និងការបញ្ឆេះម៉ាស៊ីនភ្លើងក្នុងតំបន់គម្រោង នៅពេលកំពុងធ្វើការក៏បានធ្វើអោយមានការរំខានដល់សត្វព្រៃដែលមានវត្តមាននៅក្នុងតំបន់នោះ។

**វិធានការកាត់បន្ថយ**

-ប្រតិបត្តិទៅតាមផែនការមេរបស់ក្រុមហ៊ុន ដោយបែងចែកជាប្លុករួចអនុវត្តតាមបណ្តាឆ្នាំដែលបានបញ្ជាក់ក្នុងជំពូកទី៣។ ការអនុវត្តន៍បែបនេះធ្វើអោយសត្វព្រៃក្នុងតំបន់អាចបំលាស់ទីក្នុងការស្វែងរកចំណីអាហារក៏ដូចជា ការបង្កនូវស្ថានភាពអំណោយផលដល់សត្វព្រៃក្នុងការរស់នៅបែបលក្ខណៈធម្មជាតិ។

-កំណត់ពេលវេលាធ្វើការច្បាស់លាស់ដូចជាធ្វើការតែនៅពេលថ្ងៃ (ម៉ោងចាប់ផ្តើម ៧.៣០ ទៅ ១១.៣០នាទី និងល្ងាចម៉ោង ១.៣០ ទៅ ៥.៣០នាទី) ។

-ធ្វើការអប់រំដល់បុគ្គលិក-កម្មកររបស់គម្រោងមិនអោយធ្វើការបរបាញ់សត្វគ្រប់ប្រភេទនៅតំបន់នេះ ហើយធ្វើការគ្រប់គ្រងចំពោះបទល្មើសសត្វព្រៃនានា ដែលកើតឡើងនៅក្នុងតំបន់នេះអោយបានហ្មត់ចត់ ដោយសហការជាមួយ រដ្ឋបាលព្រៃឈើ និងមន្ត្រីជំនាញនៃមន្ទីរបរិស្ថានខេត្តជាប្រចាំ។


Draft

ខ.៣ ជីវៈចម្រុះក្នុងទឹក

ការតាំងទីលំនៅ នៅជិតឬក្បែរប្រភពទឹក (អូរ) និងសកម្មភាពឈូសឆាយដីអាចបង្កអោយជីវៈចម្រុះក្នុងទឹកជាពិសេសធនធានត្រីដែលមិនអាចបន្តរស់បាននឹង ការប្រែប្រួលនូវលក្ខខណ្ឌថ្មីខុសពីបែបលក្ខណៈធម្មជាតិ ដែលបណ្តាលមកពីការកើនឡើងនូវភាពកករល្អក់ និងការនាំមកនូវល្បាប់ម៉ដ្ឋ ភាពរលួយនៃកំទេចកំទីមែកឈើនិងស្លឹកឈើ ការចោលសំណល់រឹង និងការបង្ហូរសំណល់រាវគ្រប់ប្រភេទទៅក្នុងប្រភពទឹកអូរ ការបំរែបំរួលចរន្តទឹកហូរ ការថយចុះនូវកំរិតអុកស៊ីសែននៅក្នុងទឹក...។ល។ វាអាចបង្កឲ្យមានការប៉ះពាល់ដល់មជ្ឈដ្ឋានរស់នៅរបស់បណ្តាភាវរស់នៅក្នុងទឹកផងដែរ។ ម្យ៉ាងវិញទៀត ការកើនឡើងនូវចំនួនកម្មករដែលបំរើការងារនៅក្នុងគម្រោង ក៏វាកើនឡើងនូវតម្រូវការអាហារកាន់តែច្រើនដែលឈានដល់ការចាប់ត្រី និងសត្វនានា នៅក្នុងប្រភពទឹកនៅទីនោះផងដែរ។

<u>វិធានការកាត់បន្ថយ</u>

-កំណត់យកការតាំងទីលំនៅរបស់បុគ្គលិក-កម្មករស្ថិតនៅឆ្ងាយពីប្រភពទឹក(លើសពី១០០ម) ឯការឈូសឆាយដី នឹងធ្វើឡើងតែនៅផ្លូវប្រាំងប៉ុណ្ណោះ ដើម្បីកាត់បន្ថយការហូរនាំនូវកំទេចកំទីមែកឈើ-ស្លឹកឈើ កំទេចកំទីផ្សេងៗទៀត និងល្បាប់ម៉ដ្ឋទៅក្នុងប្រភពទឹកអូរ។

-ចូលរួមថែទាំនូវគុណភាពទឹកស្ទឹង ការពារការហូរច្រោះដីមកពីការជីករ៉ែ ជាពិសេសគ្រប់គ្រងសំណល់រឹង-រាវ ដោយណែនាំដល់ បុគ្គលិក-កម្មករមិនឲ្យបោះចោល ឬបង្ហូរដោយផ្ទាល់ចូលទៅអូរជាដាច់ខាត។

-ទុកដាក់ និងលាងសំអាតគ្រឿងចក្រនៅឆ្ងាយពីប្រភពទឹក។

ខ.៤ ធនធានរ៉ែផ្សេងៗទៀត

ដោយសារតែដំណាក់កាលនេះជាដំណាក់កាលធ្វើអាជីវកម្មដូចនេះនឹងមានការបាត់បង់នូវធនធានរ៉ែផ្សេងៗទៀតក្នុងបរិមាណច្រើនដែលនៅក្បែរ នៅលើ ឬនៅក្រោមស្រទាប់រ៉ែមាស នៅពេលដែលខាងគម្រោងបានចាប់ផ្តើមធ្វើអាជីវកម្ម។

<u>វិធានការកាត់បន្ថយ</u>

ចំពោះធនធានរ៉ែផ្សេងៗទៀត ដែលខាងក្រុមហ៊ុនបានប្រទះឃើញ ក្រុមហ៊ុននឹងធ្វើការថែរក្សាទុក ហើយធ្វើរបាយការណ៍ទៅអោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីធ្វើការចាត់ចែងតាមលក្ខណៈជាក់ស្តែង។

គ. បរិស្ថានសង្គម

គ.១ សិទ្ធិនៃការប្រើប្រាស់ទឹករបស់សហគមន៍

នៅដំណាក់កាលនេះ គម្រោងវិនិយោគបានធ្វើអោយមានការប៉ះពាល់ដល់ការប្រើប្រាស់ប្រភពទឹកអូរ ទឹកអណ្តូង របស់ប្រជាជន (ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ សម្រាប់ឲ្យសត្វផឹក និងសម្រាប់ការងារកសិកម្ម) នៅក្នុង និងជុំវិញតំបន់គម្រោង ដោយសារតែការទប់ទឹកប្រើតែនៅក្នុងតំបន់គម្រោង ការឈូសឆាយលប់ប្រភពទឹក និងការបំពុលប្រភពទឹក។ល។

**វិធានការកាត់បន្ថយ**

-មិនធ្វើវិធានការរាំងខ្ទប់ ឬឈូសឆាយលប់ប្រភពទឹកដែលធ្វើអោយប៉ះពាល់ដល់បរិមាណធារទឹកតាមប្រភពទឹកហើយគម្រោងនឹងចូលរួមថែរក្សាគុណភាពប្រភពទឹកអូរ ដោយមិនបង្ហូរសំណល់រាវពីការលាងរ៉ែរ៉ៃដោយផ្ទាល់ចូលទៅក្នុងទឹកអូរ និងតាមរយៈការគ្រប់គ្រងសំណល់រឹង-រាវឲ្យ មានប្រសិទ្ធភាព ព្រមទាំងទុកដាក់ និងលាងសំអាតគ្រឿងចក្រឲ្យនៅឆ្ងាយពីប្រភពទឹកអូរ ទឹកអណ្តូង និងធ្វើការអប់រំណែនាំដល់កម្មករអោយចេះជួយ ថែរក្សាគុណភាពប្រភពទឹកអូរ ទឹកអណ្តូង ដោយមិនអោយបោះចោល នូវសំរាមពាសវាលពាសកាលឡើយ ។

-រក្សាទុកផ្ទៃដីព្រៃទ្រនាប់ដងអូរមួយចំនួន ដែលប្រការនេះបានចូលរួមជួយថែរក្សាគុណភាពទឹកក៏ដូចជាបរិមាណទឹក តាមរយៈការថែរក្សាព្រៃឈើដែលជាប្រភពទាក់ទាញទឹកភ្លៀង និងការរក្សាទុកទីជំរាល ដើម្បីជួយដល់ការទប់ស្កាត់ការហូរច្រោះដី និងកំទេចកំទីនានាចូលក្នុងប្រភពទឹកអូរ ដែលនាំអោយបាត់បង់គុណភាពទឹក ។

គ.២ ប្រពៃណី-វប្បធម៌របស់សហគមន៍មូលដ្ឋាន

គម្រោងនេះអាចអោយប៉ះពាល់ដល់ប្រពៃណី-វប្បធម៌ និងជំនឿរបស់បុគ្គលិក-កម្មករ គម្រោងដែលធ្វើការចំរុះគ្នា ដែលមកពីកន្លែង និងតំបន់ផ្សេងៗគ្នា ហើយមាននិន្នាការគោរពជំនឿសាសនា និងការរស់នៅផ្សេងៗគ្នាដែរ។

**វិធានការកាត់បន្ថយ**

-ធ្វើការសិក្សាអំពីប្រពៃណីរបស់សហគមន៍មូលដ្ឋាន ដើម្បីផ្សព្វផ្សាយដល់បុគ្គលិក-កម្មករ ឲ្យយល់ដឹងពីបញ្ហានេះ។

-ធានាការពារ និងថែរក្សាទំនៀមទំលាប់ ប្រពៃណី និងជំនឿ ដែលមានស្រាប់របស់សហគមន៍ ដោយធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មករ និងមិនធ្វើការផ្សព្វផ្សាយនូវវប្បធម៌ សាសនាផ្សេងៗ ដែលនាំអោយប៉ះពាល់ដល់សតិអារម្មណ៍របស់សហគមន៍នៅក្នុងតំបន់នេះ។

គ.៣ មុខរបរ និងប្រាក់ចំណូល

វត្តមាននៃគម្រោងសិក្សាស្រាវជ្រាវរុករក និងធ្វើអាជីវកម្មរ៉ែលោហៈនៅតំបន់ភ្នំព្រឹកអាចនឹងជះឥទ្ធិពលដល់ការរស់នៅរបស់ប្រជាជនដែលប្រកបមុខរបរ ធ្វើចំការ(ដាំពោត ដំឡូងមី និងសណ្តែក)ដែលជាមុខរបរចំបងរបស់ពួកគាត់ ដោយសារការទប់ទឹកប្រើតែនៅក្នុងតំបន់គំរោង ការលុបប្រភពទឹក និងការបំពុលប្រភពទឹកផ្សេងៗ។

**វិធានការកាត់បន្ថយ**

-អនុញ្ញាតអោយប្រជាជនប្រើប្រាស់ផ្លូវរបស់ក្រុមហ៊ុនជាប្រយោជន៍សាធារណៈ ។

-ជ្រើសរើសយកប្រជាជន ដែលរស់នៅក្នុងតំបន់គម្រោងជាអាទិភាពមកធ្វើជាបុគ្គលិក-កម្មករអោយបានច្រើនទៅតាមលក្ខខណ្ឌ និងស្ថានភាពជាក់ស្តែងរបស់ក្រុមហ៊ុន។

គ.៤ សុខភាព/សុវត្ថិភាពរបស់បុគ្គលិក- កម្មករ

-សកម្មភាពនៃគម្រោងវិនិយោគនេះ ត្រូវការកំលាំងពលកម្មក្នុងស្រុកជាច្រើននាក់ សំរាប់បម្រើការងារនៅក្នុងទីតាំងគម្រោង ដូចជាកម្មករបំរើការងារនៅកន្លែងរែងរ៉ែ កម្មករបំរើការងារនៅកន្លែងជីករ៉ែ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀត។ ដោយឡែក ទីតាំងគម្រោងស្ថិតនៅក្បែរតំបន់ព្រៃ ដូចនេះកម្មករអាចនឹងងាយកើតនូវជំងឺផ្សេងៗ ដូចជាជំងឺគ្រុនចាញ់ គ្រុនឈាម រាគរូស សើរស្បែកជាដើម។

-ជាមួយគ្នានេះដែរ វាក៏អាចនឹងមានគ្រោះថ្នាក់ជាយថាហេតុ ដែលបណ្តាលមកពីគ្រាប់មីនមិនទាន់ផ្ទុះដែលមាននៅក្នុងដីព្រៃ ឬដីចំការដែលសល់តាំងពីសម័យសង្គ្រាមមក និង ការប្រើប្រាស់ឧបករណ៍ និងគ្រឿងចក្រដែលប្រើសំរាប់ដំណើរការឈូសឆាយ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការរអិលធ្លាក់ចូល ឬបាក់រណ្តៅរ៉ែ។

<u>វិធានការកាត់បន្ថយ</u>

-មានការផ្តល់ទឹកស្អាត និងកន្លែងស្នាក់នៅសមរម្យ និងសាងសង់បង្គន់អនាម័យត្រឹមត្រូវដល់បុគ្គលិក- កម្មករដែលស្នាក់នៅ និងបំរើការងារក្នុងគម្រោង។

-បង្កើតឲ្យមានបន្ទប់ពិនិត្យព្យាបាលជំងឺ ហើយនឹងផ្តល់ថ្នាំពេទ្យសំរាប់ព្យាបាលគ្រប់គ្រាន់ និងអប់រំ-ណែនាំដល់បុគ្គលិក- កម្មករឲ្យយល់ដឹងពីបញ្ហាជំងឺឆ្លងជាប្រចាំ និងវិធីសាស្រ្តថែទាំសុខភាពរបស់ខ្លួនអោយបានល្អ។

-ក្រុមហ៊ុនត្រូវធ្វើការបោះសំអាតមីនជាមុនសិន មុននឹងចាប់ផ្តើមដំណើរការឈូសឆាយដីសាងសង់ការដ្ឋានធ្វើផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។

-បណ្តុះបណ្តាលដល់កម្មករនូវវិធីប្រើប្រាស់ឧបករណ៍/គ្រឿងចក្រ ព្រមទាំងបំពាក់នូវឧបករណ៍សុវត្ថិភាព ដល់កម្មករផងដែរ និងដាក់សញ្ញាសំគាល់ពីគ្រោះថ្នាក់ដែលអាចកើតមាននៅការដ្ឋានគម្រោង។

គ.៥ ការរំខានដោយសំលេង និងរំញ័រ

សកម្មភាពគ្រឿងចក្រក្នុងការឈូសឆាយបកស្រទាប់ដីលើ ការជីកកាយ ការដឹកជញ្ជូនដីដែលមានសារធាតុរ៉ែទៅរែងក្នុងការដ្ឋាន និងការដឹកជញ្ជូនអាចម៍ដីយកទៅស្តុកទុក នៅក្នុងតំបន់គម្រោងបានបង្កើតជាសំលេង និងរំញ័រដែលកត្តានេះបានធ្វើអោយមានការរំខានដល់សុខភាពរបស់ប្រជាជនដែលរស់នៅក្នុង និងក្បែរទីតាំងគម្រោង។

<u>វិធានការកាត់បន្ថយ</u>

-ប្រើប្រាស់នូវគ្រឿងចក្រ ដែលមានគុណភាពរួមជាមួយនឹងផែនការប្រើប្រាស់គ្រឿងចក្រប្រកបដោយប្រសិទ្ធភាព ដោយជៀសវាងការបញ្ឆេះម៉ាស៊ីននៅពេលណាដែលមិនចាំបាច់ និងមិនឲ្យលើសពី៦០ dB(A) សំរាប់តំបន់លំនៅដ្ឋាន ដែលស្ថិតក្នុងចន្លោះពីម៉ោង ០៦ព្រឹក ដល់ ម៉ោង ០៦ល្ងាច។

-កំណត់ពេលវេលាធ្វើការតែនៅពេលថ្ងៃប៉ុណ្ណោះ ដោយមិនធ្វើការរំខានដល់ការរស់នៅរបស់ប្រជាជន ដែលរស់នៅក្នុង និងក្បែរតំបន់គម្រោង។

-កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសំភារៈចេញ-ចូលក្នុងគម្រោង។

-សាងសង់បន្ទប់សំរាប់ដាក់ម៉ាស៊ីនភ្លើងដែលប្រើក្នុងគម្រោង ហើយម៉ាស៊ីនភ្លើងត្រូវបានបំពាក់នូវឧបករណ៍កាត់បន្ថយសំលេង ដើម្បីកាត់បន្ថយនូវការបញ្ចេញសំលេងខ្លាំងនៅពេលយប់។

គ.៦ ផ្លូវគមនាគមន៍

សកម្មភាពនៃការដឹកជញ្ជូនរបស់ក្រុមហ៊ុននៅក្នុងតំបន់គំរោង អាចធ្វើអោយមានការខូចខាតដល់ផ្លូវលំសាធារណៈដែលប្រជាជនធ្លាប់តែប្រើប្រាស់ផ្លូវក្នុងតំបន់នោះកន្លងមក។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុនអាចនឹងហាមឃាត់ប្រជាជន ដែលប្រើប្រាស់ផ្លូវរបស់គម្រោង និងផ្លូវផ្សេងទៀត ដែលហ៊ុំព័ទ្ធដោយតំបន់គំរោង។

<u>វិធានការកាត់បន្ថយ</u>

-ខិតខំស្ថាបនាផ្លូវ ស្ពានអោយបានរួចរាល់ឆាប់រហ័ស ហើយដាក់អោយប្រើប្រាស់ជាសាធារណៈ។

-កំណត់ទំងន់ផ្ទុក និងល្បឿននៅពេលដឹកជញ្ជូនឆ្លងកាត់លើផ្លូវគម្រោង។

-ធ្វើការថែទាំ និងជួសជុលផ្លូវដែលមាននៅតំបន់គម្រោង ដើម្បីធានាអោយបានការប្រើប្រាស់យូរអង្វែង។

-មិនហាមឃាត់នូវការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅលើផ្លូវ ស្ពានរបស់គម្រោង និង ផ្លូវដែលប្រជាជនធ្លាប់បានប្រើប្រាស់ដែលហ៊ុំព័ទ្ធដោយតំបន់គម្រោងទេ លើកលែងតែការប្រើប្រាស់ផ្លូវនោះ ក្នុងការប្រព្រឹត្តបទល្មើសនានាដូចជាការដឹកឈើ សត្វព្រៃជាដើមដែលខុសនឹងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

គ.៧ ហានីភ័យ

គម្រោងអាចនឹងកើតមាននូវការបំពុលប្រភពទឹកអូរ នៅពេលមានទឹកជំនន់ជន់លិចរណ្ដៅរ៉ែដែលបណ្ដាលអោយទឹកខ្វុលចេញពីរណ្ដៅទៅបំពុលដល់ប្រភពទឹកទាំងនោះ។

<u>វិធានការកាត់បន្ថយ</u>

-កំណត់យកទីតាំងរណ្ដៅរ៉ែនៅចម្ងាយ៥០ម៉ែត្រពីស្ទឹង ដែលគិតពីកម្រិតទឹកជំនន់ខ្ពស់បំផុតដែលធ្លាប់មានកន្លងមក។

-អនុវត្តតាមផែនការមេរបស់ក្រុមហ៊ុន ដោយកំណត់យកទំហំរណ្ដៅរ៉ែតូចៗ និងផ្លាស់គ្នាទៅតាមតំបន់នីមួយៗ

-រួសរាន់លប់ និងដាំដើមឈើ លើគម្របដីឡើងវិញភ្លាមៗក្រោយពេលយករ៉ែរួច។

-មានរៀបចំមុខទឹកបញ្ចៀសរណ្ដៅរ៉ែ

-ផ្អាកសកម្មភាពនៃការធ្វើអាជីវកម្មរ៉ែ ក្នុងករណីមានភ្លៀងធ្លាក់ខ្លាំង

-ធានាមិនបង្ហូរសំណល់រាវដែលមានសារធាតុគីមីកខ្វក់ ចូលទៅក្នុងប្រភពទឹកអូរ ដែលមាននៅក្នុងតំបន់គម្រោង។

## ៦.២.៤ ដំណាក់កាលបញ្ចប់គម្រោង

ក្រោយពីបញ្ចប់សកម្មភាពការងាររបស់ក្រុមហ៊ុន ក្រុមហ៊ុននឹងផ្ទេរដីវិនិយោគទៅឲ្យរដ្ឋវិញដែលរាជរដ្ឋាភិបាលបានផ្ដល់ជូនសំរាប់ធ្វើអាជីវកម្មរ៉ែមាស។ ជាមួយគ្នានេះដែរ នៅក្នុងដំណាក់កាលនេះ ក៏មានការជះឥទ្ធិពលតិចតួចទៅដល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមផងដែរក្នុងរយៈពេលខ្លី។

ក. បរិស្ថានធម្មជាតិ

ក.១. ធនធានរូបសាស្ត្រ

ក.១.១. សណ្ឋានដី

នៅដំណាក់កាលបញ្ចប់គម្រោង បានធ្វើអោយមានការប៉ះពាល់ដល់ដីនៅតំបន់នោះ ដោយគម្រោងបានបន្សល់ទុកនូវរណ្តៅជ្រៅៗជាច្រើន ក្រោយពីការធ្វើអាជីវកម្មរ៉ែមាសចប់រួចរាល់។

<u>វិធានការកាត់បន្ថយ</u>

គម្រោងនឹងធ្វើការលប់ និងដាំដើមឈើ (ពូជក្នុងស្រុក) ឡើងវិញជាបន្ទាន់លើរណ្តៅទាំងនោះអោយបានល្អប្រសើរឡើងវិញ ក្រោយពីសកម្មភាពទាញយកស្រទាប់រ៉ែត្រូវបានបញ្ចប់។

ក.១.២. គុណភាពដី

នៅដំណាក់កាលបញ្ចប់គម្រោងនេះនឹងធ្វើអោយដីបាត់បង់ជីជាតិ ដោយសារការជីកយករ៉ែ ការឈូសឆាយដីការបាត់បង់គំរបដីការបន្សល់ទុកនូវអាចម៍ដី ការរែងរ៉ែមាស និងការបោះចោលសំណល់រឹង-រាវគ្រប់ប្រភេទ។

<u>វិធានការកាត់បន្ថយ</u>

-យកអាចម៍ដីទៅចាក់បំពេញក្នុងរណ្តៅដែលបានយករ៉ែ ដើម្បីបង្កើតឲ្យមានគំរបដីឡើងវិញ ដោយក្រុមហ៊ុនដាំដើមឈើភ្លាមៗនៅលើទីតាំងរណ្តៅរ៉ែ ព្រមទាំងបន្តធ្វើអាជីវកម្មតាមផែនការមេដែលបានកំណត់។

-នឹងធ្វើការប្រមូល និងគ្រប់គ្រងសំណល់ទាំងនោះអោយបានសមស្របតាមលក្ខណៈបច្ចេកទេស ជៀសវាងការប៉ះពាល់ដល់បរិស្ថានក្នុងតំបន់។

-នឹងសហការជាមួយមន្ត្រីជំនាញនៃក្រសួងបរិស្ថាន ដើម្បីទុកដាក់សំណល់គ្រប់ប្រភេទឲ្យបានត្រឹមត្រូវ។

ក.១.៣. គុណភាពទឹកអូរ និងជីវៈចម្រុះក្នុងទឹក

ការគ្រប់គ្រងសំណល់រឹង/រាវ ដែលមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសវានឹងបណ្តាលអោយមានការប៉ះពាល់ដល់គុណភាពប្រភពទឹកអូរ ជាពិសេសនៅពេលមានភ្លៀងធ្លាក់បាននាំសំណល់ទាំងនោះហូរចូលទៅប្រភពទឹក

<u>វិធានការកាត់បន្ថយ</u>

-ក្រុមហ៊ុននឹងសំអាតទីតាំងគម្រោងអោយបានល្អឡើងវិញ ដូចជាធ្វើការប្រមូលសំណល់រឹង/សំរាមយកទៅដាក់ក្នុងរណ្តៅឲ្យបានសមស្រប និងប្រកបដោយលក្ខណៈបច្ចេកទេស ក្រោមការផ្តល់យោបល់ពីជំនាញក្រសួងបរិស្ថានដើម្បីធានាមិនអោយមានការបំពុលទឹកនៅក្នុងតំបន់នោះ។

-នឹងធ្វើការលប់នូវអាងស្តុកសំណល់ទាំងនេះឲ្យបានត្រឹមត្រូវ ជៀសវាងបង្ហូរសំណល់រាវចេញពីបង្គន់អនាម័យចូលទៅក្នុងប្រភពទឹក ដោយសហការជាមួយមន្ត្រីជំនាញនៃក្រសួងបរិស្ថាន ដើម្បីទុកដាក់សំណល់គ្រប់ប្រភេទឲ្យបានត្រឹមត្រូវ។

ខ. ធនធានជីវសាស្ត្រ

ខ.១ ធនធានព្រៃឈើ

ក្រោយពេល ដែលគំរោងដកចេញពីទីតាំងទៅនឹងធ្វើឲ្យមានការបាត់បង់នូវប្រភេទដើមឈើក្នុងតំបន់មួយចំនួន។

<u>វិធានការកាត់បន្ថយ</u>

គំរោងនឹងធ្វើការដាំដើមឈើ (ពូជក្នុងស្រុក) ឡើងវិញផងដែរនូវប្រភេទឈើក្នុងតំបន់ ដើម្បីជំនួសដើមឈើចាស់ប្រសិនបើខាងគំរោងបានកាប់ក្នុងប្រការណាមួយ។

គ. បរិស្ថានសង្គម

គ.១ មុខរបរ និងប្រាក់ចំណូល

នៅដំណាក់កាលបញ្ចប់គំរោងបានធ្វើឲ្យមានការប៉ះពាល់ដល់មុខរបរ និងប្រាក់ចំណូលរបស់ប្រជាជនដែលធ្លាប់តែមានមុខរបរទាក់ទងនឹងគំរោងនេះដូចជាធ្វើជាកម្មករ ជាអ្នកលក់ដូរទំនិញឲ្យក្រុមហ៊ុន។ល។

<u>វិធានការកាត់បន្ថយ</u>

-នឹងបណ្តុះបណ្តាលជំនាញបន្ថែមទៀតដល់ ហើយនឹងចេញជាលិខិតបញ្ជាក់ពីបទពិសោធន៍របស់កម្មករនៅពេលដែលកម្មករត្រូវការ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការស្វែងរកការងារធ្វើបន្តទៀត។

-នឹងផ្សព្វផ្សាយដំណឹងពីការបិទគំរោងរបស់ក្រុមហ៊ុនទៅឲ្យបុគ្គលិក-កម្មករ ដែលបំរើការងារឲ្យបានដឹងជាមុនយ៉ាងហោចណាស់ ០៣ខែ។

គ.២ ផ្លូវគមនាគមន៍

ក្នុងដំណាក់កាលបញ្ចប់គំរោងនេះនឹងធ្វើឲ្យមានការខូចខាតនូវហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់គំរោង ដោយសារតែសកម្មភាពធ្វើអាជីវកម្មក្នុងការដឹកជញ្ជូនសំភារៈ និងផលិតផលចេញ-ចូលការដ្ឋាន។

<u>វិធានការកាត់បន្ថយ</u>

-នឹងធ្វើការជួសជុលផ្លូវក្នុងតំបន់គំរោងឲ្យបានល្អប្រសើរឡើងវិញ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងករណីណាដែលមានការខូចខាតដោយសារសកម្មភាពគំរោង ដើម្បីទុកជាប្រយោជន៍សាធារណៈសំរាប់ប្រជាពលរដ្ឋប្រើប្រាស់ក្នុងតំបន់គំរោង។

តារាង ៦-១: តារាង Checklist នៃការកំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

| សមាសធាតុបរិស្ថាន និងសង្គមដែលត្រូវប៉ះពាល់ | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កម្រិតនៃហេតុប៉ះពាល់ | | | វិធានការកាត់បន្ថយ | សំគាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| ១. ដំណាក់កាលកំណត់ទីតាំង | | | | | | |
| ក. បរិស្ថានធម្មជាតិ | | | | | | |
| ក.១ ធនធានជីវសាស្ត្រ | | | | | | |
| -ធនធានព្រៃឈើនិងទីជំរក | នឹងធ្វើឲ្យបាត់បង់នូវធនធានព្រៃឈើមួយចំនួន ដោយសារតែការឈូសឆាយដីព្រៃ ដើម្បីធ្វើផ្លូវលំ ការសាងសង់អគារស្នាក់នៅរបស់កម្មករ ការសាងសង់ស្ថានីយ៍ជូសជុលបច្ចេកទេសប្រេងឥន្ធនៈ។ល។ បន្ថែមពីនេះទៀត ទីជំរករបស់សត្វព្រៃគ្រប់ប្រភេទ ដែលមានក្នុងតំបន់គម្រោង ក៏ទទួលរងការប៉ះពាល់ផងដែរ។ | ✓ | | | - ចំពោះព្រៃពាក់កណ្ដាលស្រោង គម្រោងនឹងធ្វើការសហការជាមួយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទដើម្បីធ្វើការកាត់ ចេញ និងរក្សាទុកដើម្បីជាការជួយ រក្សាលំនឹងបរិស្ថាននៅក្នុងតំបន់។<br>- ផ្ទៃដីព្រៃទ្រនាប់តាមដងអូរមួយចំនួននៅក្នុងតំបន់គម្រោង ខាងក្រុមហ៊ុននឹងធ្វើការ សហការជាមួយស្ថាប័នជំនាញ ដើម្បីធ្វើការកំណត់ពីទំហំព្រៃតាមដងអូរចំងាយ១០០ម៉ែត្រសងខាងអូរដែលត្រូវរក្សាទុកដើម្បីជាប្រយោជន៍ ជួយថែរក្សាគុណភាពទឹក កាត់បន្ថយការហូរច្រោះ ជាផ្លូវសត្វព្រៃ ឆ្លងកាត់ ជាជំរកសត្វព្រៃក៏ដូចជាការជួយថែរក្សាលំនឹងបរិស្ថានក្នុងតំបន់ផងដែរ។ | |

| | | | | | | |
|---|---|---|---|---|---|---|
| ខ. បរិស្ថានសង្គម | | | | | | |
| ខ.១ សតិអារម្មណ៍របស់ប្រជាជន | នៅដំណាក់កាលនេះ នឹងបង្កការភ្ញាក់ផ្អើលដល់ប្រជាជនដែលរស់នៅក្នុង និងក្បែរតំបន់គម្រោង ដោយពួកគាត់គិតថានឹងមានការប៉ះពាល់ដល់ដីស្រែ-ចំការ ដីលំនៅដ្ឋាន និងដីលែងសត្វដោយសារការផ្តល់ដីវិនិយោគ នេះ។ | | ✓ | | - ការពិភាក្សាក្រុមជាមួយនឹងប្រជាពលរដ្ឋមូលដ្ឋាន ដែលទទួលនិងអាចទទួលរងការប៉ះពាល់ពី ការអនុវត្តគម្រោងដើម្បីផ្តល់ជាព័តមានលំអិតស្តីពីការវិនិយោគ។ ប្រជាពលរដ្ឋ ដែលចូលរួមការពិភាក្សាអាចធ្វើការបញ្ចេញមតិយោបល់ ក៏ដូចជា បង្ហាញនូវកង្វល់របស់ខ្លួន និងលើកជាសំណូមពររបស់ខ្លួនផងដែរ។<br>- ការបង្ហាញយ៉ាងច្បាស់លាស់ពីរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គម និងសេដ្ឋកិច្ច និងរំលេចនូវរាល់វិធានការណ៍កាត់បន្ថយ និងបញ្ចៀសហេតុប៉ះពាល់ដល់ប្រជាជនមូលដ្ឋាន។ | |
| ខ.២ ការប្រើប្រាស់ដីរបស់ប្រជាជន | បានធ្វើអោយប៉ះពាល់ដល់ដីលំនៅដ្ឋាន ដីស្រែ-ចំការ និងដី លែងសត្វរបស់ប្រជាជន។ | ✓ | | | - ក្រុមហ៊ុន នឹងធ្វើការចរចាជាមួយនឹងប្រជាជន បើសិនមានការប៉ះពាល់ដល់ដីស្រែ-ចំការដីលំនៅដ្ឋាន ដែលបណ្តាលមកពីគម្រោងវិនិយោគ។<br>- អាចលែងសត្វពាហនៈ របស់ពួកគាត់បាន នៅតំបន់ភាគខ្លះ នៃគម្រោងដែលមិនទាន់អនុវត្តទៅដល់ ពីព្រោះសកម្មភាពនៃការធ្វើអាជីវកម្មរ៉ែនឹងអនុវត្តទៅតាមអនុតំបន់ដែលមានចែងនៅក្នុងផែនការមេរបស់ក្រុមហ៊ុន។ | |
| ២. ដំណាក់កាលឈូសឆាយដី និងការសាងសង់ ( ការរៀបចំការដ្ឋាន ) | | | | | | |
| ក. បរិស្ថានធម្មជាតិ | | | | | | |
| | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ក.១ ធនធានរូបសាស្ត្រ | | | | | | |
| ក.១.១ **ការប៉ះប៉ាល់សណ្ឋានដី** | - សកម្មភាពផ្សេងៗរបស់គម្រោង នឹងធ្វើអោយមានការផ្លាស់ប្តូរនូវទ្រង់ទ្រាយស្ថានភាពដើមនៃសណ្ឋានដី ដោយសារការឈូសឆាយ និងការចាក់បំពេញដីនៅទីទំនាប ដើម្បីសាងសង់ផ្លូវចូលការដ្ឋាន សាងសង់អគារ ស្នាក់នៅសំរាប់កម្មករការសាងសង់ឃ្លាំង ទីលាន ដើម្បី ជ្រើសរើស និងថែទាំផលិតផលធ្វើអាជីវកម្ម។ | ✓ | | | - ក្រុមហ៊ុននឹងធ្វើការ ឈូសឆាយដីទៅតាម លក្ខណៈសណ្ឋានដីដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធនានា ក្នុងតំបន់គម្រោងដែលដូចមានចែងក្នុងផែនការមេរបស់ក្រុមហ៊ុន ដោយមានការត្រួតពិនិត្យ និងវាយតំលៃយ៉ាងត្រឹមត្រូវ ពីមន្ត្រីជំនាញពាក់ព័ន្ធ ពិតជាអាចកាត់បន្ថយ ឬបញ្ចៀសនូវការប្រែប្រួលសណ្ឋានដីតំបន់គម្រោងអោយស្ថិតនៅកំរិតអប្បបរមា។ | |
| ក.១.២ ការហូរច្រោះដី | ទីតាំងគម្រោងទទួលរងនូវការហូរច្រោះដែលបណ្តាលមកពីកត្តាកម្មភាពធម្មជាតិ និង សកម្មភាពទាំងឡាយរបស់គម្រោង។ ម៉្យាងទៀត ទ្រង់ទ្រាយសណ្ឋានដីនៃតំបន់គម្រោងជាតំបន់ភ្នំ ដូចនេះវាងាយនឹងសឹករិចរិល និងហូរច្រោះចូលទៅកាន់ទីតាំងទំនាបក្បែរខាង ជាពិសេសនៅរដូវមានភ្លៀងធ្លាក់។ | | ✓ | | - ក្រុមហ៊ុន នឹងធ្វើការជ្រើសរើស យកទីតាំងដែលមាននីវ៉ូទាបនិងមានកំរិតប្រហាក់ប្រហែលគ្នា។<br>- ក្រុមហ៊ុន នឹងមិនមានសកម្មភាពឈូសឆាយខ្លាំងនៅរដូវវស្សា។<br>- ក្រុមហ៊ុននឹងឈូសឆាយដី ពង្របដី សំរាប់សាងសង់ដោយគោរពតាមលក្ខណៈទំរង់ប្រភេទដី និងបែបបទការ អនុវត្តន៍របស់ ក្រុមហ៊ុនដើម្បីកាត់បន្ថយការហូរច្រោះដី ដោយសារសកម្មភាព សាងសង់នានារបស់គម្រោង។<br>- ក្រុមហ៊ុននឹងធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់អោយបាន ត្រឹមត្រូវ តាមបទដ្ឋានការងារដី។ | |
| ក.១.៣ គុណភាពដី | ការហៀរ កំពប់ ការទុកដាក់ ឬបោះចោលប្រេង | | ✓ | | - មានកន្លែងដាក់ ការលាងសំអាតគ្រឿងចក្រត្រឹមត្រូវ | |

| | | | | | | |
|---|---|---|---|---|---|---|
| | ម៉ាស៊ីនលែងប្រើទៅលើដី ការទុកដាក់លាងសំអាតគ្រឿងចក្រ/ការចោលនូវ សំណល់ប្រេង-ខ្លាញ់ សំបកកំប៉ុង ប្រេងម៉ាស៊ីន សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗទៀត អាចនឹង មានការ ប៉ះពាល់គុណភាពដី ប្រសិនបើ ខាងក្រុមហ៊ុនមិនបាន ធ្វើការ គ្រប់គ្រងអោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ | | | | គ្រប់គ្រាន់និងត្រួតពិនិត្យគ្រឿងចក្រទាំងអស់ជាប្រចាំ ដើម្បីកាត់បន្ថយ នូវការលេចជ្រាប ឬលេចប្រេងម៉ាស៊ីនមុននឹងចេញប្រតិបត្តិការ។<br>- ទុកដាក់នូវប្រេងឥន្ទនៈ និងសំណល់ប្រេងម៉ាស៊ីន ឲ្យបានត្រឹមត្រូវដោយសាងសង់នូវឃ្លាំងទុកដាក់ប្រេងអោយបានសមស្រប។<br>- ជីករណ្តៅដែលមានលក្ខណៈបច្ចេកទេសសំរាប់ទុកដាក់សំណល់រឹង និងសាងសង់បង្គន់អនាម័យ និងអាងស្តុកសំណល់រាវ។<br>- ធ្វើការណែនាំ និងអប់រំដល់បុគ្គលិក-កម្មករ ដោយហាមប្រាមមិនអោយមានការបោះចោលសំរាមពាសវាលពាសកាល។ | |
| ក.១.៨ គុណភាពនិង ជលសាស្ត្រទឹកលើដី | - ការតាំងទីលំនៅរបស់គម្រោងនៅក្បែរប្រភពទឹក ការចោលសំណល់រឹង ដែលមានប្រភពចេញពីសំណល់ សំភារៈសាងសង់សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗមក ពីការប្រើប្រាស់របស់បុគ្គលិក-កម្មករគម្រោង ឬពីការហៀរ កំពប់សារធាតុប្រេងពីគ្រឿងចក្រ និងរថយន្ត នោះបណ្តាលអោយបំពុលដល់គុណភាពទឹក។<br>- ប្រព័ន្ធអូរធម្មជាតិអាចនឹងត្រូវរាំងស្ទះ ឬប្រែប្រួល | ✓ | | | - ការតាំងទីលំនៅនឹងស្ថិតនៅឆ្ងាយពីប្រភពទឹកសអូរ ៥០ម៉ែត្រគិតពីកំរិតនៃទឹកជំនន់ គ្រប់គ្រងសំណល់រឹង និងសំណល់រាវ ដោយរៀបចំប្រមូល សំណល់ រឹងយកទៅចោលនៅក្នុងរណ្តៅ ព្រមទាំងសាងសង់បង្គន់អនាម័យ។<br>- សាងសង់កន្លែងស្តុកប្រេងឥន្ទនៈអោយបានត្រឹមត្រូវ។<br>- ធ្វើការឈូសឆាយដីនៅរដូវប្រាំង។ ក្នុងករណីមានការឈូសឆាយដីរដូវវស្សា ក្រុមហ៊ុននឹងប្រតិបត្តិក្នុងទ្រង់ | |

| | | | | | | |
|---|---|---|---|---|---|---|
| | ល្បឿន ទឹកបណ្តាលមកពី ការកើនឡើងនូវកករល្បាប់ម៉ដ្ឋ/ភក់បណ្តាលមកពីសកម្មភាពឈូសឆាយដែលមិនមានផែនការច្បាស់លាស់ក្នុងការកាត់បន្ថយការហូរច្រោះ និង សំណឹកដី។ | | | | ទ្រាយតូច។<br>- អនុវត្តតាមផែនការមេរបស់ក្រុមហ៊ុន ដោយមានការតាមដាននិងត្រួតពិនិត្យពីមន្ត្រីជំនាញនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងបរិស្ថានជាប្រចាំ។ | |
| ក.១.៥ គុណភាព និង ជលសាស្ត្រទឹកក្រោមដី | ការស្តុកប្រេងឥន្ធនៈ ការហៀរ ឬកំពុបប្រេងទៅលើដីសំណល់រឹង-រាវសំណល់ផ្ទះបាយ ការឈូសឆាយដីសំរាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធ សំណល់ចេញពីអាងចម្រាញ់រ៉ែដែលផ្ទុកសារធាតុពុលអាចនឹងធ្វើអោយមានការបំពុលប្រភពទឹកក្រោមដី ប្រសិនបើក្រុមហ៊ុនមិនបានធ្វើការគ្រប់គ្រងអោយបានត្រឹមត្រូវ។ | ✓ | | | - ជីករណ្តៅសំរាប់ទុកដាក់សំណល់រឹង ចំពោះសំណល់រាវចេញពីបង្គន់អនាម័យ ត្រូវបានធ្វើការបង្ហូរចូល អាងស្តុកសំណល់រាវដែលរៀបចំតាមលក្ខណៈបច្ចេកទេស។<br>-ការឈូសឆាយដីត្រូវអនុវត្តឡើង ស្របតាមផែនការមេជាក់លាក់ដោយមិនធ្វើការឈូសឆាយលុបប្រភពទឹកផ្សេងៗដែលមានក្នុងតំបន់គម្រោង។ | |
| ក.១.៦ គុណភាពខ្យល់ | ការបំពុលខ្យល់ដោយសកម្មភាពការឈូសឆាយដីការសំអាតការដ្ឋាន (ការដុតមែកឈើ-ស្លឹកឈើ) ការបំភាយឧស្ម័នពុលពីគ្រឿងចក្រ និងការបង្កើតអោយមាន ការហុយនូវល្អងធូលីដីដោយសារការដឹកជញ្ជូនសំភារៈចេញ-ចូលការដ្ឋាន និងការបាត់បង់នូវគុណភាពវដ្តឧស្ម័នក្នុងបរិយាកាស។ | | ✓ | | - ការឈូសឆាយត្រូវធ្វើឡើងតាមដំណាក់កាល ដោយឆ្លាស់គ្នាទៅតាមឆ្នាំងនៃអនុតំបន់ ដែលបានកំណត់ក្នុងផែនការមេរបស់ក្រុមហ៊ុន។<br>- ប្រើប្រាស់គ្រឿងចក្រដែលមានបំពាក់តម្រង់ចំពោះឧស្ម័ន និងមានគុណភាពខ្ពស់ និងរៀបចំផែនការប្រើប្រាស់ម៉ាស៊ីនអោយបានសមស្រប។ | |
| ខ.១ ធនធានជីវសាស្ត្រ | | | | | | |
| ខ.១.១ ធនធានព្រៃឈើ | ធនធានព្រៃឈើ គឺមានចំនួនតិចប៉ុណ្ណោះដោយសារតែព្រៃឈើនៅតំបន់គំរោងគឺមានតែនៅលើភ្នំប៉ុណ្ណោះ ចំពោះនៅតាមជើងភ្នំវិញគឺសុទ្ធតែដីចំការ និងដី | ✓ | | | - ធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មការទាំងអស់របស់គម្រោងអោយមានការប្រុងប្រយ័ត្នដើម្បីជៀសវាងភ្លើងឆេះព្រៃ។ | |

| | | | | | | |
|---|---|---|---|---|---|---|
| | លំនៅដ្ឋានរបស់ប្រជាជនស្ទើរតែទាំងអស់ ហើយភ្នំមួយចំនួនត្រូវបានកាប់រានយកដីធ្វើចំការជាបណ្តើរៗ។ដូចនេះ វត្តមានរបស់គំរោងអាចនឹងធ្វើអោយប៉ះពាល់ដល់ធនធានព្រៃឈើទាំងនោះ ក្នុងករណីដែលខ្សែរ៉ែមាននៅកន្លែងធនធានព្រៃឈើទាំងនោះ ដោយសារតែការឈូសឆាយដីព្រៃដើម្បីយករ៉ែ។<br><br>បទល្មើសព្រៃឈើដែលអាចកើតមានក្នុងតំបន់ខ្លះនៃគម្រោង នៅដំណាក់កាលនេះ។ | | | | - ក្រុមហ៊ុននឹងបំពាក់ស្លាកសញ្ញាសំគាល់របស់គម្រោងនៅលើគ្រឿងចក្រនិងបុគ្គលិក-កម្មករ ព្រមទាំងអប់រំណែនាំ ដល់បុគ្គលិកបុគ្គលិក-កម្មករទាំងអស់របស់គម្រោងដើម្បីជៀសវាងពីជនឆ្លៀតឱកាស មួយចំនួនបន្លំខ្លួនជាបុគ្គលិករបស់គម្រោង ក្នុងការកាប់រានព្រៃឈើបែបអនាធិបតេយ្យ។<br>-ក្រុមហ៊ុនត្រូវរូសរាន់លប់ និងដាំដើមឈើ (ពូជក្នុងស្រុក)លើគំរបដីឡើងវិញភ្លាមៗបន្ទាប់ពីយករ៉ែរួច។<br>- សហការអោយបានជាប្រចាំជាមួយ រដ្ឋបាលព្រៃឈើក្នុងតំបន់ សង្កាត់រដ្ឋបាលព្រៃឈើក្នុង តំបន់ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើដែលអាចកើត មានក្នុងតំបន់គម្រោង។<br>-ក្រុមហ៊ុននឹងធ្វើការរក្សាទុកនូវដីទ្រនាប់ដងអូរសងខាង ៩០ម៉ែត្រចំនួន ៥៨ហិកតា។ | |
| ខ.១.២ សត្វព្រៃ និង ទីជំរក | ពពួកសត្វព្រៃ ដែលមាននៅក្នុងតំបន់គំរោងគឺមានចំនួនតិចប៉ុណ្ណោះដោយសារតែព្រៃឈើនៅតំបន់គំរោងគឺមានតែនៅលើភ្នំប៉ុណ្ណោះ ចំពោះនៅតាមជើងភ្នំគឺសុទ្ធតែដីចំការ និងដីលំនៅដ្ឋានស្ទើរតែទាំងអស់។ពពួកសត្វទាំងនោះ បានពឹងអាស្រ័យទៅលើព្រៃធម្មជាតិ ដែលមានក្នុងតំបន់នេះដូចនេះ ប្រភេទសត្វមួយចំនួន នឹងមានការថយចុះដោយការ | ✓ | | | - ប្រតិបត្តិទៅតាមផែនការមេរបស់ក្រុមហ៊ុន ដោយបែងចែកជាប្លុករួចអនុវត្តតាមបណ្តាឆ្នាំដែលបានបញ្ជាក់ក្នុងជំពូកទី៣។<br>- ធ្វើការអប់រំបុគ្គលិក-កម្មកររបស់គម្រោងមិនអោយធ្វើការ បរបាញ់សត្វ និង ការគ្រប់គ្រង ចំពោះបទល្មើសសត្វព្រៃ ដោយសហការជាមួយរដ្ឋបាលព្រៃឈើ និង | |

| | | | | | | |
|---|---|---|---|---|---|---|
| | ងាប់ ឬបំលាស់ទីទៅរស់នៅកន្លែងផ្សេង ដើម្បីស្វែងរកអាហារចិញ្ចឹមដោយសារតែមានការបាត់បង់នូវទីជំរក ប្រភពចំណីអាហារកន្លែងបន្តពូជ ការរំខានដោយសំលេងពីសកម្មភាពគម្រោង និងបទល្មើសសត្វព្រៃពីសំណាក់ជនឆ្លៀតឱកាសនិយម។ | | | | មន្ត្រីជំនាញនៃមន្ទីរបរិស្ថានជាប្រចាំ។ | |
| ខ.១.៣ ជីវៈចម្រុះក្នុងទឹក | ការតាំងទីលំនៅនៅជិតឬក្បែរប្រភពទឹក(អូរ) នឹងសកម្មភាពឈូសឆាយដី ការចោលសំណល់រឹង និងការបង្ហូរ សំណល់រាវការប្រែប្រួលនូវលក្ខខណ្ឌថ្មី ខុសពីបែបលក្ខណៈ ធម្មជាតិដែលបណ្តាលមកពីការកើនឡើង នូវភាពកករល្អក់ និងការនាំមកនូវ ល្បាប់ម៉ដ្ឋ ភាពល្វើយនៃកំទេចកំទីមែកឈើ និងស្លឹក ការបំរែបំរួលចរន្តទឹកហូរ ការថយចុះនូវកំរិត អុកស៊ីសែននៅក្នុងទឹក។ | ✓ | | | - កំណត់យកការតាំងទីលំនៅរបស់បុគ្គលិក-កម្មករស្ថិតនៅឆ្ងាយពីប្រភពទឹក(លើសពី១០០ម) ។ការឈូសឆាយដី នឹងធ្វើឡើងតែនៅរដូវប្រាំងប៉ុណ្ណោះ ដើម្បីកាត់បន្ថយការ ហូរនាំនូវកំទេចកំទីមែកឈើ-ស្លឹកឈើ កំទេចកំទី ផ្សេងៗទៀត និងល្បាប់ម៉ដ្ឋនៅ ក្នុងប្រភពទឹកអូរ។<br>- ចូលរួមថែទាំនូវគុណភាពទឹកអូរ ការពារការហូរច្រោះដីមកពីការជីករ៉ែ ជាពិសេសគ្រប់គ្រងសំណល់រឹង-រាវ ដោយណែនាំដល់បុគ្គលិក-កម្មករមិនឲ្យបោះចោល ឬបង្ហូរដោយ ផ្ទាល់ចូលទៅអូរជាដាច់ខាត។<br>- ទុកដាក់ និងលាងសំអាតគ្រឿងចក្រឆ្ងាយពីប្រភពទឹក។ | |
| គ.១ បរិស្ថានសង្គម | | | | | | |
| គ.១.១ ការរស់នៅរបស់ប្រជាជន | សកម្មភាពគ្រឿងចក្រ ក្នុងការឈូសឆាយដី ការប្រើប្រាស់ម៉ាស៊ីនភ្លើង ការដឹកជញ្ជូនសំភារៈចេញ-ចូលនៅក្នុងតំបន់គម្រោងបានបង្កើតជាសំលេង និងរំញ័រ | | ✓ | | - ប្រើប្រាស់គ្រឿងចក្រដែល មានបំពាក់ឧបករណ៍កាត់បន្ថយ សំលេងរួមជាមួយ នឹងមានផែនការប្រើប្រាស់ | |

| | | | | | | |
|---|---|---|---|---|---|---|
| | ដែលកត្តានេះបានធ្វើអោយមានការរំខាន ដល់ប្រជាជនដែលរស់នៅក្នុង និងក្បែរទីតាំងគម្រោង។ | | | | គ្រឿងចក្រ ឲ្យមានប្រសិទ្ធភាព។<br>- កំណត់ពេលវេលាធ្វើការតែនៅពេលថ្ងៃប៉ុណ្ណោះ ដោយមិនធ្វើការរំខានដល់ការរស់នៅរបស់ប្រជាជននៅក្នុង និងក្បែរតំបន់។<br>- កំណត់ល្បឿនបើកបរក្នុងតំបន់គម្រោង។<br>- សាងសង់បន្ទប់សំរាប់ដាក់ម៉ាស៊ីនភ្លើង ហើយម៉ាស៊ីនភ្លើងត្រូវបានបំពាក់នូវស៊ីម៉ាំងដើម្បីកាត់បន្ថយនូវ ការបញ្ចេញសំលេង។ | |
| គ.១.២ សុខភាព/សុវត្ថិភាពរបស់បុគ្គលិក-កម្មករ | - ទីតាំងគម្រោងស្ថិតនៅតំបន់ព្រៃភ្នំ ដូចនេះកម្មករអាច នឹងងាយកើតនូវជំងឺផ្សេងៗដូចជាជំងឺគ្រុនចាញ់ រាគរូស សើរស្បែកជាដើម វាក៏អាចនឹងមានគ្រោះថ្នាក់ជាយថាហេតុ ដែលប្រើប្រតិបត្តិក្នុងគម្រោង។<br>- ជាមួយគ្នានេះដែរ វាក៏អាចនឹងមានគ្រោះថ្នាក់ជាយថាហេតុដែលបណ្ដាលមកពីគ្រាប់មីនមិនទាន់ផ្ទុះ ដែលមាន នៅក្នុងដីព្រៃឬដីចំការដែលសល់តាំងពីសម័យសង្គ្រាមមក | ✓ | | | -មានការផ្ដល់ទឹកស្អាត និងកន្លែងស្នាក់នៅសមរម្យ និងសាងសង់បង្គន់អនាម័យត្រឹមត្រូវដល់បុគ្គលិក-កម្មករ។<br>-បង្កើតឲ្យមានបន្ទប់ ពិនិត្យព្យាបាលជំងឺ ហើយនឹងផ្ដល់ថ្នាំពេទ្យសម្រាប់ព្យាបាលគ្រប់គ្រាន់ និងអប់រំ-ណែនាំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងពីបញ្ហាជំងឺឆ្លងផ្សេងៗ។<br>- ក្រុមហ៊ុនត្រូវធ្វើការដោះសំអាតមីនជាមុនសិន មុននឹងចាប់ផ្ដើមដំណើរការឈូសឆាយដីសាងសង់ការដ្ឋាន ធ្វើផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។<br>- មណ្ឌុះបណ្ដាលដល់កម្មករនូវវិធីប្រើប្រាស់ឧបករណ៍/គ្រឿងចក្រព្រមទាំងបំពាក់នូវឧបករណ៍សុវត្ថិភាពដល់កម្មករ។ | |
| គ.១.៣ ផ្លូវគមនាគមន៍ | សកម្មភាពនៃការដឹកជញ្ជូនសម្ភារៈចេញ-ចូល អាចធ្វើ | | | | | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| | ឲ្យមានការខូចខាតដល់ផ្លូវលំនិងស្ពានសាធារណៈដែលប្រជាជនធ្លាប់តែប្រើប្រាស់ ការសាងសង់ និង ការជួសជុលផ្លូវសំរាប់ប្រើប្រាស់ជាផ្លូវ សំរាប់ទំនាក់ទំនងក្នុងទីតាំងគម្រោងរបស់ក្រុមហ៊ុន អាចនឹងធ្វើអោយមានការរំខាន ដល់ការធ្វើដំណើរការរបស់ប្រជាជនក្នុងតំបន់។ | ✓ | | | - ខិតខំស្ដាបនាផ្លូវនេះអោយបានរួចរាល់ឆាប់រហ័សហើយ ដាក់ឲ្យប្រើប្រាស់ជាសាធារណៈ។<br>-កំណត់ទំនង់ផ្ទុក និងល្បឿននៅពេលធ្វើចរាចរ។<br>- ធ្វើការថែទាំ និងជួសជុលផ្លូវដែលមាននៅតំបន់គម្រោង។ | |
| ៣. ដំណាក់កាលធ្វើអាជីវកម្ម | | | | | | |
| ក. បរិស្ថានធម្មជាតិ | | | | | | |
| ក.១ ធនធានរូបសាស្ត្រ | | | | | | |
| ក.១.១ សណ្ឋានដី | គម្រោងនឹងប្រើប្រាស់គ្រឿងចក្រកាយយកដីស្រទាប់លើ ដែលពុំមានរ៉ែចេញ ហើយក្រុមហ៊ុន នឹងយកអាចម៍ដីទាំងនោះទៅចាក់គរនៅក្រៅការដ្ឋាន ដើម្បីរក្សាទុកចាក់បំពេញការដ្ឋានឡើងវិញ នៅពេលប្រតិបត្តិការជីកយករ៉ែត្រូវបានបញ្ចប់។ ការបកស្រទាប់ដីលើចេញ គឺធ្វើឡើងជាដំណាក់ៗ។ សកម្មភាពឈូសឆាយគំរបដីចេញនេះនឹងមានការផ្លាស់ប្តូរនូវទ្រង់ទ្រាយសណ្ឋានដី ដោយសារការឈូសឆាយដី ជីក កកាយដែលមានរណ្តៅធំៗ និងមានជំរៅជ្រៅ ឬធ្វើឲ្យរណ្តៅធំៗ ទាំងនោះក្លាយទៅជាស្រះតូចៗ ដែលបញ្ហានេះបាន បណ្តាលឲ្យ | ✓ | | | - ធ្វើការឈូសឆាយសណ្ឋានដីអោយទៅតាមផែនការកំនត់ ដោយជៀសវាង នូវការធ្វើអោយប៉ះពាល់ដល់សណ្ឋានដីច្រើន និងត្រូវមានការត្រួតពិនិត្យ និងវាយតំលៃពីមន្ត្រីជំនាញ។<br>- ការជីករណ្តៅ ក្រុមហ៊ុននឹងកំណត់យកជំរៅសមស្របបំផុតអាស្រ័យទៅតាមសណ្ឋានដីដែលអាចធ្វើទៅបាន ដើម្បីអង្កេតពីស្ថានភាពនៃស្រទាប់រ៉ែពិតប្រាកដ។<br>- សំរាប់អាចម៍ដីដែលបានជីករួច ក្រុមហ៊ុននឹងគរទុកនៅ ក្នុងទីតាំងដ៏សមគួរក្បែរនោះ សំរាប់ទុកកាយលប់រណ្តៅទាំងនោះវិញ ដែលឲ្យមានឥរិយាបថដីប្រហាក់ប្រហែល ឬ នីវ៉ូដីដែលនៅក្បែររណ្តៅ និងដាំដើមឈើដែលសម | |

Draft

| | | | | | |
|---|---|---|---|---|---|
| | មានការប្រែប្រួលស្ថានភាពកំរិតទឹជំរាលដែលមាននូវក្នុងតំបន់។ | | | ស្របទៅនឹងតំបន់ គម្រោងឡើងវិញ មុនពេលក្រុមហ៊ុនប្តូរទៅទីតាំងការដ្ឋានផ្សេងទៀត។ | |
| ក.១.២ ការហូរច្រោះដី | សកម្មភាពទាំងឡាយរបស់គម្រោងដូចជា ការកកាយ ការជីកការបាញ់ទឹករ៉ែងរ៉ែ នឹងធ្វើឲ្យមានការហូរច្រោះដី នៅទីតាំងគម្រោង ហើយម្យ៉ាងទៀត ទ្រង់ទ្រាយសណ្ឋានដីនៃតំបន់គម្រោងជាតំបន់ទីជំរាលដូចមានបង្ហាញជូនក្នុងជំពូក ទី៤។ ដូចនេះវាងាយនឹងសឹករិចរិល និងហូរច្រោះដី ដែលនាំនូវកករល្បាប់ម៉ដ្ឋហូរចូលទៅកាន់ទីតាំងទំនាបក្បែរខាង ឬ ហូរចូលទៅក្នុងប្រភពទឹកអូរ ដោយសារសកម្មភាព ទាំងឡាយរបស់គម្រោង។ | | ✓ | - ដើម្បីធានាបានកុំឲ្យមានហេតុប៉ះពាល់បរស្ថានអវិជ្ជមានលើការហូរច្រោះដីចូលទៅក្នុងអូរ និងខូចខាតផ្លូវ ក្រុមហ៊ុននឹង អនុវត្ត នូវវិធានការណ៍ដូចជា ការជីកដីយករ៉ែនៅតំបន់នីមួយៗ គឺមានគំលាតឆ្ងាយពីអូរយ៉ាងហោចណាស់ចំនួន ៥០ម៉ែត្រ (គិតពីកំរិត ជន់អតិបរិមានៃទឹក) និងគំលាតចេញពីផ្លូវវិញ គឺមានចំងាយ ៣០ម៉ែត្រ ដើម្បីទប់ស្កាត់ការហូរច្រោះដី។ រីឯមាត់រណ្តៅត្រូវបាន កាយដីស្រទាប់លើមួយចំនួន ដើម្បីទប់ ជុំវិញចំពោះរណ្តៅដែលបានជីកមិនទាន់បានកប់រួចរាល់។<br>-ស្រាវកន់លប់ និងដាំដើមឈើ លើគម្របដីឡើងវិញភ្លាមៗ ក្រោយពេលយករ៉ែរួច។<br>- ក្រុមហ៊ុននឹងធ្វើប្រឡាយក្របរណ្តៅរ៉ែ ធ្វើការសាងសង់ផ្លូវទឹកតូចៗសំរាប់បង្វៀងផ្លូវទឹកលើតំនរអាចម៍ដីនិងរណ្តៅរ៉ែដើម្បីធ្វើការគ្រប់គ្រង ទឹកភ្លៀងអោយហូរទៅកាត់ប្រភពទឹកផ្សេងៗ ដើម្បីកាត់បន្ថយការហូរច្រោះដី ដោយសារតែល្បឿនទឹកហូរខ្លាំង នៅពេលមានភ្លៀងធ្លាក់ម្តងៗ ។<br>- កំណត់ពេលវេលានិងផែនការអោយបានច្បាស់លាស់ | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ក្នុងការធ្វើអាជីវកម្មនៅរដូវភ្លៀង។<br>- មិនត្រូវធ្វើអាជីវកម្មនៅរដូវភ្លៀងខ្លាំងទេ ដើម្បីជៀសវាងសំណល់រាវដែលមានសារធាតុកករល្អក់ ល្បាប់ម៉ដ្ឋ ឬ អាចម៍ដីរ៉ែហូរចេញពីការដ្ឋានចូលទៅក្នុងប្រភពទឹកអូរក្នុងតំបន់គម្រោង។ | |
| ក.១.៣ គុណភាពដី | ការហៀរ កំពប់ការទុកដាក់ឬច្រាលចោលប្រេងម៉ាស៊ីនលែងប្រើទៅលើដី ការទុកដាក់/ការចោលនូវសំណល់ប្រេង-ខ្លាញ់សំបកកំប៉ុង ប្រេងម៉ាស៊ីន សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗទៀត អាចនឹងមានការប៉ះពាល់គុណភាពដី ប្រសិនបើខាងក្រុមហ៊ុនមិនបានធ្វើការគ្រប់គ្រងអោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ | | ✓ | | - ក្រុមហ៊ុននឹងត្រួតពិនិត្យគ្រឿងចក្រគ្រប់ប្រភេទអោយបានល្អ ជាប្រចាំ ដើម្បីកាត់បន្ថយនូវការលេចជ្រាបប្រេងម៉ាស៊ីន នៅពេលចេញ-ក្រោយពេលប្រតិបត្តិការ។<br>- ទុកដាក់នូវប្រេងឥន្ធនៈសំរាប់បំរើការងារ នៅក្នុងការដ្ឋាន និងសំណល់ប្រេងម៉ាស៊ីនឲ្យបានត្រឹមត្រូវ ។<br>- មានផែនការគ្រប់គ្រងសំណល់រឹង-រាវគ្រប អោយបានល្អប្រសើរដោយជីកជារណ្តៅ និងសង់បង្គន់។<br>- ធ្វើការណែនាំ និងអប់រំដល់បុគ្គលិក-កម្មករ ដោយហាមប្រាមមិនអោយមានការបោះចោលសំរាម ។ | |
| ក.១.៤ គុណភាព និង ជលសាស្ត្រទឹកលើដី | - សកម្មភាពគម្រោង បាននាំអោយមានការប៉ះពាល់គុណភាពទឹកអូរ ដោយសារសំណល់រឹង-រាវ សំណល់ផ្ទះបាយ សំណល់ប្រេង និង សំណល់ផ្សេងៗទៀត ដែលមិនបានគ្រប់គ្រងអោយបានត្រឹមត្រូវ។<br>- ការកើនឡើងនូវកករល្បាប់ម៉ដ្ឋ/ភក់ ដោយសារសកម្មភាពឈូសឆាយ ដែលមិនមានផែនការច្បាស់ | ✓ | | | - គ្រប់គ្រងសំណល់រឹងនិងសំណល់រាវ ដោយរៀបចំប្រមូលសំណល់រឹងយកទៅចោលនៅក្នុងរណ្តៅ ព្រមទាំងសាងសង់បង្គន់អនាម័យ<br>- សាងសង់កន្លែងស្តុកប្រេងឥន្ធនៈអោយបានត្រឹមត្រូវ។<br>- ធ្វើការឈូសឆាយដីនៅរដូវប្រាំង ។ ក្នុងករណីមានការឈូសឆាយដីរដូវវស្សាក្រុមហ៊ុននឹងប្រតិបត្តិក្នុងទ្រង់ | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| | លាស់ក្នុងការកាត់បន្ថយការហូរច្រោះដីសំណឹកដី សំណល់ថ្មមិនមានផ្ទុកសារធាតុរ៉ែដែលជីកយកចេញពីអណ្តូងរ៉ែ និងការបង្ហូរសំណល់រាវពីការលាង រ៉ែង រ៉ែ។ ប្រព័ន្ធជលសាស្ត្រធម្មជាតិលើដីអាច ប្រែប្រួលដូចជាធ្វើអោយរាំងស្ទះចរន្តទឹក មានការផ្លាស់ប្តូរទិសដៅចរន្តទឹក និងល្បឿនទឹកនៅក្នុងតំបន់គម្រោង ។ | | | | ទ្រាយតូច។<br>- អនុវត្តតាមផែនការមេរបស់ក្រុមហ៊ុន ដោយមានការតាមដាននិងត្រួតពិនិត្យពីមន្ត្រីជំនាញ ។<br>- ក្រុមហ៊ុនមិនត្រូវបង្ហូរសំណល់រាវ ដែលមានសារធាតុកករល្អក់ល្បាប់ម៉ដ្ឋ ឬអាចម៍ដី ចូលទៅក្នុងប្រភព ទឹកអូរនានាដែលមាននៅក្នុងតំបន់គម្រោង។<br>-ក្រុមហ៊ុននឹងត្រូវសាងសង់ទីតាំងរក្សាសំណល់ថ្ម គឺត្រូវត្រូវហ៊ុំព័ទ្ធទៅដោយទំនប់ដែលជញ្ជាំងទំនប់មានកម្រាស់ និងកំពស់ខ្ពស់ល្មមជានាដល់ការមិនបាក់រលំសំណល់ថ្ម ឬការមិនហៀរហូរទឹកកង្វក់មកក្រៅនៅពេលមានភ្លៀងធ្លាក់ខ្លាំង។ នៅផ្នែកកណ្តាលនៃទីតាំងនេះត្រូវបង្កប់បំពង់បញ្ឈរមួយ ដែលអាចអោយគេត្រួតពិនិត្យបានពីគុណភាពទឹក នៅផ្នែកបាតនៃទីតាំងស្តុកទុកសំណល់ថ្មនេះផងដែរ។ វិធានការបន្សាបមួយចំនួននឹងត្រូវប្រើប្រាស់នៅពេលពិនិត្យឃើញថាគុណភាពទឹកនៃបាតទំនប់នេះ អាចបង្កនូវការបំពុលបាន។ ជញ្ជាំងទំនប់នឹងមានដាំដើមឈើដើម្បីធានាទប់មិនឲមានការរលំជញ្ជាំងទំនប់ និងកាត់បន្ថយការជ្រាបចេញនូវទឹកកខ្វក់។ | |
| ក.១.៥ គុណភាព និង ជលសាស្ត្រទឹកក្រោមដី | ការស្តុកប្រេងឥន្ធនៈ ការហៀរ ឬកំពប់ប្រេងទៅលើដី សំណល់រឹង សំណល់ផ្ទះបាយ សំណល់បង្គន់អនាម័យ និងសំណល់ផ្សេងៗទៀតអាចនឹងធ្វើអោយមាន | ✓ | | | -ក្រុមហ៊ុននឹងកាត់បន្ថយនូវការលេចជ្រាបនៃប្រេងចេញពីម៉ាស៊ីននឹងធ្វើការត្រួតពិនិត្យនូវគ្រឿងចក្រមុននឹងចេញ ប្រតិបត្តិការ។ | |

| | | | | | | |
|---|---|---|---|---|---|---|
| | ការបំពុលប្រភពទឹកក្រោមដីប្រសិនបើក្រុមហ៊ុនមិនបានធ្វើការគ្រប់គ្រងសំណល់ ទាំងនោះអោយបានត្រឹមត្រូវ។ | | | | - សាងសង់ឃ្លាំងទុកដាក់ប្រេងឥន្ធនៈប្រកបដោយសុវត្ថិភាព ដើម្បីជៀសវាងការហៀរ កំពប់ ឬជ្រាបទៅក្នុងដី។<br>-គ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទអោយបានល្អប្រសើរដោយជីកជារណ្តៅ និងសង់បង្គន់។<br>- ការឈូសឆាយដីត្រូវអនុវត្តឡើង ស្របតាមផែនការមេជាក់លាក់ដោយធ្វើការឈូសឆាយប្រកបដោយប្រសិទ្ធភាពលប់រណ្តៅនិងដាំដើមឈើ(ពូជក្នុងស្រុក)ភ្លាមៗក្រោយពេលយករ៉ែរួច។<br>-ក្រុមហ៊ុននឹងត្រូវសាងសង់ ទីតាំងសំណល់ពីការចម្រាញ់រ៉ែដើម្បីរក្សាទុក ដែលមានទំនប់ដីរឹងមាំព័ទ្ធជុំវិញបាតនិងជញ្ជាំងនៃអាងស្តុកត្រូវក្រាលទៅដោយដីឥដ្ឋ និងពាសគ្របពីលើដោយផ្លាស្ទិកដើម្បីធានាថាមិនមានការជ្រាបចេញនូវសារធាតុពុលចូលទៅក្នុងស្រទាប់ ទឹកក្រោមដី។ បាតនៃអាងត្រូវមានបង្កប់បណ្តាញទុយោសម្រាប់បូមទឹកដែលបន្សាបជាតិពុលរួចហើយទៅកាន់អាងតំកល់ទឹកទី១ សម្រាប់ការប្រើប្រាស់ជាថ្មី។ ទុយោបញ្ឈរនៅផ្នែកខាងក្នុងនៃ អាងក៏ត្រូវបានរៀបចំសម្រាប់ត្រួតពិនិត្យគុណភាពទឹកនៅ បាតអាងស្តុកសំណល់ពីការចម្រាញ់រ៉ែនេះផងដែរ។ កំហាប់ជាតិស៊ីយ៉ានួរដែលនៅក្នុងសំណល់ពីអាងត្រាំរ៉ែ ត្រូវបានបន្សាបដោយកាល់ស្យូមអ៊ីប៉ូក្លរីតដែលគេដាក់បញ្ចូលទៅក្នុងសំណល់ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ទាំងនោះ និងដោយកាំរស្មីស្វាយអ៊ុលត្រាពីពន្លឺព្រះអាទិត្យ៕ | |
| ក.១.៦ គុណភាពខ្យល់ | សកម្មភាពការឈូសឆាយដី ការដុតមែកឈើ-ស្លឹកឈើដើម្បីសំអាតការដ្ឋាន មុននឹងការកាយយកធនធានរ៉ែមានតំលៃការបំភាយឧស្ម័នពុលពីគ្រឿងចក្រ ការបាត់ តុល្យភាពនៃការស្រូបយក ឧស្ម័នពុលគ្រឿងចក្រ ការបាត់ តុល្យភាពនៃការស្រូបយក ឧស្ម័នកាបូនឌីអុកស៊ីត និងការ បញ្ចេញឧស្ម័នអុកស៊ីសែន បានធ្វើអោយមានការប្រែប្រួលគុណភាពខ្យល់នៅក្នុងតំបន់។ | ✓ | | | - ការបំពុលខ្យល់ដែលបង្កឡើងដោយសកម្មភាពឈូសឆាយដី ក្នុងតំបន់គម្រោង នឹងត្រូវកាត់បន្ថយតាមរយៈនៃតាមផែនការមេរបស់ក្រុមហ៊ុន។<br>- ប្រើប្រាស់គ្រឿងចក្រ ដែលមានគុណភាពខ្ពស់និងមានបំពាក់តំរងចម្រោះឧស្ម័នត្រឹមត្រូវ ដើម្បីកាត់បន្ថយការបញ្ចេញនូវឧស្ម័នពុលទៅក្នុងបរិយាកាស។ | |
| ខ.១ ធនធានជីវសាស្ត្រ | | | | | | |
| ខ.១.១ ធនធានព្រៃឈើ | ធនធានព្រៃឈើ គឺមានចំនួនតិចប៉ុណ្ណោះដោយសារតែព្រៃឈើនៅតំបន់តំរោងគឺមានតែនៅលើភ្នំប៉ុណ្ណោះ ចំពោះនៅតាមជើងភ្នំវិញគឺសុទ្ធតែដីចំការ និងដីលំនៅដ្ឋានរបស់ប្រជាជនស្ទើរតែទាំងអស់ ហើយភ្នំមួយចំនួនត្រូវបានកាប់រានយកដីធ្វើចំការជាបណ្តើរៗ ។ដូចនេះ វត្តមានរបស់គំរោងអាចនឹងធ្វើអោយប៉ះពាល់ដល់ធនធានព្រៃឈើទាំងនោះ ក្នុងករណីដែលខ្សែរ៉ែមាននៅកន្លែងធនធានព្រៃឈើទាំងនោះ ដោយសារតែការឈូសឆាយដីព្រៃដើម្បីយករ៉ែ។ | ✓ | | | -ធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មករទាំងអស់ របស់គម្រោងអោយមានការប្រុងប្រយ័ត្ន ដើម្បីជៀសវាង ភ្លើងឆេះព្រៃ។<br>-បំពាក់ស្លាបសញ្ញាសំគាល់របស់ គម្រោងនៅលើគ្រឿងចក្រនិងអប់រំណែនាំ ដល់បុគ្គលិក-កម្មករ ទាំងអស់របស់គម្រោង អោយពាក់នូវប័ណ្ណ សំគាល់របស់គម្រោងអោយបានជាប់ជានិច្ចនៅ ពេលធ្វើការ ដើម្បី ជៀសវាងពីជនឆ្លៀត ឱកាសមួយចំនួនបន្លំខ្លួនជាបុគ្គលិករបស់គម្រោងក្នុងការកាប់រានព្រៃឈើបែបអនាធិបតេយ្យ។<br>-ក្រុមហ៊ុនត្រូវរួសរាន់លប់ និងដាំដើមឈើ (ពូជក្នុងស្រុក | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | )លើតំបន់ដីឡើងវិញភ្លាមៗបន្ទាប់ពីយករ៉ែរួច។<br>- សហការអោយបានជាប្រចាំជាមួយ រដ្ឋបាលព្រៃឈើក្នុងតំបន់ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើដែលអាចកើតមានក្នុងតំបន់គម្រោង។ | |
| ខ.១.២ សត្វព្រៃនិង ទីជំរក | ពពួកសត្វព្រៃ ដែលមាននៅក្នុងតំបន់គំរោងគឺមានចំនួនតិចប៉ុណ្ណោះដោយសារតែព្រៃឈើនៅតំបន់គំរោងគឺមានតែនៅលើភ្នំប៉ុណ្ណោះ ចំពោះនៅតាមជើងភ្នំគឺសុទ្ធតែដីចំការ និងដីលំនៅដ្ឋានស្ទើរតែទាំងអស់។ ពពួកសត្វទាំងនោះ បានពឹងអាស្រ័យទៅលើព្រៃធម្មជាតិ ដែលមានក្នុងតំបន់នេះដូចនេះ ប្រភេទសត្វមួយចំនួន នឹងមានការថយចុះដោយការងាប់ ឬបំលាស់ទីទៅរស់នៅកន្លែងផ្សេង ដើម្បីស្វែងរកអាហារចិញ្ចឹមដោយសារតែមានការបាត់បង់នូវទីជំរក ប្រភពចំណីអាហារ កន្លែងបន្តពូជ ការរំខានដោយសំលេងពីសកម្មភាពគម្រោង និងបទល្មើសសត្វព្រៃពីសំណាក់ជនឆ្លៀតឱកាសនិយម។ | ✓ | | | - ប្រតិបត្តិទៅតាមផែនការមេរបស់ក្រុមហ៊ុន ដោយបែងចែកជាប្លុករួចអនុវត្តតាមបណ្តាឆ្នាំដែលបានបញ្ជាក់ក្នុងជំពូកទី៣។ការអនុវត្តន៍បែបនេះធ្វើអោយសត្វព្រៃក្នុងតំបន់អាចបំលាស់ទីក្នុងកាស្វែងរកចំណីអាហារក៏ដូចជាការបង្កនូវស្ថានភាពអំណោយផលដល់សត្វព្រៃក្នុងការរស់នៅបែបលក្ខណៈធម្មជាតិ។<br>- កំណត់ពេលវេលាធ្វើការច្បាស់លាស់ដូចជាធ្វើការតែនៅពេលថ្ងៃនិងប្រើប្រាស់គ្រឿងចក្រអោយបានសមស្រប។<br>- ធ្វើការអប់រំដល់បុគ្គលិក-កម្មកររបស់គម្រោង) មិនអោយធ្វើការបរបាញ់សត្វគ្រប់ប្រភេទនៅតំបន់នេះ ហើយធ្វើការគ្រប់គ្រងចំពោះ បទល្មើសសត្វព្រៃនានាដោយសហការ រដ្ឋបាលព្រៃឈើ និងមន្ត្រីជំនាញនៃមន្ទីរបរិស្ថានជាប្រចាំ។ | |
| ខ.១.៣ ជីវៈចម្រុះក្នុងទឹក | ភាពល្អក់កករ និងការនាំមកនូវល្បាប់ម៉ត់ ភាពរលួយនៃកំទេចកំទីឈើ និងស្លឹកឈើ ការចោលសំណល់រឹង និងការបង្ហូរសំណល់រាវទៅក្នុងប្រភពទឹកអូរ ការបំរែ | ✓ | | | - កំណត់យកការតាំងទីលំនៅរបស់បុគ្គលិក-កម្មករស្ថិតនៅឆ្ងាយពីប្រភពទឹក(លើសពី១០០ម) ឯការឈូស | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| | បំរួលចរន្តទឹកហូរ ការថយចុះនូវកំរិតអុកស៊ីសែនក្នុងទឹកនឹងអាចបង្កឲ្យមានការប៉ះពាល់ដល់មជ្ឈដ្ឋានរស់នៅរបស់បណ្តាភាវៈរស់ក្នុងទឹកផងដែរ។ | | | | ឆាយដី នឹងធ្វើឡើងតែនៅរដូវប្រាំង ដើម្បីកាត់បន្ថយការហូរនាំកំទេចកំទីមែកឈើ-ស្លឹកឈើ កំទេចកំទីផ្សេងៗទៀត និង ល្បាប់ម៉ដ្ឋទៅក្នុងប្រភពទឹកអូរ។<br>- ចូលរួមថែរក្សានូវគុណភាពទឹកអូរ ការពារការហូរច្រោះដី ជាពិសេសឆាប់រួសរាន់ក្នុងការលប់រណ្តៅ និងដាំដើមឈើ (ពូជក្នុងស្រុក)ឡើងវិញ និងគ្រប់គ្រងសំណល់រឹង-រាវ ដោយណែនាំដល់បុគ្គលិក-កម្មករមិនអោយបោះចោល ឬ បង្ហូរដោយផ្ទាល់ចូលទៅអូរជាដាច់ខាត។<br>- ទុកដាក់និងលាងសំអាតគ្រឿងចក្រនៅឆ្ងាយពីប្រភពទឹក | |
| ខ.១.៤ ធនធានរ៉ែផ្សេងៗទៀត | - នឹងមានការបាត់បង់នូវធនធានរ៉ែផ្សេងៗទៀតក្នុងបរិមាណច្រើន ដែលនៅក្បែរ នៅលើ រឺនៅក្រោមស្រទាប់រ៉ែមាស នៅពេលដែលខាងម្ចាស់គំរោងបានចាប់ផ្តើមធ្វើអាជីវកម្ម។ | | ✓ | | ចំពោះធនធានរ៉ែផ្សេងៗទៀតដែលខាងក្រុមហ៊ុនបានប្រទះឃើញ ក្រុមហ៊ុននឹងធ្វើការរក្សាទុក ហើយធ្វើរបាយការណ៍ទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីចាត់ចែងតាមលក្ខណៈជាក់ស្តែង។ | |
| គ.១ បរិស្ថានសង្គម | | | | | | |
| គ.១.១ សិទ្ធនៃការប្រើប្រាស់ទឹករបស់សហគមន៍ | ការរំខានដល់ការប្រើប្រាស់ទឹករបស់ប្រជាជន(ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ សំរាប់ឲ្យសត្វផឹក និងសំរាប់ ការងារកសិកម្ម) ក្នុង និងជុំវិញតំបន់គំរោង ដោយសារការទប់ទឹកប្រើតែនៅក្នុងតំបន់គំរោង | | ✓ | | - មិនធ្វើការរាំងខ្ទប់ ឬឈូសឆាយលប់ប្រភពទឹកដែលធ្វើឲ្យប៉ះពាល់ដល់បរិមាណធារទឹកតាមប្រភពទឹក ហើយ គំរោងនឹងចូលរួមថែរក្សាគុណភាព ប្រភពទឹក អូរ ដោយមិនបង្ហូរសំណល់រាវពីការលាងរ៉ែដោយផ្ទាល់ចូល | |

| | | | | | | |
|---|---|---|---|---|---|---|
| | ការល្បួសឆាយលប់ប្រភពទឹក ការបំពុលប្រភពទឹក។ល។ | | | | ទៅក្នុងទឹកអូរ និងតាមរយៈការគ្រប់គ្រងសំណល់រឹង រាវឲ្យមានប្រសិទ្ធិភាព ព្រមទាំងដាក់ និងលាងសំអាតគ្រឿងចក្រឲ្យនៅឆ្ងាយពីប្រភពទឹកស្ទឹង។<br>- ធ្វើការអប់រំដល់កម្មករអោយចេះជួយថែរក្សាគុណភាពប្រភពទឹកអូរ ដោយមិនអោយបោះចោលនូវសំរាមពាសវាលពាសកាលឡើយ។<br>រក្សាទុកនូវផ្ទៃដីព្រៃទ្រនាប់ដងអូរមួយចំនួន ដែលប្រការនេះបានចូលរួមជួយថែរក្សាគុណភាពទឹកក៏ដូចជាបរិមាណ ទឹកតាមរយៈការថែរក្សាព្រៃឈើ ដែលជាប្រភពទាក់ទាញ ទឹកភ្លៀង និងការរក្សាទុកទីជំរាល ដើម្បីជួយដល់ការទប់ ស្កាត់ការហូរច្រោះដី និងកំទេចកំទីនានាចូលក្នុងប្រភពទឹក អូរ ដែលនាំឲ្យបាត់បង់គុណភាពទឹក។ | |
| គ.១.២ ប្រពៃណី-វប្បធម៌របស់សហគមន៍មូលដ្ឋាន | -គំរោងនេះអាចបណ្តាលឲ្យប៉ះពាល់ដល់ប្រពៃណី និងជំនឿរបស់បុគ្គលិក-កម្មករគំរោង ដែលធ្វើការចំរុះគ្នាមកពីតំបន់ផ្សេងៗគ្នា ហើយមាននិន្នាការគោរពជំនឿ និងការរស់នៅផ្សេងៗគ្នាដែរ។ | ✓ | | | -ធ្វើការសិក្សាអំពីប្រពៃណី ទំនៀមទំលាប់របស់សហគមន៍មូលដ្ឋានដើម្បីផ្សព្វផ្សាយដល់បុគ្គលិក-កម្មករឲ្យបានយល់ ពីបញ្ហានេះ។<br>-ធានាការពារ និងថែរក្សាទំនៀមទំលាប់ ប្រពៃណី និងជំនឿសាសនាដែលមានស្រាប់របស់សហគមន៍។ | |

| | | | | | | |
|---|---|---|---|---|---|---|
| គ.១.៣ មុខរបរ និងប្រាក់ចំណូល | ធ្វើចំការ(ដាំពោត ដំឡូងមី និងសណ្តែក)ដែលជាមុខរបរចំបង របស់ពួកគាត់ ដោយសារការទប់ទឹកប្រើតែនៅក្នុងតំបន់គំរោង ការលុបប្រភពទឹក និងការបំពុលប្រភពទឹកផ្សេងៗ។ | | ✓ | | - អនុញ្ញាតអោយប្រជាជនប្រើប្រាស់ផ្លូវរបស់ក្រុមហ៊ុនជាប្រយោជន៍សាធារណៈ ។<br>- ជ្រើសរើសយកប្រជាជនដែលរស់នៅក្នុងតំបន់គំរោងជាអាទិភាពមកធ្វើជាបុគ្គលិក-កម្មករឲ្យបានច្រើន។ | |
| គ.១.៤ សុខភាព/សុវត្ថិភាពរបស់បុគ្គលិក-កម្មករ | -ទីតាំងគំរោងស្ថិតនៅតំបន់ព្រៃភ្នំ ដូចនេះកម្មករអាចនឹងងាយកើតនូវជំងឺផ្សេងៗដូចជា ជំងឺគ្រុនចាញ់ រាគរូស សើរស្បែកជាដើម វាក៏អាចនឹងមានគ្រោះថ្នាក់ជាយថាហេតុ ដែលបណ្តាលមកពីការប្រើប្រាស់ ឧបករណ៍ និងគ្រឿងចក្រដែលប្រើសំរាប់ដំណើរការឈូសឆាយដី និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង។<br>- ជាមួយគ្នានេះដែរ វាក៏អាចនឹងមានគ្រោះថ្នាក់ជាយថាហេតុដែលបណ្តាលមកពីគ្រាប់មីនមិនទាន់ផ្ទុះដែលមានក្នុងដីព្រៃ ឬដីចំការដែលសល់តាំងពីសម័យសង្គ្រាម។ | ✓ | | | -មានការផ្តល់ទឹកស្អាត និងកន្លែងស្នាក់នៅសមរម្យ និងសាងសង់បង្គន់អនាម័យត្រឹមត្រូវដល់បុគ្គលិក-កម្មករ។<br>- បង្កើតឲ្យមានបន្ទប់ពិនិត្យព្យាបាលជំងឺ និងផ្តល់ថ្នាំពេទ្យ សំរាប់ព្យាបាលគ្រប់គ្រាន់ និងអប់រំ ណែនាំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងពីបញ្ហាជំងឺឆ្លង។<br>- ក្រុមហ៊ុនត្រូវធ្វើការបោសសំអាតមីនជាមុនសិន មុននឹង ចាប់ផ្តើមដំណើរការឈូសឆាយដីសាងសង់ការដ្ឋានធ្វើផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។<br>- បណ្តុះបណ្តាលដល់កម្មករនូវវិធីប្រើប្រាស់ឧបករណ៍/គ្រឿងចក្រព្រមទាំងបំពាក់នូវឧបករណ៍សុវត្ថិភាពដល់កម្មករ និងដាក់សញ្ញាសំគាល់ពីគ្រោះថ្នាក់ដែលអាចកើតមាន។ | |
| គ.១.៥ ការរំខានដោយសំលេង និងរំញ័រ | សកម្មភាពគ្រឿងចក្រក្នុងការឈូសឆាយបកស្រទាប់ដី លើ ការជីកកកាយ ការដឹកជញ្ជូនដីដែលមាន | ✓ | | | -ប្រើប្រាស់នូវគ្រឿងចក្រដែលមានគុណភាពរួមជាមួយនឹងផែនការប្រើប្រាស់គ្រឿងចក្រប្រកបដោយប្រសិទ្ធិ | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| | សារធាតុ រ៉ែមាសទៅរោងក្នុងការដ្ឋាន និងការដឹកជញ្ជូនអាចម៍ដី យកទៅស្តុកទុកក្នុងតំបន់គំរោងបានបង្កើតជាសំលេង និងរំញ័រ កត្តានេះបានធ្វើឲ្យមានការរំខានដល់សុខភាពរបស់ប្រជាជនដែលរស់នៅក្នុង និងក្បែរទីតាំង គំរោង។ | | | | ភាព ដោយជៀសវាងការបញ្ឆេះម៉ាស៊ីននៅពេលណាដែលមិនចាំបាច់ និងមិនឲ្យលើសពី ៦០ dB(A) សំរាប់តំបន់លំនៅដ្ឋាន ដែលស្ថិតក្នុងចន្លោះពីម៉ោង៦ព្រឹកដល់ម៉ោង៦ល្ងាច។<br>-កំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះ ដោយមិនធ្វើការរំខានដល់ការរស់នៅរបស់ប្រជាជនដែលរស់នៅក្នុង និងក្បែរតំបន់គំរោង។<br>-កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសំភារៈចេញចូល តំបន់គំរោង។<br>-សាងសង់បន្ទប់សំរាបដាក់ម៉ាស៊ីនភ្លើងដែលប្រើក្នុងគំរោង ហើយម៉ាស៊ីនភ្លើងត្រូវបំពាក់ឧបករណ៍កាត់បន្ថយសំលេង ដើម្បីកាត់បន្ថយនូវការបញ្ចេញសំលេងខ្លាំងនៅពេលយប់។ | |
| គ.១.៦ ផ្លូវគមនាគមន៍ | សកម្មភាពនៃការដឹកជញ្ជូនរបស់ក្រុមហ៊ុននៅក្នុងដំណាក់កាលនេះមានសកម្មភាពមមាញឹកក្នុងការដឹកសំភារៈចេញ ចូលអាចធ្វើឲ្យមានការខូតខាតដល់ផ្លូវលំ សាធារណៈ ដែលប្រជាជនធ្លាប់តែប្រើប្រាស់។ | ✓ | | | -កំណត់ទំងន់ផ្ទុក និងល្បឿននៅពេលដឹកជញ្ជូនឆ្លងកាត់ លើផ្លូវសាធារណៈទាំងអស់នោះ។<br>-ធ្វើការថែទាំ និងជួសជុលផ្លូវដែលមានក្នុងតំបន់គំរោង ដើម្បីធានាអោយបានការប្រើប្រាស់យូរអង្វែង។ | |
| គ.១.៧ ហានិភ័យ | គំរោងអាចនឹងកើតមាននូវការបំពុលទឹកអូរ និងប្រភពទឹកដទៃទៀតនៅពេលមានទឹកជន់លិចរណ្តៅរ៉ែ ដែលបណ្តាលឲ្យទឹកខ្ពុលចេញពីរណ្តៅទៅបំពុល | | ✓ | | -កំណត់យកទីតាំងរណ្តៅនៅចំងាយ៥០ម៉ែត្រពីអូរដែលគិតពីកំរិតទឹកជំនន់ខ្ពស់បំផុតដែលធ្លាប់មានកន្លងមក។<br>- រុសរាន់លុប និងដាំដើមឈើលើគំរបដីឡើងវិញភ្លាមៗ | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| | ដល់ប្រភពទឹកទាំងនោះ។ | | | | ក្រោយពេលយករ៉ែរួច។<br>- មានរៀបចំមុខទឹកបញ្ចៀសរណ្ដៅរ៉ែ<br>-ផ្អាកសកម្មភាពនៃការធ្វើអាជីវកម្មក្នុងករណីមានភ្លៀងធ្លាក់ខ្លាំង<br>-ធានាមិនបង្ហូរសំណល់រាវដែលមានសារធាតុកករល្អក់ចូល ទៅក្នុងប្រភពទឹកស្ទឹង អូរ ដែលមានក្នុងតំបន់គំរោង។ | |
| ៤. ដំណាក់កាលបញ្ចប់គំរោង | | | | | | |
| ក. បរិស្ថានធម្មជាតិ | | | | | | |
| ក. ១ ធនធានរូបសាស្ត្រ | | | | | | |
| ក.១.១ សណ្ឋានដី | - ធ្វើឲ្យមានការប៉ះពាល់ដល់ដីតំបន់នោះដោយគំរោង បានធ្វើឲ្យមានការប៉ះពាល់ដល់ដីនៅតំបន់នោះដោយ គម្រោងបានបន្សល់ទុកនូវរណ្ដៅជ្រៅជាច្រើនក្រោយពី ការធ្វើអាជីវកម្មរ៉ែមាសចប់រួចរាល់។ | | ✓ | | - គំរោងនឹងធ្វើការលុប និងដាំដើមឈើ(ពូជក្នុងស្រុក)ឡើងវិញជាបន្ទាន់លើរណ្ដៅទាំងនោះអោយបានល្អប្រសើរឡើងវិញ ក្រោយពីសកម្មភាពទាញយកស្រទាប់រ៉ែត្រូវបានបញ្ចប់។ | |
| ក.១.២ គុណភាពដី | នៅដំណាក់កាលបញ្ចប់គំរោងនេះនឹងធ្វើឲ្យដីបាត់បង់ជីជាតិ ដោយសារការជីករករ៉ែ ការឈូសឆាយដី ការបាត់បង់គំរបដី ការបន្សល់ទុកនូវអាចម៍ដីពីការរែងរ៉ែត្បូង និងការបោះចោលសំណល់រឹង-រាវគ្រប់ប្រភេទ។ | ✓ | | | -យកអាចម៍ដីទៅចាក់បំពេញក្នុងរណ្ដៅដែលបានយករ៉ែដើម្បីបង្កើតឲ្យមានគំរបដីឡើងវិញ ដោយក្រុមហ៊ុនដាំដើម ឈើភ្លាមៗនៅលើទីតាំងរណ្ដៅរ៉ែព្រមទាំងបន្តធ្វើអាជីវកម្ម តាមផែនការមេដែលបានកំណត់។ | |
| ក.១.៣ គុណភាពជីវៈចំរុះ | -ការគ្រប់គ្រងសំណល់រឹង/រាវ ដែលមិនត្រឹមត្រូវតាម | ✓ | | | - ក្រុមហ៊ុននឹងសំអាតទីតាំងគំរោងឲ្យបានល្អឡើងវិញ | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| ក្នុងទឹក | លក្ខណៈបច្ចេកទេសវានឹងបណ្តាលឲ្យមានការប៉ះពាល់ដល់គុណភាពប្រភពទឹកស្ទឹង ជាពិសេសនៅពេលមានភ្លៀងធ្លាក់បាននាំសំណល់ទាំងនោះហូរចូល ទៅប្រភពទឹក។ | | | | ដូច ជាធ្វើការប្រមូលសំណល់រឹង/សំរាមយកទៅទុកដាក់ក្នុងរណ្តៅឲ្យបានសមស្រប និងប្រកបទៅដោយលក្ខណៈ បច្ចេកទេសក្រោមការផ្តល់យោបល់ពីជំនាញក្រសួងបរិស្ថាន ដើម្បីធានាមិនអោយមានការបំពុលទឹកក្នុងតំបន់នោះ។<br>-នឹងធ្វើការលុបនូវអាងស្តុកសំណល់ទាំងនេះឲ្យបានត្រឹមត្រូវ ជៀសវាងបង្ហូរសំណល់ការចេញពីបង្គន់អនាម័យចូល ទៅក្នុងប្រភពទឹកដោយសហការជាមួយមន្រ្តីជំនាញនៃក្រសួងបរិស្ថាន ដើម្បីទុកដាក់សំណល់គ្រប់ប្រភេទឲ្យបានត្រឹមត្រូវ។ | |
| ខ. ធនធានជីវសាស្រ្ត | | | | | | |
| ខ.១ ធនធានព្រៃឈើ | - ក្រោយពេលដែលគំរោងដកចេញពីទីតាំងគំរោងទៅនឹងធ្វើឲ្យមានការបាត់បង់នូវប្រភេទដើមឈើក្នុងតំបន់ មួយចំនួន។ | | ✓ | | - គំរោងនឹងធ្វើការដាំដើមឈើ(ពូជក្នុងស្រុក) ឡើងវិញផង ដែរនូវប្រភេទឈើក្នុងតំបន់ ដើម្បីជំនួសដើមចាស់ប្រសិន បើខាងគំរោងបានកាប់ក្នុងប្រការណាមួយ។ | |
| | | | | | | |
| គ.បរិស្ថានសង្គម | | | | | | |
| ខ.១ មុខរបរ និងប្រាក់ចំណូល | នៅដំណាក់កាលបញ្ចប់គំរោងបានធ្វើឲ្យមានការប៉ះពាល់ដល់មុខរបរ និងប្រាក់ចំណូលរបស់ប្រជាជនដែលធ្លាប់តែមានមុខរបរទាក់ទងនឹងគំរោងនេះដូចជាធ្វើជាកម្មករ ជាអ្នកលក់ដូរទំនិញឲ្យក្រុមហ៊ុន។ល។ | | ✓ | | -នឹងខិតខំស្នើសុំធ្វើគំរោងផ្សេងៗទៀតក្នុងតំបន់ បើសិនមានការគាំទ្រពីរាជរដ្ឋាភិបាល ដើម្បីជួយកាត់បន្ថយនូវការបាត់បង់ការងាររបស់ប្រជាជនក្នុងតំបន់។ | |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | - នឹងបណ្តុះបណ្តាលជំនាញបន្ថែមទៀតដល់កម្មករ ហើយ ចេញជាលិខិតបញ្ជាក់ពីបទពិសោធន៍របស់កម្មករ<br>- នឹងផ្សព្វផ្សាយពីការបិទគំរោងរបស់ក្រុមហ៊ុនទៅឲ្យបុគ្គលិក-កម្មករ ដែលបំពើការងារឲ្យបានដឹងជាមុន យ៉ាងហោចណាស់ ០៣ខែ។ | |
| ខ.២ ផ្លូវគមនាគមន៍ | នៅក្នុងដំណាក់កាលបញ្ចប់គំរោងនេះអាចនឹងមានការធ្វើឲ្យខូចខាតនូវហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់គំរោងដោយសារតែសកម្មភាពក្នុងការដឹកជញ្ជូនសំភារៈ និងផលិតផលចេញ-ចូលការដ្ឋានកន្លងមក។ | ✓ | | | - នឹងធ្វើការជួសជុលផ្លូវក្នុងតំបន់ឲ្យបានល្អប្រសើរឡើងវិញ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងករណីណាដែលមានការខូចខាតដោយសារសកម្មភាពគំរោង ដើម្បី ទុកជាប្រយោជន៍សាធារណៈសំរាប់ប្រជាពលរដ្ឋប្រើប្រាស់ ក្នុងតំបន់គំរោង។ | |

## ៦.៣ ហេតុប៉ះពាល់បរិស្ថានវិជ្ជមាន

រាល់គំរោងអភិវឌ្ឍន៍ទាំងអស់តែងតែធ្វើឲ្យមានការប្រែប្រួលនូវស្ថានភាពបរិស្ថាននៅតំបន់ ដែលគំរោងតាំងនៅ។ រាល់ហេតុប៉ះពាល់ត្រូវបង្ហាញជា២ផ្នែកផ្ទុយគ្នាគឺ ហេតុប៉ះពាល់វិជ្ជមាន និងហេតុប៉ះពាល់អវិជ្ជមាន។ ថ្វីត្បិតតែហេតុប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងពីសកម្មភាពផ្សេងៗនៅគ្រប់ដំណាក់កាលរបស់គំរោង តែម្ចាស់គំរោងក៏មានផែនការ និងថវិកាសំរាប់អនុវត្តនូវវិធានការទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានទាំងនោះទៅតាមស្ថានភាពជាក់ស្តែងឲ្យនៅក្នុងកំរិតអប្បបរមា។

ជាក់ស្តែងសំរាប់គំរោងវិនិយោគអាជីវកម្មរ៉ែលោហៈរបស់ក្រុមហ៊ុន PHU YANG (CAMBODIA) Co.,Ltd បាន អនុវត្តនូវវិធានការកាត់បន្ថយ និងវិធានការជាក់ស្តែងផ្សេងៗទៀតនឹងធ្វើឲ្យគំរោងនេះផ្តល់ប្រយោជន៍ជាវិជ្ជមានច្រើន ដោយផ្ទាល់ និងដោយប្រយោលសំរាប់សហគមន៍ក្នុងតំបន់គំរោង និងប្រទេសជាតិទាំងមូល។ ហេតុប៉ះពាល់បរិស្ថានវិជ្ជមានសំខាន់ៗ ដែលសហគមន៍ក្នុងតំបន់គំរោង និងប្រទេសជាតិអាចនឹងទទួលបាននៅរួមមានៈ

### ៦.៣.១ ធនធានរូបសាស្ត្រ និងជីវសាស្ត្រ

ក. ធនធានរ៉ែលោហៈ

គំរោងធ្វើអាជីវកម្មរ៉ែលោហៈ ក្នុងតំបន់នេះនឹងអាចជួយកាត់បន្ថយពីការហូរចូលនូវសកម្មភាពធ្វើរាជីវកម្មរ៉ែបែបអានាធិបតេយ្យក្នុងតំបន់។

ខ.ធនធានព្រៃឈើ និងសត្វព្រៃ

- ដោយសារវត្តមាននៃគំរោងនោះបានជួយផ្អាក ឬលុបបំបាត់សកម្មភាពបែបអាណាធិបតេយ្យរបស់ជនឆ្លៀតឱកាសមួយចំនួនដូចជាៈ ការរានដីព្រៃធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ការកាប់ព្រៃឈើ និងការបរបាញ់សត្វ។ល។
- គំរោងនឹងជួយស្តារឡើងវិញនូវតំបន់ដីព្រៃដែលរេចរិលតាមរយៈផែនការដាំដើមឈើឡើងវិញ នៅតាមការដ្ឋានរបស់គំរោង។ ប្រការនេះបានជួយកាត់បន្ថយនូវរហោស្ថានកម្ម និងជួយបង្កើនសោភ័ណភាពក្នុងតំបន់។
- ព្រំប្រទល់គំរោង និងបណ្តាផ្លូវក្នុងទីតាំងគំរោងនឹងក្លាយជាផ្លូវសំរាប់ការពារភ្លើងឆេះព្រៃបានយ៉ាងប្រសើរ។

គ. គុណភាព និងការហូរច្រោះដី

តាមរយៈនៃការបង្កើតគំរបដីឡើងវិញដោយសកម្មភាពដាំដើមឈើ (ពូជក្នុងស្រុកសមស្រប) ឡើងវិញនៅតាមការដ្ឋានរបស់គំរោងអាចជួយលុបបំបាត់តំបន់ដីព្រៃរេចរិល និងបានជួយជំរុញឲ្យមានការកាត់បន្ថយ ការហូរច្រោះដី សំណល់ស្លឹកឈើ កំណល្បប់ហូរចូលប្រភពទឹក និងហូរទៅកាត់តំបន់ផ្សេងៗទៀត ជាពិសេសបានជួយបង្កើននូវជីជាតិដល់ដីនៅតំបន់នោះ។

ឃ. គុណភាពខ្យល់

ការដាំឈើឡើងវិញលើផ្ទៃដីតំបន់រេចរិល (នៅការដ្ឋានអាជីវកម្មរបស់គំរោង) ឡើងវិញ អាចជួយសំអាតភាពកខ្វក់នៃខ្យល់ បង្កើនឧស្ម័នទ្រទ្រង់ជីវិតមនុស្ស-សត្វ អុកស៊ីសែន ($O_2$) និងបង្កើនកំរិតស្រូបនូវឧស្ម័នពុលក្នុងបរិយាកាសដូចជា ឧស្ម័នកាបូនិក ($CO_2$) ជាដើម។

## ៦.៣.២ ធនធានសេដ្ឋកិច្ច-សង្គម

### ក.ការប្រើប្រាស់ដី និងសុវត្ថិភាពនៃការប្រើប្រាស់ដី

ដោយសារតែតំបន់នេះធ្លាប់ជាតំបន់សមរភូមិ ហេតុដូចនេះហើយទើបមកដល់បច្ចុប្បន្ននេះក៏គេនៅសង្កេតឃើញថា តំបន់នេះជាតំបន់ដែលសំបូរទៅដោយមីន និងគ្រាប់មិនទាន់ផ្ទុះជាច្រើនដែលបានកប់នៅក្នុងដីរាយពាសពេញតំបន់នេះ។ យ៉ាងណាមិញដោយសារតែវត្តមាននៃក្រុមហ៊ុនក្នុងតំបន់បានធ្វើការដោះមីនក្នុងតំបន់នោះ ដែលបានផ្តល់ប្រយោជន៍ក្នុងការបង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ដី និងក៏ដូចជាបង្កើនសុវត្ថិភាពក្នុងការធ្វើដំណើរក្នុងតំបន់នោះផងដែរ។

### ខ.ហេដ្ឋារចនាសម្ព័ន្ធ

គំរោងវិនិយោគមានការសាងសង់នូវផ្លូវគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនក្នុងតំបន់គំរោង ដែលមានដូចចែងក្នុងផែនការមេរបស់ក្រុមហ៊ុន ប្រការនេះបានជំរុញឲ្យមានការឈានទៅមុខមួយជំហ៊ានទៀតនូវការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់។ ចំពោះផ្លូវគមនាគមន៍ថ្មីក្នុងតំបន់គំរោងនឹងត្រូវបានឈូសឆាយ និងថែទាំសំរាប់ទុកជាប្រយោជន៍ប្រើប្រាស់ជាសាធារណៈ។

### គ. មុខរបរ និងប្រាក់ចំណូល

- ការងារជាច្រើន និងត្រូវបានបង្កើតឡើងដោយសារតំរូវការរបស់គំរោងវិនិយោគ ដែលកត្តានេះបានធ្វើឲ្យប្រជាជនក្នុងសហគមន៍មានការងារធ្វើ ដែលអាចនឹងទទួលបាននូវប្រាក់ចំណូលជាទៀងទាត់សំរាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ បន្ថែមពីនេះទៀតកាតទទួលបានជំនាញពីការងារដែលទទួលបានពីការបំពាក់បំប៉នពីសំណាក់ក្រុមហ៊ុន។
- ក្រៅពីធ្វើការឲ្យគំរោង ប្រជាជនអាចបែរមកទាញប្រាក់ចំណូលបន្ថែម តាមរយៈការផ្គត់ផ្គង់ជាស្បៀងអាហារ ។ល។

### ឃ. កាត់បន្ថយចំណាកស្រុក

- ការបង្កើតការងារជាច្រើនរបស់ក្រុមហ៊ុន បានជួយឲ្យមានការកាត់បន្ថយចំណាកស្រុកនៃប្រជាជនក្នុងតំបន់ដើម្បីទៅរកការងារធ្វើ ដែលនេះបានផ្តល់ជាប្រយោជន៍សំរាប់រាជរដ្ឋាភិបាលសំរាប់ធ្វើផែនការគ្រប់គ្រង និងអភិវឌ្ឍន៍

### ង. ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

- ក្រុមហ៊ុននឹងជំរុញឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិតាមរយៈការបង់ពន្ធអាករលើការនាំចូលគ្រឿងចក្រ និងប្រេងឥន្ធនៈសំរាប់ការប្រើប្រាស់ក្នុងការប្រតិបត្តិគំរោង ពន្ធកាត់ទុក ពន្ធលើប្រាក់ចំនេញ និងពន្ធអាករផ្សេងៗទៀត ក្នុងរយៈពេលប្រតិបត្តិការ និងថែទាំគំរោងទៅតាមកិច្ចសន្យារវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា។
- សកម្មភាពធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបានបង្កើតនូវទំនាក់ទំនងសង្វាក់ផលិតកម្ម និងឧស្សាហកម្មនានាដូចជា ការលក់ដូរម្ហូបអាហារ និងការផលិតគ្រឿងចក្រនានាជាដើម។

ច. ការបង្ហាញពីទិដ្ឋភាពល្អប្រសើក្នុងដំណើរការវិនិយោគនានា

- ដោយសារនៅពេលមានដំណើរការល្អប្រសើរនៃការវិនិយោគលើការធ្វើអាជីវកម្មរ៉ែមាសនៅតំបន់នេះបានបង្ហាញទៅដល់អន្តរជាតិពីទិដ្ឋភាពល្អប្រសើរនៃដំណើរការវិនិយោគគ្រប់ប្រភេទក្នុងប្រទេសកម្ពុជា ដែលនេះជាផ្លូវឈានទៅដល់ការបើកទូលាយដល់ការធ្វើវិនិយោគនានាមកកាន់ប្រទេសជាតិយើង។

តារាង ៦.២ : ការកំណត់ពីទំហំនៃហេតុប៉ះពាល់វិជ្ជមាន

| ធនធានបរិស្ថាន | ទំហំ | ការពិពណ៌នា |
|---|---|---|
| ធនធានរូបសាស្ត្រ និងជីវសាស្ត្រ | | |
| ធនធានរ៉ែលោហៈ | C | គំរោងធ្វើអាជីវកម្មរ៉ែលោហៈក្នុងតំបន់នេះនឹងអាចជួយកាត់បន្ថយពីការហូរចូលនូវសកម្មភាពធ្វើអាជីវកម្មរ៉ែបែបអាណាធិបតេយ្យក្នុងតំបន់។ |
| ធនធានព្រៃឈើ និងសត្វព្រៃ | C | -ដោយសារវត្តមាននៃគំរោងនៅតំបន់នោះបានជួយផ្អាក ឬលុបបំបាត់សកម្មភាពបែបអាណាធិបតេយ្យរបស់ជនឆ្លៀតឱកាសមួយចំនួនដូចជាៈ ការរានដីព្រៃ ការកាប់ព្រៃឈើ និងការបរបាញ់សត្វ។ល។<br>-គំរោងនឹងជួយស្តារឡើងវិញនូវតំបន់ដីព្រៃដែលរេចរិលតាមរយៈផែនការដាំដើមឈើឡើងវិញនៅតាមការដ្ឋានរបស់គំរោង។ ប្រការនេះបានជួយកាត់បន្ថយនូវរហោស្ថានកម្ម និងជួយបង្កើនសោភ័ណភាពក្នុងតំបន់។<br>- ព្រំប្រទល់គំរោង និងបណ្តាផ្លូវក្នុងតំបន់គំរោងនឹងក្លាយជាផ្លូវសំរាប់ការពារភ្លើងឆេះព្រៃបានយ៉ាងប្រសើរ។ |
| គុណភាព និងការហូរច្រោះដី | C | តាមរយៈការបង្កើតឡើងវិញដោយសកម្មភាពដាំដើមឈើ (ពូជក្នុងស្រុកសមស្រប) ឡើងវិញនៅតាមការដ្ឋានរបស់គំរោងអាចជួយលុបបំបាត់តំបន់ដីព្រៃរេចរិល និងបានជួយជំរុញឲ្យមានការកាត់បន្ថយការហូរច្រោះ សំណល់ស្លឹកឈើកំណាល្បប់ហូរចូលចូលប្រភពទឹក និងហូរទៅកាត់តំបន់ផ្សេងៗទៀតជាពិសេសបានជួយបង្កើននូវជីជាតិដល់ដីនៅតំបន់នោះ។ |
| គុណភាពខ្យល់ | C | - ការដាំឈើលើផ្ទៃដីតំបន់រេចរិល (នៅតាមការដ្ឋានអាជីវកម្មរបស់គំរោង) ឡើងវិញ អាចជួយសំអាតភាពកខ្វក់នៃខ្យល់ បង្កើនឧស្ម័នទ្រទ្រង់ជីវិត មនុស្ស-សត្វ ($O_2$) និងបង្កើនកំរិតស្រូបនូវឧស្ម័នពុលក្នុងបរិយាកាសដូចជា $CO_2$ ជាដើម |
| ធនធានសេដ្ឋកិច្ច-សង្គម | | |
| ការប្រើប្រាស់ដី និងសុវត្ថិភាពនៃការប្រើប្រាស់ដី | B | ដោយសារតែតំបន់នេះជាតំបន់ដែលធ្លាប់ជាសមរភូមិ ហេតុនេះហើយទើបមកដល់ពេលបច្ចុប្បន្ននេះក៏គេនៅសង្កេតឃើញថាតំបន់នេះជាតំបន់ដែលសំបូរទៅដោយមីន និងគ្រាប់មិនទាន់ផ្ទុះជាច្រើន ដែលបានកប់ក្នុងដីរាយពាសពេញនៅក្នុងតំបន់នេះ។ យ៉ាងណាមិញ ដោយសារតែវត្តមាននៃក្រុមហ៊ុនក្នុងតំបន់បានធ្វើការដោះមីនក្នុងតំបន់នោះដែលបានផ្តល់ជាប្រយោជន៍ក្នុងការបង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ដី និងដូចជាការបង្កើនសុវត្ថិភាពក្នុងការធ្វើដំណើរនៅក្នុងតំបន់ |
| ហេដ្ឋារចនាសម្ព័ន្ធ | A | -គំរោងវិនិយោគមានការសាងសង់ផ្លូវគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើន |

| | | |
|---|---|---|
| | | ក្នុងតំបន់គំរោង ដែលមានដូចចែងក្នុងផែនការមេរបស់ក្រុមហ៊ុន។ ប្រការនេះបានជំរុញឲ្យមានការឈានទៅមុខមួយជំហ៊ានទៀតនូវការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់។<br>-ចំពោះផ្លូវគមនាគមន៍ថ្មីក្នុងតំបន់គំរោងនឹងត្រូវបានឈូសឆាយ និងថែទាំសំរាប់ទុកជាប្រយោជន៍ប្រើប្រាស់ជាសាធារណៈ។ |
| មុខរបរ និងប្រាក់ចំណូល | A | -ការងារជាច្រើននឹងត្រូវបានបង្កើតឡើងដោយសារតំរូវការរបស់គំរោងវិនិយោគ ដែលកត្តានេះបានធ្វើឲ្យប្រជាជនក្នុងសហគមន៍មានការងារធ្វើ និងអាចទទួលបានចំណូលជាទៀងទាត់សំរាប់ការរស់នៅប្រចាំថ្ងៃ។ បន្ថែមពីនេះទៀតពួកគាត់បានទទួលជំនាញពីការងារ តាមរយៈការបណ្តុះបណ្តាលពីសំនាក់ក្រុមហ៊ុន។<br>- ក្រៅពីធ្វើការឲ្យគំរោង ប្រជាជនអាចបែរមកទាញប្រាក់ចំណូលបន្ថែមតាមរយៈការផ្គត់ផ្គង់ជាស្បៀងអាហារដល់បុគ្គលិក-កម្មករ។ |
| កាត់បន្ថយចំណាកស្រុក | B | -ការបង្កើតការងារជាច្រើនរបស់ក្រុមហ៊ុនបានជួយឲ្យមានការកាត់បន្ថយចំនាកស្រុកនៃប្រជាជនក្នុងតំបន់ដើម្បីទៅរកការងារធ្វើដែលនេះបានផ្តល់ជាប្រយោជន៍សំរាប់រាជរដ្ឋាភិបាលក្នុងការធ្វើផែនការគ្រប់គ្រង និងអភិវឌ្ឍន៍។ |
| ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ | A | -ក្រុមហ៊ុននឹងជំរុញឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តាមរយៈការបង់ពន្ធអាករលើការនាំចូលគ្រឿងចក្រ ប្រេងឥន្ធនៈសំរាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀតក្នុងរយៈពេលប្រតិបត្តិការ និងថែទាំគំរោងទៅតាមកិច្ចសន្យារវាងក្រុមហ៊ុន និងរាជរដ្ឋាភិបាលកម្ពុជា។<br>-សកម្មភាពធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបានបង្កើតទំនាក់ទំនងសង្វាក់ផលិតកម្ម និងឧស្សាហកម្មនានាដូចជា ការលក់ដូរម្ហូបអាហារ និងការផលិតគ្រឿងចក្រនានាជាដើម។ |
| ការបង្ហាញពីទិដ្ឋភាពល្អប្រសើរក្នុងដំណើរការវិនិយោគនានា | B | -ដោយសារនៅពេលមានដំណើរការល្អប្រសើរនៃការវិនិយោគលើអាជីវកម្មរ៉ែត្បូងនៅតំបន់នេះបានបង្ហាញទៅដល់អន្តរជាតិនានាពីទិដ្ឋភាពល្អប្រសើរនៃដំនើរវិនិយោគគ្រប់ប្រភេទក្នុងប្រទេសកម្ពុជា ដែលនេះជាផ្លូវឈានទៅដល់ការបើកទូលាយដល់ការធ្វើវិនិយោគនានាមកកាន់ប្រទេសជាតិយើង។ |

*សំគាល់:*

*A : ហេតុប៉ះពាល់បរិស្ថានវិជ្ជមានកំរិតធំ ឬច្រើន*

*B : ហេតុប៉ះពាល់បរិស្ថានវិជ្ជមានកំរិតមធ្យម*

*C : ហេតុប៉ះពាល់បរិស្ថានវិជ្ជមានកំរិតតិចតួច*

Draft

Draft